# ប្រវត្តិសង្ខេបពុទ្ធសាសនបណ្ឌិត្យ





# THE BUDDHIST INSTITUTE

## *A Short History*

# ការបោះពុម្ពលើកទី ១ ឆ្នាំ ២០០៥

©រក្សាសិទ្ធិគ្រប់បែបយ៉ាងដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ

ISBN- ១៣: ៩៧៨-៩៩៩៥០-៥០-០០-៩

ISBN- ១០: ៩៩៩៥០-៥០-០០-៥

បោះពុម្ពនៅទីក្រុងភ្នំពេញ ក្នុងព្រះរាជាណាចក្រកម្ពុជា ដោយរោងពុម្ព X7Design Group.

រចនាសៀវភៅដោយរោងពុម្ព X7Design Group.

ក្របខាងមុខ: ជារូបភាពរបស់ព្រះរាជបណ្ណាល័យ និងពុទ្ធសាសនបណ្ឌិត្យ ដែលបានទទួលមកពីបណ្ណសារដ្ឋានជាតិនៃព្រះរាជាណាចក្រកម្ពុជា។ រូបភាពដែលមានរចនាជាស៊ុមពទ្ធ័ជុំវិញពីឆ្វេងទៅស្តាំជារបស់ កញ្ញា ស៊ុយសាន ការប៊ុំឡៃស (ដកស្រង់ពីសារពត៌មាននគរវត្ត) លោក សឹង ង៉ុកថាន់ (ជាការប្រមូលដោយផ្ទាល់ខ្លួន) ព្រះតេជគុណ អ៊ុម ស៊ូរ ព្រះតេជគុណ ហួត តាត និងព្រះតេជគុណ ជួន ណាត (បានទទួលមកពីបណ្ណសារដ្ឋានជាតិនៃព្រះរាជាណាចក្រកម្ពុជា)។

ក្របខាងក្រោយ: ជារូបភាពពុទ្ធសាសនបណ្ឌិត្យថតនៅឆ្នាំ ២០០៥ ដោយលោក អេនថូនី ម៉ាឆ្វីរ៉ន

តំលៃដាក់លក់នៅវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ: ២ ដុល្លា ៥០ សេន

HEINRICH
BÖLL
FOUNDATION

Embassy of
the Federal
Republic of
Germany
Phnom Penh

៩២៩.២៨ក

# ប្រវត្តិសង្ខេប ពុទ្ធសាសនបណ្ឌិត្យ

ស្រាវជ្រាវ និងសរសេរដោយ

ឈាត ស្រ៊ាង
យិន សំបូរ
សេង ហុកម៉េង
ប៊ុង តក្តីបុរ៉ាមី
សោម សុរាសី

កែសម្រួលដោយ

ផេននី អែដវីដស៍

ពុទ្ធសាសនបណ្ឌិត្យ
បណ្ណាល័យ
LIBRARY
BUDDHIST INSTITUTE
0709/05

INSTITUT BOUDDHIQUE

ពុទ្ធសាសនបណ្ឌិត្យ
២០០៥

# ស្នាដៃនេះ

កើតឡើងពីកិច្ចសហការគ្នា រវាង

**ពុទ្ធសាសនបណ្ឌិត្យ** និង **បណ្ណាល័យអេឡិចត្រូនិចខ្មែរ**

ក្នុងគោលបំណងយ៉ាងមុតមាំដើម្បីថែរក្សា ការពារ កុំឲ្យបាត់បង់តទៅទៀត

ព្រមទាំងផ្សព្វផ្សាយស្នាដៃ-ឯកសារទាំងនេះ

សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ។

សូមថ្លែងអំណរគុណដល់

**អង្គការរីហ្សូ កូស៊ី-កៃ  វិទ្យាស្ថានបើកទូលាយ**

**ការុណាខ្មែរ និង មូលនិធិខ្មែរសម្រាប់ការសិក្សា**

ដែលបានគាំទ្រគម្រោងការស្នាដៃនេះ សម្រាប់ទុកក្នុងបណ្ណាល័យអេឡិចត្រូនិច។

Buddhist Institute of Ministry of Cult and Religion and eLibrary of Cambodia have made a cooperative effort to digitalize books and manuscripts in order to preserve our Cambodian literary heritage. This will promote and provide easy, instant access, free of charge to the public and future generations to come.

A sincere thank you to our generous supporters: Rissho Kosei-Kai, Open Institute, Karuna Cambodia and Cambodian Education Excellence Foundation, who made this endeavor possible.

www.budinst.gov.kh      www.elibraryofcambodia.org

# មាតិកា


សេចក្តីថ្លែងអំណរគុណ ៤
បុព្វកថា ៦
សេចក្តីផ្តើម ៧
ព្រះរាជបណ្ណាល័យ ១៩២១-១៩២៩ ១២
ពុទ្ធសាសនបណ្ឌិត្យ ១៩៣០-២០០៥ ២១
ការកកើត ១៩២៩-១៩៤២ ២១
អន្តរកាល ១៩៤២-១៩៥៤ ៣៤
សម័យឯករាជ្យ ១៩៥៤-១៩៧៥ ៣៨
ការបិទទ្វារ ១៩៧៥-១៩៩២ ៤១
ការចាប់បដិសន្ធិឡើងវិញ ១៩៩២-២០០៥ ៤១
សេចក្តីសន្និដ្ឋាន ៤៧
ជីវប្រវត្តិសង្ខេប ៤៩
កាលប្រវត្តិ ៦៩
សទ្ធានុក្រមឋានន្តរស័ក្តិក្នុងគណៈសង្ឃខ្មែរ ៧២
ឯកសារយោង ៧៥

## សេចក្តីថ្លែងអំណរគុណ

សៀវភៅនេះពុំអាចចេញជារូបរាងបាននោះទេ ប្រសិនបើពុំមានការឧបត្ថម្ភពីមូលនិធិហេនរិចបូល ដែលបានផ្តល់ថវិកាសំរាប់គម្រោងស្រាវជ្រាវអំពីពុទ្ធសាសនបណ្ឌិត្យពីខែមករាដល់ខែមិថុនា ឆ្នាំ២០០៥ ដែលជារយៈពេលយើងធ្វើការស្រាវជ្រាវ និងសរសេរ និងព្រមទាំងបានឧបត្ថម្ភមួយផ្នែកធំក្នុងការចំណាយសំរាប់ការបោះពុម្ព។ យើងខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅផងដែរ ដល់ស្ថានទូតអាល្លឺម៉ង់ដែលបានផ្តល់វិភាគទានមួយចំនួនរបស់ខ្លួនដល់ការបោះពុម្ព។

នៅពុទ្ធសាសនបណ្ឌិត្យ យើងទាំងអស់គ្នាមានអំណរសាទរជាខ្លាំង ដោយបានឃើញថា លោកនាយក ងួន វ៉ាន់ចន្ធី បានសំដែងនូវការគាំទ្ររបស់លោក យ៉ាងពេញទំហឹង លើគម្រោងស្រាវជ្រាវនេះ ចាប់តាំងពីពេលដំបូងមក ព្រមទាំងផ្តល់នូវបទសម្ភាស និងឯកសាររបស់វិទ្យាស្ថានទៀតផង។

ដើម្បីតាក់តែងឱ្យបានជាសៀវភៅដ៏ស្រស់ស្អាតមួយក្បាលនេះ យើងត្រូវចងចាំជានិច្ចគ្រប់ដង្ហើមចេញចូលរបស់យើងនូវគុណូបការៈរបស់សហសេវិកគ្រប់រូបទាំងក្នុង និងក្រៅប្រទេស។ ចាប់តាំងពីគម្រោងបានចាប់ផ្តើមនៅចុងឆ្នាំ២០០៤ អ្នកស្រី ហ្សាកគីលីន ហ្វីល្លីយ៉ូហ្សាត់ នៃសាលាបារាំងចុងបូព៌ាបានផ្តល់នូវការគាំទ្រដ៏សំខាន់ និងឯកសារកម្រមួយចំនួន ដែលជាសម្បត្តិផ្ទាល់របស់អ្នកស្រី និងរបស់សាលាបារាំងនៅទីក្រុងប៉ារីស។ លោកបណ្ឌិត គ្រីស្តូហ្វ៍ ហ្កូសសា ក៏បានបង្ហាញនូវចិត្តសប្បុរសដូចគ្នានេះដែរ តាមរយៈការផ្តល់ឯកសារដែលទាក់ទងនឹងពុទ្ធសាសនបណ្ឌិត្យ។ ដោយហេតុតែទំហំការសិក្សានេះនៅតូច យើងពុំទាន់បានប្រើប្រាស់ឯកសារទាំងនេះអស់នៅឡើយទេ។ យើងសង្ឃឹមថា កិច្ចការដ៏តូចមួយនេះពិតជាការបណ្តុះនូវគ្រាប់ពូជសំរាប់ពេលអនាគត ឱ្យមានការយកចិត្តទុកដាក់កាន់តែច្រើនចំពោះពុទ្ធសាសនាសម័យថ្មី និងការអភិវឌ្ឍរបស់វាក្នុងព្រះរាជាណាចក្រកម្ពុជា។ ដោយមានការរួមចំណែករបស់លោកស្រី និងលោកបណ្ឌិត ពុទ្ធសាសនបណ្ឌិត្យសព្វថ្ងៃមានឯកសារជាច្រើន ដោយបូករួមទាំងសារពត៌មានខ្មែរ នគរវត្ត ជាហ្វីល ដែលជាអំណោយសប្បុរសធម៌របស់លោកសាស្ត្រាចារ្យ ដេវីដ ឆេនដឡឺ។

ឯកឧត្តម នុត ណារ៉ាង ប្រធានគណៈកម្មការស្រាវជ្រាវនៃវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ បានផ្តល់នូវដំបូន្មានដ៏មានតំលៃ លើផ្នែកអត្ថន័យ និងការរៀបចំសៀវភៅនេះ។ លោកបណ្ឌិត ហ៊ាន សុខុម នៅមជ្ឈមណ្ឌលសំរាប់សិក្សាជាន់ខ្ពស់ បានជួយអានពង្រាងជាភាសាខ្មែរ និងបានផ្តល់នូវមត្តុទ្ទេសក៏ដ៏មានតំលៃផ្នែកអត្ថន័យ និងរចនាបទ។ ឯកឧត្តម ហ៊ីង គីមថន ក៏បានផ្តល់នូវពេលវេលាដ៏មានតំលៃរបស់លោកក្នុងការផ្តល់ពត៌មាន និងការចងចាំរបស់លោកទាក់ទងនឹងពុទ្ធសាសនបណ្ឌិត្យ កាលពីទសវត្សរ៍១៩៦០។ លោក ហង់រី លោកា បានផ្តល់នូវការលើកទឹកចិត្ត និងជំនួយល្អៗរហូតមក ដូចលោកបណ្ឌិត ឃឹង ហុក ឌី ដែរ។ ព្រះឧត្តមវិជ្ជា ឃី សុវណ្ណរតនា និង លោក ដេវីដ ឆេនដឡឺ បានសរសេរបុព្វកថាសំរាប់សៀវភៅនេះ។ លោកអេនថូនី ម៉ាឆ្ងីរ៉ន

បានស្ម័គ្រចិត្តបូជានូវពេលវេលា ជំនាញ និងគតិផ្នែកសោភ័ណរបស់លោកក្នុងការធ្វើគម្របសៀវភៅទាំងខាងមុខ ទាំងខាងក្រោយឱ្យមានជាសោភ័ណភាពគួរជាទីគយគន់។

លោកស្រី សាន់ដ្រា ចូនស៍ ទីប្រឹក្សាស្រាវជ្រាវនៃវិទ្យាស្ថាន បានជួយធ្វើការសម្របសម្រួលក្នុងការបោះពុម្ព។ យើងក៏សូមថ្លែងអំណរគុណចំពោះលោកស្រី និងលោក ស សុខនី ដែលបានត្បៀងគរករថវិកាសំរាប់ធ្វើការបោះពុម្ពនេះ។ ជាទីបញ្ចប់ យើងខ្ញុំជាអ្នកស្រាវជ្រាវទាំងអស់ ក៏សូមថ្លែងអំណរគុណដល់លោកបណ្ឌិត គ្រិចហ្គីរ មូឡឺ និងបុគ្គលិកទាំងអស់នៅ បណ្ណសារដ្ឋានជាតិ បណ្ណាល័យជាតិ និងបណ្ណាល័យពុទ្ធសាសនបណ្ឌិត្យ ដែលបានជួយសំរួលដល់ការរកឯកសារ ដែលទាក់ទងទាំងឡាយ។

# បុព្វកថា

នេះគឺជាសៀវភៅលើកដំបូងដែលនិយាយពិស្តារអំពីប្រវត្តិ តួនាទី សកម្មភាព និងវិភាគទានរបស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ តាំងពីការកកើតឡើងរហូតដល់សម័យបច្ចុប្បន្ន។ នៅក្នុងប្រវត្តិ៧៥ឆ្នាំ របស់ខ្លួន វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យបានឆ្លងកាត់នូវការវិវត្តយ៉ាងច្រើន។

ខ្ញុំព្រះករុណា អាត្មាភាពយល់ឃើញថា សៀវភៅនេះនឹងមានតំលៃយ៉ាងសំខាន់ចំពោះអ្នកអានទូទៅ និងអ្នកសិក្សាស្រាវជ្រាវអំពីវប្បធម៌ និងព្រះពុទ្ធសាសនាខ្មែរ។ ទោះបីជាមានទំហំតូចក៏ពិតមែន សៀវភៅនេះនឹងជាពន្លឺសំរាប់ការស្រាវជ្រាវជាបន្តទៀត ទាក់ទងនឹងវិភាគទានដ៏ថ្លៃថ្លាមិនអាចកាត់ថ្លៃបានរបស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យចំពោះព្រះពុទ្ធសាសនា និងវប្បធម៌ប្រពៃណីខ្មែរ។

ព្រះឧត្តមវិជ្ជា ឃី សុវណ្ណរតនា
ព្រះរាជាគណៈថ្នាក់កិត្តិយសជាទីប្រឹក្សាផ្ទាល់
សម្តេចព្រះសង្ឃរាជគណៈមហានិកាយ
សាស្ត្រាចារ្យនៃពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ

នេះគឺជាសៀវភៅដ៏មានតំលៃដែលបានពន្យល់ប្រាប់ពីប្រវត្តិនៃវិទ្យាស្ថានវប្បធម៌នៅក្នុងប្រទេសកម្ពុជានាសម័យទំនើប ហើយវាក៏បានផ្តល់នូវជីវប្រវត្តិដ៏គួរឱ្យចាប់អារម្មណ៍របស់អ្នកប្រាជ្ញនិងព្រះសង្ឃ ដែលខំប្រឹងប្រែងបំពេញភារកិច្ចយ៉ាងខ្លាំងក្លាដើម្បីពង្រឹងព្រះពុទ្ធសាសនាខ្មែរ និងដើម្បីប្រមូលចងក្រង និងផ្សព្វផ្សាយនូវពតិមានអំពីទំនៀមទម្លាប់ ប្រវត្តិសាស្ត្រ និងអក្សរសាស្ត្រខ្មែរ។

ខ្ញុំមានសេចក្តីសប្បាយរីករាយណាស់ក្នុងឱកាសនៃការប្រារព្ធនូវខួបទី ៧៥ របស់វិទ្យាស្ថាននេះ ហើយសូមកោតសរសើរផងដែរចំពោះការសិក្សាដែលគួរឱ្យចាប់អារម្មណ៍នេះ ។

សាស្ត្រាចារ្យ ដេវីដ ឆេនដ៏ឡឺ
សាកលវិទ្យាល័យ ម៉ូណាសនៃប្រទេសអូស្ត្រាលី ក្រុងមែលបិន
ថ្ងៃទី ២៧ ខែឧសភា ឆ្នាំ ២០០៥

# សេចក្តីផ្តើម

រយៈពេល ៧៥ឆ្នាំមកហើយដែល "ពុទ្ធសាសនបណ្ឌិត្យ" បានចូលរួមចំណែកក្នុងការផ្សាយព្រះពុទ្ធសាសនា និងអក្សរសាស្ត្រសំរាប់ដឹកនាំខេមរជនទាំងអស់ឱ្យឈានទៅរកអរិយធម៌ខ្ពង់ខ្ពស់។ សព្វថ្ងៃនេះ ពុទ្ធសាសនបណ្ឌិត្យបាននឹងកំពុងបំពេញនូវតួនាទីរបស់ខ្លួនយ៉ាងសកម្មក្នុងការសិក្សាស្រាវជ្រាវ និងប្រមូលចងក្រងឯកសារស្តីពីវប្បធម៌ខ្មែរ។ ក្រោមការដឹកនាំរបស់គណៈកម្មការស្រាវជ្រាវ និងវិទ្យាស្ថាន អ្នកស្រាវជ្រាវវ័យក្មេងមួយចំនួនត្រូវបានដាក់ពង្រាយក្នុងគម្រោងស្រាវជ្រាវ ដែលផ្តោតលើផ្នែក ប្រវត្តិសាស្ត្រ អក្សរសាស្ត្រ ព្រះពុទ្ធសាសនា ប្រពៃណី និងការប្រឈមមុខរបស់កម្ពុជាបច្ចុប្បន្ន។ តាមរយៈសកម្មភាពនេះ កេរ្តិ៍ឈ្មោះរបស់វិទ្យាស្ថានក្នុងវិស័យស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រ ពិតជានឹងមានសន្ទុះទៅមុខមិនខាន បើធៀបនឹងរយៈពេលកន្លងមក។

"វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ" ដែលយើងស្គាល់សព្វថ្ងៃនេះ មានវិវឌ្ឍន៍តាំងពីសម័យអាណាព្យាបាលបារាំងរហូតមកដល់បច្ចុប្បន្ន ទាំងសកម្មភាព តួនាទី ទាំងនាមរបស់ស្ថាប័ននេះ។ វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យកាលដំបូងបំផុត ត្រូវបានគេប្រសិទ្ធិនាមថាជា "វិទ្យាស្ថានស្រុកអាយសំរាប់ការសិក្សាព្រះពុទ្ធសាសនាថេរវាទ" ប៉ុន្តែក្រោយនោះបន្តិចមក ឈ្មោះនេះត្រូវបានគេសង្ខេបខ្លីមកនៅត្រឹមតែ "ពុទ្ធសាសនបណ្ឌិត្យ" តែប៉ុណ្ណោះ។ លើសពីនេះទៀត ឈ្មោះនេះក៏ត្រូវបានគេហៅប្លែកៗពីគ្នារហូតមក ដោយខ្លះហៅថា "ក្រុមពុទ្ធសាសនបណ្ឌិត្យ" ឬ "មន្ទីរពុទ្ធសាសនបណ្ឌិត្យ"។ ឈ្មោះទាំងនេះត្រូវបានគេប្រើរហូតមកដល់សម័យឯករាជ្យផងដែរ។ ពេលនោះទោះយ៉ាងណា អ្វីដែលគេនិយមប្រើនោះគឺ "វិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ" ប្រហែលជាដើម្បីលើកតម្កើងស្ថាប័នដ៏សំខាន់មួយនេះ ឱ្យសមនឹងប្រទេសដែលមានអធិបតេយ្យភាព។ ប៉ុន្តែជូនកាលក៏មានអ្នកខ្លះហៅស្ថាប័ននេះថាជា "ក្រសួងពុទ្ធសាសនបណ្ឌិត្យ" ផងដែរ។ ក្នុងចន្លោះឆ្នាំ១៩៥០-១៩៧៥ និងរហូតមកដល់បច្ចុប្បន្ននេះ វិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ ជាស្ថាប័នចំណុះឱ្យក្រសួងធម្មការ និងសាសនា។ សព្វថ្ងៃ ស្ថាប័ននេះត្រូវបានគេហៅជាផ្លូវការថា "វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ"។ តាមពិតទៅ ពាក្យថា "វិជ្ជាឋាន" និង "វិទ្យាស្ថាន" ពុំមានអ្វីប្លែកគ្នាសូម្បីតែបន្តិចនោះទេ។ ពាក្យទាំងពីរមានន័យជារួមថាជា "គ្រឹះស្ថានដែលធ្វើការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ"។

ការរស់ឡើងវិញរបស់វិទ្យាស្ថានស្រាវជ្រាវនេះក្នុងឆ្នាំ១៩៩២ ក្រោមការឧបត្ថម្ភពីរាជរដ្ឋាភិបាល ការជួយជ្រោមជ្រែងពីសំណាក់អង្គការផ្តល់ជំនួយបរទេសមួយចំនួន បានផ្តល់នូវសេចក្តីសង្ឃឹមមួយដ៏ធំដល់អ្នកស្រាវជ្រាវក្នុងការស្ថាបនាជាថ្មីម្តងទៀតនូវការចងក្រងអត្តសញ្ញាណវប្បធម៌ជាតិខ្មែរ។ ក្នុងដំណាក់កាលដំបូង ក្រោយពីការបំផ្លិចបំផ្លាញនៃរបបប្រល័យពូជសាសន៍ ដំណើរការរបស់វិទ្យាស្ថានត្រូវជួបនឹងការលំបាកយ៉ាងច្រើន ដែលក្នុងនោះ

រួមមានកង្វះខាតឯកសារសំរាប់ធ្វើការស្រាវជ្រាវ កង្វះខាតបុគ្គលិក និងការជួយលើកទឹកចិត្តពីមជ្ឈដ្ឋានផ្សេងៗ។ ទោះជាយ៉ាងណាក៏ដោយ ការស្ថាបនាជាថ្មីម្តងទៀតនូវស្ថាប័នស្រាវជ្រាវ ដែលធ្លាប់មានកិត្តិស័ព្ទល្បីល្បាញក្នុងអតីតកាលនេះ ពិតជាសញ្ញាមួយបង្ហាញឱ្យឃើញនូវការខ្វាយខ្វល់អំពីវប្បធម៌ជាតិ ដែលទទួលនូវការគំរាមកំហែងយ៉ាងខ្លាំងក្នុងសម័យមុនៗ។

ក្នុងសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា និងរដ្ឋកម្ពុជា សេរីភាពជំនឿសាសនាត្រូវបើកទូលាយសំរាប់ប្រជាពលរដ្ឋទូទៅ ក្រោមការកំណត់របស់ច្បាប់នៃនយោបាយដឹកនាំរបស់រដ្ឋ។ ក្នុងដំណាក់កាលស្តារឡើងវិញនូវឃឿនសេដ្ឋកិច្ចនេះ អតីតភាពរបស់ពុទ្ធសាសនបណ្ឌិត្យមិនត្រូវបានគេយកមកពិចារណានោះទេ។ នៅចុងទសវត្សរ៍ឆ្នាំ១៩៨០ គេឃើញមានសំណង់អគារមួយនៅវត្តឧណ្ណាលោម ដែលមានសរសេរផ្លាកពីមុខថា "ពុទ្ធសាសនបណ្ឌិត្យ" ប៉ុន្តែមិនមានការរៀបចំជាស្ថាប័ននោះទេ។

ក្រោយពីការដណ្តើមបានជោគជ័យរបស់កងទ័ពរំដោះលើនាយទាហានរបស់របបសាធារណរដ្ឋ លន់ នុល ក្នុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ប្រជាជនខ្មែរភាគច្រើនជឿថា ប្រទេសជាតិរបស់ខ្លួននឹងបានរួចផុតពីសង្គ្រាមស៊ីវិលក្នុងស្រុក ហើយវប្បធម៌ជាតិនឹងមានភាពរីកចំរើនទៅមុខជាមិនខាន។ ប៉ុន្តែទីបំផុត អ្វីដែលពួកគាត់ទាំងអស់គ្នាបានទទួលនោះ គឺផ្ទុយស្រលះពីសេចក្តីស្រមៃនេះ។ អ្វីដែលប្រជាជនធ្លាប់មានពីមុនមក ត្រូវបាត់បង់ស្ទើរទាំងអស់។ កម្មសិទ្ធិផ្ទាល់ខ្លួន សេរីភាពជំនឿសាសនា ការនិយាយស្តី សាលារៀន ការប្រើប្រាស់ក្រដាសប្រាក់ជាដើមត្រូវបានហាមឃាត់ទាំងអស់។ និយាយម្យ៉ាងទៀត ស្ថាប័នអ្នកចេះដឹង ក៏ដូចជាអ្នកប្រាជ្ញត្រូវបានកំទេចស្ទើរតែទាំងស្រុង។ ពុទ្ធសាសនបណ្ឌិត្យ ក៏មានជោគវាសនាដូចគ្នានេះដែរ ដោយត្រូវបានគេបង្ខំឱ្យបិទទ្វារចាប់តាំងពីថ្ងៃរំដោះ។ ក្រោយពីនោះមក ឯកសារដ៏ច្រើនលើសលប់ ដែលស្ថាប័ននេះធ្លាប់បានប្រមូលចងក្រងរហូតមកត្រូវបានដុតបំផ្លាញ ឬខូចខាតដោយការមិនយកចិត្តទុកដាក់ថែរក្សា។ គោលបំណងនៃរបបនេះក្នុងការបង្កើតនូវប្រវត្តិសាស្ត្រថ្មីមួយឱ្យប្រជាជនខ្មែរ ដែលមិនធ្លាប់មានក្នុងប្រវត្តិសាស្ត្រជាង២០០០ឆ្នាំ ពិតជាបានធ្វើឱ្យប្រពៃណីវប្បធម៌របស់ប្រជាជាតិនេះ ដែលធ្លាប់មានពីមុនមកត្រូវបានបំផ្លិចបំផ្លាញយ៉ាងធំធេង។

ឯកសារដែលធ្លាប់មានតំលៃ និងកិត្តិស័ព្ទរបស់ពុទ្ធសាសនបណ្ឌិត្យនៅសម័យមុនត្រូវបានបំផ្លាញតាមរូបភាពផ្សេងៗ។ ពុទ្ធសាសនបណ្ឌិត្យ នៅសម័យឯករាជ្យ ត្រូវបានស្រទាប់អ្នកសិក្សាយ៉ាងច្រើននៅទីក្រុងឱ្យតំលៃយ៉ាងខ្លាំង តាមរយៈការចែកផ្សាយនូវស្នាដៃរបស់ខ្លួនយ៉ាងទូលំទូលាយ ព្រោះថាបណ្ណាល័យរបស់វិទ្យាស្ថាននេះមានតម្កល់នូវក្បួនច្បាប់មានតំលៃដ៏ច្រើន ដែលអ្នកសិក្សាអាចសិក្សារៀនសូត្របន្តទៀតបាន។ ចំណែកនៅទីជនបទវិញ ឈ្មោះ និងសកម្មភាពរបស់វិទ្យាស្ថាននេះត្រូវបានគេស្គាល់យ៉ាងច្រើនដែរ តាមរយៈដំណើររបស់ខ្លួនដែល

ធ្លាប់មានតាំងពីការចាប់បដិសន្ធិក្នុងសម័យអាណានិគមមកនោះ។

រដ្ឋាភិបាលអាណាព្យាបាលបារាំង បានអនុញ្ញាតឱ្យមានការបង្កើតនូវស្ថាប័ននេះឡើងក្នុងឆ្នាំ១៩៣០ ក្នុងបំណងធ្វើការសិក្សាអំពីព្រះពុទ្ធសាសនានៅដែនឥណ្ឌូចិន ដើម្បីឱ្យក្លាយជាកំលាំងចលករមួយសំរាប់ប្រឆាំងនឹងការរីកសាយភាយនៃឥទ្ធិពលវប្បធមិរបស់សៀម។ ការងាររបស់វិទ្យាស្ថាននេះ ត្រូវធ្វើកិច្ចសហប្រតិបត្តិការយ៉ាងស្អិតរមួតជាមួយស្ថាប័នដទៃទៀតរួមមាន សាលាបាលីជាន់ខ្ពស់ ព្រះរាជបណ្ណាល័យ និងក្រុមជំនុំព្រះត្រៃបិដកដែលមានអាយុចាស់ជាងខ្លួន ក្នុងបំណងទប់ស្កាត់នូវឥទ្ធិពលវប្បធមិរបស់សៀម។

ទំនាក់ទំនងផ្នែកវប្បធមិ ក៏ដូចជាពុទ្ធសាសនា រវាងកម្ពុជានិងសៀមកើតមានឡើងជាយូរយាណាស់មកហើយ ពិសេសក្រោយពីខេមរជនលែងទទួលនូវឥទ្ធិពលពីសំណាក់ប្រទេសដែលធ្លាប់មានអរិយធមិខ្ពង់ខ្ពស់មានឥណ្ឌា និងស្រីលង្កាជាដើមនោះ។ ចំពោះផ្នែកពុទ្ធសាសនា ដោយហេតុតែការអប់រំនៅប្រទេសសៀមមានកំរិតខ្ពស់ជាងប្រទេសកម្ពុជានោះ ព្រះសង្ឃខ្មែរតែងតែបានធ្វើដំណើរទៅបន្តការសិក្សារបស់ខ្លួននៅទីនោះ។ តាមរយៈការសិក្សានេះ ពុទ្ធសាសនាខ្មែរបានទទួលនូវឥទ្ធិពលយ៉ាងច្រើនពីប្រទេសសៀមនេះ។

នៅសម័យអណានិគម ទោះជាប្រទេសសៀមមិនទទួលនូវការគ្រប់គ្រងផ្ទាល់ដោយបរទេសក៏ពិតមែនក៏ប្រទេសនេះស្ថិតនៅក្រោមឥទ្ធិពលរបស់រាជាណាចក្រអង់គ្លេស ដែលធ្វើអាណានិគមលើអាណាចក្រម៉ាឡេនិងភូមាដែរ។ ដោយសារមូលហេតុដូច្នេះហើយ បារាំងដែលជាដៃគូប្រជែងផ្នែកអាណានិគមជាមួយនឹងចក្រភពអង់គ្លេស តែងប្រើគ្រប់មធ្យោបាយដើម្បីទប់ស្កាត់នូវឥទ្ធិពលសៀមមកលើដែនឥណ្ឌូចិនដែលជាដែនដីអាណានិគមរបស់ផងខ្លួន។



ព្រះឆាយាល័ក្ខណ៍ព្រះមហាថេរ៥អង្គដែលជាមហាបណ្ឌិតបែកព្រះពុទ្ធសាសនាគណៈមហានិកាយ ប្រទេសកម្ពុជាក្នុងរវាងឆ្នាំ១៩៣១

មធ្យោបាយមួយក្នុងចំណោមនោះ តឺបារាំងបានបញ្ឈប់មិនឱ្យព្រះសង្ឃខ្មែរបន្តធ្វើដំណើរទៅសិក្សានៅប្រទេសសៀមតាមរយៈការពង្រឹងការអប់រំសាសនានៅកម្ពុជា។ នៅឆ្នាំ១៩០៩ មានការសាកល្បងបង្កើតឱ្យមានសាលាបាលីនៅសៀមរាប តែមិនបានទទួលជោគជ័យនោះទេ។ រហូតដល់ឆ្នាំ១៩១១ ទើបមានការបង្កើតឱ្យមានសាលាបាលីក្នុងព្រះរាជវាំងនៅទីក្រុងភ្នំពេញ ដែលនៅឆ្នាំ១៩១៤គេឱ្យប្តូរទៅអគារថ្មីនិងឱ្យឈ្មោះថា "សាលាបាលីជាន់ខ្ពស់" ដែលមានព្រះមហាវិមលធម្ម ថោង ជាចាងហ្វាងមុនគេបង្អស់។

ព្រះមហាវិមលធម្មនាម ថោង នេះ ជាអ្នកប្រាជ្ញបព្វជិត ដែលបានលើកតម្កើងឱ្យមានការសិក្សាព្រះធម៌វិន័យភាសាបាលី និងព្រះត្រៃបិដក។ ព្រះអង្គជាអ្នកដែលចាប់អារម្មណ៍លើការសិក្សាគម្ពីរព្រះត្រៃបិដក និងវិជ្ជាដទៃទៀតដើម្បីឱ្យសាសនារបស់ជាតិមានវិវឌ្ឍន៍ស្របនឹងការរីកចំរើនរបស់មនុស្សជាតិ។ ព្រះអង្គនៅតែគោរពនូវទំនៀមទម្លាប់ដូចព្រះមហាសង្ឃរាជ ទៀង មុនដែរ ប៉ុន្តែព្រះមហាវិមលធម្ម ថោង ក៏មិនញញើតនឹងប្រតិបត្តិតាមពុទ្ធោវាទសោះឡើយ។ ក្រៅពីនេះ ព្រះអង្គក៏មានការឧបត្ថម្ភចំពោះ ព្រះរាជបណ្ណាល័យ ស្ថាប័នមួយដែលមានទិសដៅលើកតម្កើងពុទ្ធសាសនាដូចគ្នានេះ។



ព្រះសង្ឃប្រើផាក្រាប ដែលជាសញ្ញាមួយរបស់គណៈមហានិកាយចាស់

ទន្ទឹមនឹងការស្តារឡើងវិញនូវសាសនាជាតិ ពុទ្ធសាសនបណ្ឌិត្យ ក៏បានផ្តោតការយកចិត្តទុកដាក់របស់ខ្លួនទៅលើផ្នែកប្រពៃណីទំនៀមទម្លាប់ខ្មែរផងដែរ។ ទិសដៅក្នុងការអប់រំផ្នែកសីលធម៌ដល់ខេមរជនមានតំលៃយ៉ាងធំធេង ហើយការប្រមូលចងក្រងនូវមរតកដែលជាអត្តសញ្ញាណជាតិក៏មានតំលៃជាមាសប្រាក់ដែរ។ ក្នុងពេលដែលប្រទេសកំពុងស្ថិតក្រោមការគ្រប់គ្រងរបស់បរទេសនោះ អ្នកស្នេហាជាតិនៅជំនាន់នោះបានប្រើប្រាស់ពុទ្ធសាសន

បណ្ឌិត្យដែលជាឃ្លាំងចំណេះដឹងរបស់ខ្មែរនេះប្រឆាំងនឹងអំពើបំផ្លិចបំផ្លាញវប្បធម៌ខ្មែរ តាមរូបភាពដែលអាចធ្វើទៅបាន ។ ការគិតគូរអំពីអនាគតរបស់វប្បធម៌ជាតិរបស់ស្ថាប័នជាតិនេះគួរត្រូវបានរៀនសូត្រ និងលើកតម្កើងឱ្យបានទូលំទូលាយ ។

ក្នុងបរិបទនយោបាយមួយ ដែលពុទ្ធសាសនបណ្ឌិត្យកំពុងតែខិតខំស្តារឡើងវិញ នូវកេរ្តិ៍ឈ្មោះជាប្រវត្តិសាស្ត្ររបស់ខ្លួនក្នុងផ្នែកស្រាវជ្រាវ និងប្រមូលចងក្រងឯកសារស្នាដៃទាំងឡាយណា ដែលទាក់ទងនឹងសាសនា ប្រវត្តិសាស្ត្រ អក្សរសិល្ប៍ សិល្បៈ ប្រពៃណីទំនៀមទម្លាប់ខ្មែរជាដើមនោះ ការសិក្សាអំពីវិវឌ្ឍន៍របស់ស្ថាប័នគួរតែត្រូវបានធ្វើតាមបែបវិទ្យាសាស្ត្រ ។ ប្រពៃណីនេះ បាននឹងកំពុងជំរុញឱ្យស្ថាប័ននេះក្នុងពេលបច្ចុប្បន្នធ្វើការតំរង់ទិសដៅរបស់ខ្លួន ដើម្បីចូលរួមឱ្យបានសកម្មខ្លាំងក្លាក្នុងការលើកតម្កើងតំលៃនៃអក្សរសាស្ត្រ និងវប្បធម៌ជាតិ ក្នុងយុគសម័យនៃសាកលភាវូបនីយកម្មនេះ ។ តាមរយៈការស្រាវជ្រាវនេះ យើងសង្ឃឹមថា តួនាទី និងសកម្មភាពរបស់វិទ្យាស្ថាន ដែលដំណើរការឡើងក្នុងបរិដ្ឋាននយោបាយកំណត់ណាមួយកាលពីអតីតកាល ពិតជានឹងអាចធ្វើជាមេរៀនមួយដែលមានតំលៃកាត់ថ្លៃពុំបាន ក្នុងការស្តារឡើងវិញ និងពង្រីកបន្ថែមនូវកិត្តិស័ព្ទរបស់ខ្លួនជាពុំខានឡើយ ។ ទន្ទឹមជាមួយនេះ តួនាទីរបស់ស្ថាប័ននាពេលបច្ចុប្បន្នក្នុងការថែរក្សានូវអត្តសញ្ញាណវប្បធម៌ ដែលជាដំណែលពីបុព្វបុរសខ្មែរ ប្រាកដជានឹងអាចចូលរួមចំណែកក្នុងការអភិវឌ្ឍប្រទេសជាតិជាពុំខានឡើយ ។

សូមបញ្ជាក់ផងដែរថា ការបោះពុម្ពនេះគ្រាន់តែជាស្នាដៃខ្លីមួយ របស់អ្នកស្រាវជ្រាវនៃវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ដោយដាក់បញ្ចូលគ្នានូវពត៌មានទាំងឡាយ ដែលប្រមូលបានក្នុងរយៈពេល៦ខែមកនេះ សំរាប់ការប្រារព្ធខួបទី៧៥របស់វិទ្យាស្ថាន ។ ដោយហេតុតែឯកសារដ៏ច្រើនលើសលុបត្រូវបានបំផ្លាញក្នុងរយៈកាលកន្លងមក ស្នាដៃនេះពឹងផ្អែកជាសំខាន់ទៅលើឯកសារ ដែលមាននៅបណ្ណសារដ្ឋានជាតិ ។ ប្រភពដទៃទៀតដែលយើងបានស្រាវជ្រាវមានឯកសារបោះផ្សាយដោយពុទ្ធសាសនបណ្ឌិត្យ កម្ពុជសុរិយា និងកាសែតនគរវត្តដែលជាកាសែតទី១ ផ្សាយជាខេមរភាសា ដែលសព្វថ្ងៃមានជាហ្វីលនៅពុទ្ធសាសនបណ្ឌិត្យ ក៏ដូចជាឯកសារជាភាសាខ្មែរ និងបារាំងសម័យសង្គមរាស្ត្រនិយមដែលរក្សាទុកនៅបណ្ណាល័យជាតិដែរ ។ ក្នុងកម្រងស្នាដៃលើកក្រោយ យើងខ្ញុំនឹងធ្វើការសិក្សាលំអិតទៅលើការរីកចំរើន និងតួនាទីរបស់ស្ថាប័ននេះ ពិសេសក្រោយសម័យអាណានិគមតាមរយៈការស្រាវជ្រាវដែលមានលក្ខណៈវិទ្យាសាស្ត្រ ។

ឃាត ស្រ៊ាង
អនុប្រធានគម្រោងស្រាវជ្រាវអំពី
ប្រវត្តិពុទ្ធសាសនបណ្ឌិត្យ
ខែឧសភា ឆ្នាំ២០០៥



# ប្រវត្តិសាស្ត្រ



## ព្រះរាជបណ្ណាល័យ ១៩២១-១៩២៩

"ព្រះរាជបណ្ណាល័យ" ជាស្ថាប័នមួយដែលត្រូវបានបង្កើតឡើងដើម្បីប្រមូលនូវឯកសារផ្សេងៗជាច្រើន ដែលទាក់ទងជាសំខាន់នឹងផ្នែកទំនៀមទម្លាប់ ប្រពៃណីខ្មែរ និងវិស័យព្រះពុទ្ធសាសនាព្រោះជាជំនឿដ៏សំខាន់របស់ប្រជាជនខ្មែរទូទាំងប្រទេស និងជាតម្រូវការសិក្សារបស់ខេមរជន ទាំងព្រះសង្ឃ ទាំងគ្រហស្ថ ជាបញ្ញវន្តខ្មែរ និងអ្នកសិក្សា ដែលមកពីគ្រប់មជ្ឈដ្ឋានដើម្បីធ្វើការស្រាវជ្រាវ ។




នៅពេលដែលស្ថាប័នណាមួយទទួលបានជោគជ័យនោះ តែងមានមនុស្សជាច្រើនអះអាងថា វាជាស្នាដៃរបស់ខ្លួន។ ករណីព្រះរាជបណ្ណាល័យក៏ដូចគ្នានេះដែរ។ ដោយប្រឈមមុខនឹងកង្វះខាតឯកសារប្រវត្តិសាស្ត្រ ការចម្រាញ់យកនូវការពិតពីការនិយាយតៗគ្នានោះពុំមែនជាកាតព្វកិច្ចងាយស្រួលឡើយ ។ យើងជឿជាក់ថា ព្រះរាជបណ្ណាល័យនេះ លេចជារូបរាងឡើងពីការបណ្តុំនៃចេតនាជាច្រើន ជាឧទាហរណ៍ ពីសំណាក់ព្រះមហាក្សត្រ ស៊ីសុវត្ថិ ដែលមានព្រះទ័យធ្វើកំណែទំរង់ និងពីក្រុមម្ខាងទៀតដែលចង់ឱ្យមានការកែទំរង់ផ្នែកបញ្ញាញាណ នៅក្នុងគណៈមហានិកាយ ដែលដឹកនាំដោយព្រះមហាវិមលធម្មថោង ព្រះតេជគុណ ល្វី ឯម អ៊ុម ស៊ូរ ជួន ណាត និងហួត តាត។ ដោយមានការប្រុងប្រយ័ត្តនឹងបណ្តាអ្នកប្រឆាំងដែលមានចិត្តស្រលាញ់ប្រពៃណី និងស្អប់ខ្ពើមការបោះពុម្ព តាមរយៈការចេញផ្សាយនូវរាជប្រកាសផ្សេងៗ ដែលជាការធ្វើឱ្យទាបថោកដល់ប្រពៃណី ព្រះករុណា ស៊ីសុវត្ថិ នៅចុងទសវត្សរ៍១៩១០ បានបង្ហាញនូវព្រះបសាទចិត្តរបស់ទ្រង់ចំពោះសេចក្តីប្រាថ្នារបស់អ្នកកែទំរង់ ដែលចង់ឱ្យមានការពង្រីកនូវការបោះពុម្ពសៀវភៅខាងព្រះពុទ្ធសាសនាឱ្យបានកាន់តែច្រើន។ ក្នុងខណៈពេលដែល

បារាំងមានការចាប់អារម្មណ៍ចំពោះការបង្កើតមជ្ឈមណ្ឌលសំរាប់ការសិក្សានៅក្នុងប្រទេសខ្មែរ ដើម្បីប្រកួតប្រជែងជាមួយសៀមនោះ ព្រះករុណាស៊ីសុវត្ថិបានស្តែងឱ្យឃើញនូវចេតនាជាអ្នកគាំទ្រ ដល់វិស័យអប់រំ។ ដោយឃើញថានៅពេលមួយនោះសៀមបានប្រើប្រាស់នូវរបៀបគ្រប់គ្រង សិល្បៈ និងការរៀបចំ ស្ថាប័ននាសម័យអង្គរជាគំរូសំរាប់ការអភិវឌ្ឍនយោបាយ និងវប្បធម៌របស់គេ ព្រះមហាក្សត្រស៊ីសុវត្ថិក៏បានយកតម្រាប់តាមការគ្រប់គ្រងស្ថាប័នសម័យទំនើបរបស់សៀមមកប្រើសំរាប់ពង្រឹងប្រទេសកម្ពុជា។ ក្នុងនាមជាអ្នកស្រាវជ្រាវ អ្វីដែលយើងពិពណ៌នាខាងក្រោមនេះ គឺជារឿងរ៉ាវដែលយោងទៅតាមឯកសារសម័យអាណានិគម ហើយនៅកន្លែងខ្លះក៏មានលាយបញ្ចូលគ្នានឹងពត៌មានដែលបានពីរាជកិច្ចរាជការខ្មែរ និងសារពត៌មានដទៃទៀតផងដែរ។

កាលពីដើមឡើយ ព្រះរាជបណ្ណាល័យនេះបានបង្កើតឡើងដោយរាជប្រកាសចុះនៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ១៩២១ ដែលជាគំនិតផ្តួចផ្តើមរបស់រ៉េស៊ីដង់ជាន់ខ្ពស់បើយោងលើឯកសារសម័យអាណានិគម ហើយមានឈ្មោះថាជា "ខេមរបណ្ណាល័យ" មានទីតាំងនៅភ្នំពេញ។ តាមរាជប្រកាសលេខ២ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩២៥ បណ្ណាល័យនេះត្រូវបានរៀបចំឡើងវិញ ដោយប្រែឈ្មោះជាថ្មីថា "ព្រះរាជបណ្ណាល័យ"។



ព្រះរាជបណ្ណាល័យឆ្នាំ១៩២៨

ព្រះរាជបណ្ណាល័យកម្ពុជាត្រូវស្ថិតក្រោមអាណាព្យាបាលភាពរបស់ព្រះរាជា និងលោករ៉េស៊ីដង់ជាន់ខ្ពស់ប្រចាំកម្ពុជា។ បណ្ណាល័យនេះត្រូវគ្រប់គ្រងដោយជនជាតិអ៊ឺរ៉ុបម្នាក់ ដែលជាសមាជិករបស់សាលាបារាំងចុងបូព៌ា ដែលដំបូងឡើយមានកញ្ញា ស៊ុយសាន ការប៉ឺឡែស ជាតំណាង និងត្រូវមានក្រុមជំនុំត្រួតត្រាអមជាជនជាតិខ្មែររួមមានសេនាបតី (រដ្ឋមន្ត្រី) ក្រសួងមហាផ្ទៃ និងធម្មការជាអធិបតី សេនាបតីក្រសួងវាំង សេនាបតីក្រសួងសិក្សាធិការ រាជាគណៈឋានានុក្រម២អង្គ ១អង្គខាងធម្មយុត្តិ ១អង្គខាងគណៈមហានិកាយដែលសេនាបតីក្រសួងធម្មការចាត់ដោយមានសេចក្តីសុំពីក្រុមជំនុំសង្ឃ អ្នកចេះដឹងអក្សរខ្មែរពីរនាក់ ដែលសេនាបតីក្រសួង

សិក្សាធិការចាត់មក ជាងរចនាឬជាងខេមរៈនានាពីរនាក់ ១នាក់ត្រូវចាត់ដោយសេនាបតីក្រសួងរចនា ១នាក់ទៀតត្រូវចាត់ដោយអធិបតីរចនាខេមរៈ។

ប្រសិនបើយើងប្រៀបធៀបលើមុខវិជ្ជាមួយចំនួន ដែលគេបានបង្រៀននៅក្នុងសាលាបរិយត្តិជាន់ខ្ពស់ក្នុងក្រុងកម្ពុជា និងឯកសារដែលបណ្ណាល័យបានប្រមូលនោះគឺឃើញមានភាពស្រដៀងគ្នាយ៉ាងខ្លាំង។ ជាឧទាហរណ៍ គោលបំណងនៃការបង្កើតសាលាបរិយត្តិជាន់ខ្ពស់ខាងព្រះបរមពុទ្ធវចនៈគឺដើម្បីបង្រៀនឱ្យបានត្រឹមត្រូវតាមភាសាបាលីនិងសំស្ក្រឹត សាវតារខាងនយោបាយ ខាងសាសនា ការរចនាពីបុរាណនិងខាងសាសនាក្នុងស្រុកទាំងពួងផងដែរ។ ការណ៍នេះបានធ្វើឱ្យយើងអាចសន្និដ្ឋានជាដំបូងបានថា ព្រះរាជបណ្ណាល័យ ត្រូវបានបង្កើតឡើងដើម្បីជួយដល់ការសិក្សារបស់ព្រះសង្ឃខាងសាលាបរិយត្តិជាន់ខ្ពស់។ ប៉ុន្តែប្រសិនបើយើងមើលមួយជ្រុងទៀតនោះ យើងនឹងឃើញថា ក្រៅពីការជួយការសិក្សារបស់ព្រះសង្ឃ ព្រះរាជបណ្ណាល័យនៅមានភារៈជាអ្នកប្រមូល រក្សា និងបោះពុម្ពឯកសារទាក់ទងនឹងបញ្ហាប្រពៃណីទំនៀមទម្លាប់ និងលិខិត ដែលមានប្រយោជន៍ដល់នគរកម្ពុជា ដូចមានចែងក្នុងរាជប្រកាសដដែលនេះស្រាប់ថា "សំរាប់រក ប្រមូល រក្សា និងបោះពុម្ពចេញឱ្យអ្នកទាំងពួងមើលអស់ទាំងសៀវភៅ សាស្ត្រា លិខិតបោះពុម្ព ឬសរសេរដែជាភាសាគ្រប់មុខ តែត្រូវយកភាសាខ្មែរ បាលី សំស្ក្រឹតជាដើម មានន័យថា អស់ទាំងសៀវភៅ សាស្ត្រាឬលិខិតដែលមានប្រយោជន៍ដល់នគរក្រុងកម្ពុជាធិបតី ជាន់បុរាណក្តី ឬជាន់ឥឡូវក្តី និងសាវតារខាងនយោបាយ ខាងរចនា ខាងសាសនាក្នុងស្រុកទាំងប៉ុន្មាន ដែលកាន់ព្រះពុទ្ធសាសនាប៉ែកខាងត្បូង។"

ទោះបីជាមានមនុស្សមួយចំនួនយល់ថា តួនាទីរបស់ ព្រះរាជបណ្ណាល័យ មានប្រយោជន៍សំរាប់ការសិក្សាអំពីខ្មែរនៅពេលក្រោយមកទៀតក៏ដោយ ក៏នៅតែមានមតិប្រឆាំងថា ការប្រមូលនេះគឺដើម្បីបំរើផលប្រយោជន៍របស់បារាំងផងដែរ។



ព្រះរាជបណ្ណាល័យ

ដើម្បីធ្វើឱ្យមានភាពងាយស្រួលនោះ ព្រះរាជបណ្ណាល័យបានបែងចែកជាពីរផ្នែកធំៗ គឺប៉ែកសៀវភៅក្បួនខ្នាត និងបោះពុម្ពឱ្យអ្នកទាំងពួងមើល និងប៉ែករចនា។

ប៉ែកសៀវភៅក្បួនខ្នាត និងបោះពុម្ពចេញឱ្យអ្នកទាំងពួងមើលនោះ បែងចែកជាពីរផ្នែកទៀត។ផ្នែកទីមួយ ជាតួព្រះរាជបណ្ណាល័យមានទីសមុហបញ្ជី ទទួលបន្ទុកក្នុងការធ្វើបញ្ជីឯកសារពីព្រះបរមរាជវាំង ពីក្រសួងសេនាបតីគ្រប់ក្រុម ពីខេត្តក្រៅ ពីវត្ត (សាស្ត្រា ឬសៀវភៅ និងរបស់ផ្សេងៗ ដែលមានប្រយោជន៍ខាងសាសនា) និងរបស់ ដែលមានប្រយោជន៍ខាងសាវតារ។ ក្រៅពីនេះ ក៏មានតម្កល់ឯកសារនិយាយពីការប្រាស្រ័យទៅវិញទៅមក និងប្រទេសក្រៅ សៀវភៅបោះពុម្ពចេញ មានកំណត់កាសែត។ លើសពីនេះផ្នែកនេះត្រូវប្រមូលសាស្ត្រា ឬសៀវភៅសរសេរដៃ ជាភាសាបាលី ជាភាសាខ្មែរ បារាំង និងភាសាស្រុកទាំងប៉ុន្មានដែលកាន់ពុទ្ធសាសនាប៉ែកខាងត្បូង សៀវភៅបោះពុម្ពជាភាសាបាលី ខ្មែរ និងភាសាអ្នកស្រុកកាន់ពុទ្ធសាសនាខាងត្បូង ផែនទីត្រៃភូមិ គំនូរ និងរូប ដែលទាក់ទងនឹងនគរកម្ពុជា និងសាសនា។ ផ្នែកទីពីរការិយាល័យបោះពុម្ព ទទួលបន្ទុកបោះពុម្ពទាំងសៀវភៅសាសនា (បាលី និងបាលីខ្មែរ) និងសៀវភៅក្រៅសាសនា (ភាសាខ្មែរ) បញ្ហារឿងព្រេង សៀវភៅអធិប្បាយពីវិជ្ជាការផ្សេងៗ រឿងសាវតារ សៀវភៅខាងសិក្សាធិការ ស័ព្ទវចនៈ (ភាសាបាលី-សំស្ក្រឹត-ខ្មែរ ខ្មែរ-បារាំង បារាំង-ខ្មែរ) គំនូរ (អំពីរឿងព្រះពុទ្ធសាសនា និងរឿងផ្សេងៗឯទៀតដែលសំខាន់)។ ម្យ៉ាងទៀត ក្រុមនេះក៏បានបង្កើតការិយាល័យចម្លងលើស្លឹករឹត និងលើក្រដាសផងដែរ។ ប៉ែកទីពីរគឺប៉ែករចនា ក្រុមនេះមានពីរកន្លែងទៀត។ កន្លែងទីមួយគឺតាំងសៀវភៅ សាស្ត្រា សៀវភៅសរសេរ ដែលជាអក្សរគ្រប់បែប សាស្ត្រា សៀវភៅសរសេរដែលមានគំនូរ ចំណែកកន្លែងទីពីរមានតាំងពុទ្ធបូជា ធ្លឹត ទូរមានថត គ្រែឈើ ព្រះពុទ្ធរូប។ ព្រះរាជបណ្ណាល័យកម្ពុជាក៏បានអនុញ្ញាតឱ្យមានការខ្ចី និងទិញសៀវភៅមួយចំនួន ដែលខ្លួនបានបោះពុម្ពផងដែរ ។



ព្រះសង្ឃគង់លើគ្រែទេសនាក្នុងសម័យអាណានិគម

បន្ទាប់ពីបានបង្កើតព្រះរាជបណ្ណាល័យ សម្ដេចក្រុមព្រះនរោត្តមភាណុវង្ស សេនាបតីក្រសួងមហាផ្ទៃ និងធម្មការបានធ្វើការផ្សាយដំណឹងទៅតាមខេត្តស្ដីពីការបង្កើតព្រះរាជបណ្ណាល័យ អំពីគោលបំណង និងសុំឱ្យផ្ញើមកនូវរាល់ឯកសារ ឬរបស់មានតំលៃមកចូលរួមក្នុងការធ្វើឱ្យព្រះរាជបណ្ណាល័យកាន់តែមានការរីកចំរើន ដើម្បីថ្ងៃក្រោយអាចបង្កើតជាសារមន្ទីរពុទ្ធសាសនាមួយបាន។ បន្ទាប់ពីការផ្សព្វផ្សាយនោះ នៅឆ្នាំ១៩២៥ដដែល គេឃើញខេត្តបាត់ដំបងបានផ្ដើមយកគម្ពីរសាស្ត្រា និងរបស់របរផ្សេងៗខាងពុទ្ធសាសនាមកតម្កល់ទុកនៅក្នុងព្រះរាជបណ្ណាល័យ ឱ្យកាន់តែសំបូរឡើងទៀត។ ហើយដើម្បីផ្ដល់ជារង្វាន់ និងការលើកទឹកចិត្តនោះ ព្រះករុណាបានធ្វើការសរសើរ និងព្រះរាជទានគ្រឿងឥស្សរិយយសថ្នាក់ មុនីសារាភរណ៍ ឱ្យអ្នកដែលបានយកវត្ថុទាំងនោះមក។ រហូតដល់ឆ្នាំ១៩២៧ ទើបខេត្តកំពង់ចាម ដោយយកតម្រាប់តាមខេត្តបាត់ដំបង បានយកគម្ពីរសាស្ត្រា និងរបស់ផ្សេងៗ មកជូនព្រះរាជបណ្ណាល័យ។ មកដល់ឆ្នាំ១៩២៩ យើងឃើញមានការកែប្រែការគ្រប់គ្រងខ្លះនៅក្នុងការគ្រប់គ្រងគ្រឹះស្ថាននេះ។ តួនាទីលោកសេនាបតីក្រសួងសិក្សាធិការ ក្រសួងមហាផ្ទៃ និងធម្មការ ត្រូវលើកឱ្យទៅជាអធិបតីរង ដែលស្ថិតនៅក្រោមអធិបតីភាពរបស់សេនាបតីទី១នៃកុងស៊ីយ៍សេនាបតី។ ចំណែកឯក្រុមជំនុំនោះគឺទុកតែរាជាគណៈ១អង្គក្នុងគណៈធម្មយុត្តិ ១អង្គក្នុងគណៈមហានិកាយដែលសេនាបតីក្រសួងមហាផ្ទៃ និងធម្មការ ចាត់តាមសេចក្ដីសុំក្រុមជំនុំសង្ឃ និងបណ្ឌិតជាតិខ្មែរបីរូប។ ដោយឡែកយើងឃើញបាត់ក្រសួងរចនាប៉ុន្តែ បានដាក់ជំនួសមកវិញនូវអ្នកតំណាងរាជការអាណាព្យាបាលនៅជិតរាជការខ្មែរក្នុងក្រុមជំនុំនេះវិញ។



ការធ្វើអំណោយដល់ព្រះរាជបណ្ណាល័យកម្ពុជាក្នុងឆ្នាំ១៩២៧

នៅឆ្នាំ១៩២៨ព្រះរាជាហ្លួងព្រះបាងនៃប្រទេសលាវស៊ីសាវ៉ាងវង្សបានមកធ្វើទស្សនកិច្ចនៅទីក្រុងភ្នំពេញ។ក្នុងដំណើរទស្សនកិច្ចនោះ ព្រះអង្គម្ចាស់ ពេជ្ររតន៍ បានចូលមកធ្វើទស្សនកិច្ច ព្រះរាជបណ្ណាល័យ។ ២ ឬ៣ថ្ងៃក្រោយមកទៀត ព្រះអង្គម្ចាស់ ពេជ្ររតន៍ ក៏បានយាងមកទស្សនាព្រះរាជបណ្ណាល័យជាថ្មីម្ដងទៀត ក្នុងគោល

បំណងដើម្បីសួរដល់អ្នកអភិរក្សព្រះរាជបណ្ណាល័យ ព្រោះព្រះអង្គមានបំណងបង្កើតព្រះរាជបណ្ណាល័យ ដូចគ្នានេះ នៅទីក្រុងហ្លួងព្រះបាង និងវៀងច័ន្ទ ។

នៅខែកញ្ញា ឆ្នាំ១៩២៨ អ្នកអភិរក្សព្រះរាជបណ្ណាល័យ បានជួបជាមួយព្រះអង្គម្ចាស់ ពេជ្ររតន៍ នៅហាណូយដើម្បីពិភាក្សាអំពីសេចក្ដីប៉ងប្រាថ្នារបស់ព្រះអង្គ ហើយបានយាងចូលទៅជួបអគ្គទេសាភិបាល និយាយពីគម្រោងនេះ។ បន្ទាប់មកលោក ហ្កាវោ ចាងហ្វាងកិច្ចការនយោបាយ បានមានប្រសាសន៍ទៅកាន់លោក អគ្គទេសាភិបាល ទាក់ទងតាមរយៈលិខិតមួយទៅ ការប៉ីឡែស អ្នកអភិរក្សព្រះរាជបណ្ណាល័យ ដើម្បីបញ្ជាក់បង្ហាញពីភាពចាំបាច់នៃការបង្កើតមជ្ឈមណ្ឌលពុទ្ធសាសនា ដូចនៅប្រទេសកម្ពុជា។ ការប៉ីឡែស បានទៅប្រទេសលាវមើលនឹងធ្វើការបង្កើតនូវមជ្ឈមណ្ឌលសិក្សាពុទ្ធសាសនាសំរាប់បញ្ចវ័ន្តនៅទីនោះ ។

ដើម្បីជាប្រយោជន៍ដល់រាជការ ព្រះសង្ឃ និងអ្នកទាំងពួងដែលនៅឆ្ងាយ ទើបព្រះរាជបណ្ណាល័យ បង្កើតឱ្យមានទស្សនាវដ្ដី "កម្ពុជសុរិយា" ដែលចេញផ្សាយ១ខែម្ដង ។ កម្ពុជសុរិយា ទស្សនាវដ្ដីផ្សាយជាខេមរភាសា មានកំណើតតាំងពីឆ្នាំ១៩២៦មកនោះ ក៏បានផ្ដល់ជាវេទិកាដ៏ធំមួយដល់អ្នកប្រាជ្ញខាងព្រះពុទ្ធសាសនា។ គោលបំណងមួយទៀត គឺដើម្បីជួយសំរួលដល់សាធារណជនដែលមានបំណងចង់ផ្សាយដំណឹង ការណ៍អ្វី ឬផ្សាយពីចំណេះ ស្នាដៃ អក្សរសាស្ត្រ ។ ព្រះអង្គម្ចាស់ភាណុវង្សបានចុះផ្សាយអត្ថបទមួយនៅថ្ងៃទី១១ ខែមេសា ឆ្នាំ១៩២៧ ក្នុងគោលបំណងទាក់ទាញ និងជំរុញឱ្យមានការអានទស្សនាវដ្ដីឱ្យបានច្រើន ។ ទស្សនាវដ្ដីនេះ មិនត្រឹមតែបោះផ្សាយអំពីរឿងរ៉ាវ ដែលទាក់ទងនឹងព្រះពុទ្ធសាសនាប៉ុណ្ណោះទេ វាថែមទាំងបានបោះផ្សាយ អត្ថបទមួយចំនួនទៀតដែលនិយាយ អំពីប្រពៃណី ទំនៀមទម្លាប់ ប្រវត្តិសាស្ត្រ និងរឿងព្រេងរបស់ខ្មែរ ព្រមទាំងប្រវត្តិសាស្ត្រ និងអក្សរសាស្ត្រ របស់ប្រទេសដទៃផងដែរ ។

និយាយម្យ៉ាងវិញទៀត ទស្សនាវដ្ដីកម្ពុជសុរិយានេះបង្កើតឡើង ក្នុងគោលបំណងជួយទ្រោលបំភ្លឺប្រជាជាតិខ្មែរឱ្យមានប្រាជ្ញាឈ្វេងយល់ភ្លឺស្វាង ទាំងខាងគតិលោក ទាំងខាងគតិធម៌ តាមគ្រោងការណ៍ចុះផ្សាយប្រចាំខែនូវអត្ថបទខាងពុទ្ធសាសនាដែលមាននៅក្នុងស្លឹករឹតស្រាប់ ទាំងគតិលោកទាំងគតិធម៌ ដែលមានប្រយោជន៍ដល់សាធារណជន បោះផ្សាយអត្ថបទអក្សរសាស្ត្រដែលនិពន្ធដោយសមាជិកក្រុម ក៏ដូចជារបស់អ្នកប្រាជ្ញមកពីគ្រប់ទិសទី និងចុះផ្សាយប្រវត្តិការណ៍ និងដំណឹងពិសេសៗ ឬផ្លូវការដែលទាក់ទងនឹងក្រុមនេះ ។

ទោះយ៉ាងណា ចាប់ពីឆ្នាំ១៩២៨មក ដោយហេតុតែមានការរីកចំរើនខាងសៀវភៅគតិធម៌ច្រើនហើយនោះ កម្ពុជសុរិយាក៏បែរទៅបោះផ្សាយអត្ថបទខាងគតិលោកច្រើនវិញ ព្រោះអត្ថបទខាងគតិលោកនេះមិនសូវមានការបោះផ្សាយ និងដែលជាតម្រូវការរបស់អ្នកអានច្រើនផង ។

ទំនាក់ទំនងជាលើកដំបូងនៃក្រុមការងារ ព្រះរាជបណ្ណាល័យកម្ពុជា ជាមួយប្រទេសលាវបានចាប់ផ្តើម បន្ទាប់ពីពិធីបុណ្យរាជាភិសេករបស់ព្រះករុណាព្រះបាទ ស៊ីសុវត្ថិមុនីវង្ស នៅខែកក្កដា ឆ្នាំ១៩២៨។ នៅទីព្រះរាជបណ្ណាល័យ មានចាត់តាំងតុនូវសៀវភៅ ដែលខ្លួនទើបបានបោះពុម្ពហើយ ។ នៅថ្ងៃចុងក្រោយនៃពិធីរាជាភិសេក ត្រូវនឹងថ្ងៃទី២៩ ខែកក្កដា ឆ្នាំ១៩២៨ ព្រះចៅប្រទេសលាវព្រះបាទ ស៊ីសាវ៉ាងវង្ស បានយាងទតរាជបណ្ណាល័យកម្ពុជា ដោយមានកញ្ញា ការប៉ុឡែស ជាអ្នកបដិសណ្ឋារកិច្ច ធ្វើការអធិប្បាយជូនព្រះបាទ ស៊ីសាវ៉ាងវង្ស និងថ្វាយជូននូវសៀវភៅ ដែលព្រះរាជបណ្ណាល័យបានផ្សព្វផ្សាយ ។



បណ្ណារក្សព្រះរាជបណ្ណាល័យថតរូបរួមគ្នាក្នុងឆ្នាំ១៩២៨

ក្រៅពីព្រះរាជបណ្ណាល័យ ស្ថាប័នមួយទៀតដែលរួមចំណែកក្នុងការរៀបចំព្រះពុទ្ធសាសនា គឺ "សាលាបាលីជាន់ខ្ពស់"។ គោលបំណងនៃការបង្កើតសាលាបាលីជាន់ខ្ពស់នៅកម្ពុជា គឺដើម្បីលុបបំបាត់ឱ្យអស់នូវការធ្វើដំណើររបស់ព្រះភិក្ខុសាមណេរខ្មែរទៅប្រទេសសៀម ក្នុងបំណងទៅសិក្សាព្រះត្រៃបិដក។ ក្នុងរាជ្យព្រះបាទសម្តេចហរិរក្សរាមាឥស្សរាធិបតី ព្រះអង្គឌួង ព្រោះតែសៀមមានកិរិតអប់រំខ្ពស់ជាងប្រទេសខ្លួន គ្រប់ខេមរជនតែងតែចង់ទៅបន្តការសិក្សានៅទីនោះ។ សម្តេចព្រះមហាសង្ឃនាយក ទៀង អតីតសម្តេចព្រះសង្ឃរាជគណៈមហានិកាយ និងសម្តេចព្រះសុគន្ធាធិបតី ប៉ាន អតីតសម្តេចព្រះសង្ឃរាជទី១ខាងគណៈធម្មយុត្តិកនិកាយ ជាព្រះថេរពីរអង្គ ដែលទៅធ្វើការសិក្សាទ្រឹស្តីពុទ្ធសាសនានៅប្រទេសសៀម។ ក្រោយពីទទួលបាននូវចំណេះដឹងរឹងមាំហើយ ព្រះអង្គបានត្រឡប់មកធ្វើការបង្រៀនបន្តនៅក្នុងប្រទេសកំណើតរបស់ខ្លួន។ ដោយយកគំរូតាមសម្តេចព្រះសង្ឃរាជទាំងពីរព្រះអង្គនេះ ព្រះសង្ឃទាំងឡាយណា ដែលចង់បន្តការសិក្សារបស់ខ្លួនឱ្យបានខ្ពស់តែងតែនិមន្តទៅប្រទេសសៀម។ ហេតុដូច្នេះ ដើម្បីបញ្ឈប់នូវសកម្មភាពនេះ សាលាបាលីជាន់ខ្ពស់ មួយត្រូវបានបង្កើតឡើងនៅទីក្រុងភ្នំពេញ។

សាលានេះត្រូវបានស្ថាបនា និងកែប្រែទៅតាមរាជប្រកាសលេខ៨៥ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩១៤ លេខ២១ ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ១៩២៣ និងលេខ៦២ ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ១៩២៨។ ស្ថាប័ននេះធ្វើការបង្រៀនភាសាបាលី ដែលជាភាសាសំខាន់សំរាប់តែងធម៌វិន័យព្រះពុទ្ធសាសនា បង្រៀនបកប្រែភាសាសំស្ក្រឹត ឡាតាំង និងសៀមមកជាភាសាខ្មែរ ហើយកម្មវិធីទាំងនេះធ្វើឡើងក្នុងគោលបំណងឱ្យសមណសិស្សយល់កាន់តែច្បាស់អំពីព្រះធម៌វិន័យដែលព្រះសង្ឃ និងគ្រហស្ថអាចយកទៅអនុវត្តន៍បាន។ លើសពីនេះទៀត ដោយមើលឃើញពីការចំណាយច្រើនលើការធ្វើដំណើរ សារាចរលេខ៤ ចុះថ្ងៃទី៣០ ខែមិនា ឆ្នាំ១៩១៦ បានហាមឃាត់មិនឱ្យព្រះភិក្ខុ សាមណេរ និងគ្រហស្ថទៅធ្វើការសិក្សាព្រះត្រៃបិដកនៅក្រៅប្រទេសទៀតឡើយ និងព្រមទាំងជំរុញឱ្យមកសិក្សានៅសាលាបាលីជាន់ខ្ពស់ជំនួសវិញ។

តាំងពីសាលានេះកើតមក មានព្រះសង្ឃជាច្រើនបានបញ្ចប់ការសិក្សា។ ជារៀងរាល់ឆ្នាំ ព្រះសង្ឃជាច្រើនបានចេញពីសាលាដោយទទួលបាននូវសញ្ញាប័ត្រ ដែលបានផ្តល់នូវគុណភាពប្រសើរជាងពេលមុនៗ។ ជាមួយនេះ ព្រះសង្ឃក្នុងវត្តអារាមភាគច្រើន មានព្រះទ័យបីតិសោមនស្សនឹងការងាររបស់សាលាបាលីនេះ ហើយចំណែក ចៅអធិការវត្តធំៗក៏បានសុំឱ្យមានការបង្កើតសាលាបាលីរងក្នុងវត្តរបស់ខ្លួន និងសុំឱ្យតែងតាំងព្រះសង្ឃដែលរៀនចប់ពីសាលានេះទៅជួយបង្រៀងបន្ត។ ទង្វើបែបនេះ បានធ្វើឱ្យការផ្សព្វផ្សាយនូវទ្រឹស្តីព្រះពុទ្ធសាសនាតាមគម្ពីរ នេះមានសន្ទុះទៅមុខយ៉ាងលឿន។



ព្រះឆាយាល័ក្ខណ៍សម្តេចព្រះមហាសង្ឃរាជ និងសម្តេចព្រះសង្ឃនាយកគណៈ មហានិកាយឆ្នាំ១៩៥១

និយាយម្យ៉ាងទៀត សាលាបាលីជាន់ខ្ពស់នេះជាកន្លែងប្រមូលផ្តុំអ្នកប្រាជ្ញខ្មែរខាងសាសនាជាតិ ដើម្បីធ្វើការនិពន្ធចងក្រងសៀវភៅ និងអត្ថបទជាភាសាបាលី និងខ្មែរ ពិសេសព្រះត្រៃបិដកដើម្បីយកទៅចែកផ្សាយ និងជាវជូនបណ្ណាវត្តជាងពាក់កណ្តាលដែលចុះឈ្មោះចង់បានសៀវភៅនេះ។ ក្រៅពីនេះ ស្ថាប័នអប់រំនេះបានផ្ទេរនូវចំណេះដឹងដល់យុវជនជំនាន់ក្រោយ តាមរយៈកម្មវិធីបណ្តុះបណ្តាលរបស់សាលាយ៉ាងទូលំទូលាយទៀតផង។

នៅខែមករា ឆ្នាំ១៩២៨ មានដំណើរបេសកកម្មជាលើកដំបូងរបស់ក្រុមការងាររបស់ព្រះរាជបណ្ណាល័យ រួមមាន ការប៉ុឡែស ព្រះតេជគុណ ហួត តាត និង ថី ជី ដែលជាអ្នកបំរើការនៅមន្ទីរព្រះរាជបណ្ណាល័យផងដែរ។ ដំណើរទស្សនកិច្ចនៅស្រុកកូសាំងស៊ីន (វៀតណាមខាងត្បូងសព្វថ្ងៃ) របស់កញ្ញា ការប៉ុឡែស រយៈពេល១ខែក្នុងគោលបំណងសំខាន់គឺដើម្បីសាកល្បងពិនិត្យមើលសកម្មភាពរបស់ប្រជាពលរដ្ឋខ្មែរ និងការប្រតិបត្តិព្រះពុទ្ធសាសនានៅកូសាំងស៊ីន។ ផ្តើមចេញពីគំនិតរបស់កញ្ញា ការប៉ុឡែស ក្នុងការស្វះស្វែងបង្កើតឱ្យមានសាលារៀនដោយផ្អែកលើវត្តអារាម ដែលមានទីតាំងនៅទីនោះស្រាប់។ ដំណើរទស្សនកិច្ចរយៈពេល១ខែបានទទួលការគាំទ្រពីលោកអគ្គទេសាភិបាល គ្រូចឹមែរ។ តាមការសិក្សាឃើញថា ស្រុកដែលមានចៅហ្វាយស្រុកជាជនជាតិខ្មែរ ស្រុកនោះមានការរីកចំរើនខាងសិក្សាព្រះពុទ្ធសាសនាបានច្រើន ចំណែកស្រុកដែលមានចៅហ្វាយស្រុកជាជនជាតិយួននោះពុំសូវមានការចំរើននោះទេ។ លទ្ធផលដែលទទួលបានពីទស្សនកិច្ចនេះគឺព្រះសង្ឃ២៩អង្គត្រូវបានរាជការកូសាំងស៊ីនបញ្ជូនមករៀន និងស្នាក់នៅទីវត្តឧណ្ណាលោម។

សាលានេះត្រូវបានស្ថាបនា និងកែប្រែទៅតាមរាជប្រកាសលេខ៨៥ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩១៤ លេខ២១ ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ១៩២៣ និងលេខ៦២ ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ១៩២៨។ ស្ថាប័ននេះធ្វើការបង្រៀនភាសាបាលី ដែលជាភាសាសំខាន់សំរាប់តែងធម៌វិន័យព្រះពុទ្ធសាសនា បង្រៀនបកប្រែភាសាសំស្ក្រឹត ឡាតាំង និងសៀមមកជាភាសាខ្មែរ ហើយកម្មវិធីទាំងនេះធ្វើឡើងក្នុងគោលបំណងឱ្យសមណសិស្សយល់កាន់តែច្បាស់អំពីព្រះធម៌វិន័យដែលព្រះសង្ឃ និងគ្រហស្ថអាចយកទៅអនុវត្តន៍បាន។ លើសពីនេះទៀតដោយមើលឃើញពីការចំណាយច្រើនលើការធ្វើដំណើរ សារាចរលេខ៤ ចុះថ្ងៃទី៣០ ខែមិនា ឆ្នាំ១៩១៦ បានហាមឃាត់មិនឱ្យព្រះភិក្ខុ សាមណេរ និងគ្រហស្ថទៅធ្វើការសិក្សាព្រះត្រៃបិដកនៅក្រៅប្រទេសទៀតឡើយ និងព្រមទាំងជំរុញឱ្យមកសិក្សានៅសាលាបាលីជាន់ខ្ពស់ជំនួសវិញ។

តាំងពីសាលានេះកើតមក មានព្រះសង្ឃជាច្រើនបានបញ្ចប់ការសិក្សា។ ជារៀងរាល់ឆ្នាំ ព្រះសង្ឃជាច្រើនបានចេញពីសាលាដោយទទួលបាននូវសញ្ញាប័ត្រ ដែលបានផ្តល់នូវគុណភាពប្រសើរជាងពេលមុនៗ។ ជាមួយនេះ ព្រះសង្ឃក្នុងវត្តអារាមភាគច្រើន មានព្រះទ័យបីតិសោមនស្សនឹងការងាររបស់សាលាបាលីនេះ ហើយចំណែក ចៅអធិការវត្តធំៗក៏បានសុំឱ្យមានការបង្កើតសាលាបាលីរងក្នុងវត្តរបស់ខ្លួន និងសុំឱ្យតែងតាំងព្រះសង្ឃដែលរៀនចប់ពីសាលានេះទៅជួយបង្រៀនបន្ត។ ទង្វើបែបនេះ បានធ្វើឱ្យការផ្សព្វផ្សាយនូវទ្រឹស្តីព្រះពុទ្ធសាសនាតាមគម្ពីរ នេះមានសន្ទុះទៅមុខយ៉ាងលឿន។



ព្រះឆាយាល័ក្ខណ៍សម្តេចព្រះមហាសង្ឃរាជ និងសម្តេចព្រះសង្ឃនាយកគណៈមហានិកាយឆ្នាំ១៩៥១

និយាយម្យ៉ាងទៀត សាលាបាលីជាន់ខ្ពស់នេះជាកន្លែងប្រមូលផ្តុំអ្នកប្រាជ្ញខ្មែរខាងសាសនាជាតិ ដើម្បីធ្វើការនិពន្ធចងក្រងសៀវភៅ និងអត្ថបទជាភាសាបាលី និងខ្មែរ ពិសេសព្រះត្រៃបិដកដើម្បីយកទៅចែកផ្សាយ និងជាវជូនបណ្ណាវត្តជាងពាក់កណ្តាលដែលចុះឈ្មោះចង់បានសៀវភៅនេះ។ ក្រៅពីនេះ ស្ថាប័នអប់រំនេះបានផ្ទេរនូវចំណេះដឹងដល់យុវជនជំនាន់ក្រោយ តាមរយៈកម្មវិធីបណ្តុះបណ្តាលរបស់សាលាយ៉ាងទូលំទូលាយទៀតផង។

នៅខែមករា ឆ្នាំ១៩២៨ មានដំណើរបេសកកម្មជាលើកដំបូងរបស់ក្រុមការងាររបស់ព្រះរាជបណ្ណាល័យ រួមមាន ការប៉ុឡែស ព្រះតេជគុណ ហួត តាត និង ចី ជី ដែលជាអ្នកបំរើការនៅមន្ទីរព្រះរាជបណ្ណាល័យផងដែរ។ ដំណើរទស្សនកិច្ចនៅស្រុកកូសាំងស៊ីន (វៀតណាមខាងត្បូងសព្វថ្ងៃ) របស់កញ្ញា ការប៉ុឡែស រយៈពេល១ខែក្នុងគោលបំណងសំខាន់គឺដើម្បីសាកល្បងពិនិត្យមើលសកម្មភាពរបស់ប្រជាពលរដ្ឋខ្មែរ និងការប្រតិបត្តិព្រះពុទ្ធសាសនានៅកូសាំងស៊ីន។ ផ្តើមចេញពីគំនិតរបស់កញ្ញា ការប៉ុឡែស ក្នុងការស្វះស្វែងបង្កើតឱ្យមានសាលារៀនដោយផ្អែកលើវត្តអារាម ដែលមានទីតាំងនៅទីនោះស្រាប់។ ដំណើរទស្សនកិច្ចរយៈពេល១ខែបានទទួលការគាំទ្រពីលោកអគ្គទេសាភិបាល ក្រូចឺមែរ។ តាមការសិក្សាឃើញថា ស្រុកដែលមានចៅហ្វាយស្រុកជាជនជាតិខ្មែរ ស្រុកនោះមានការរីកចំរើនខាងសិក្សាព្រះពុទ្ធសាសនាបានច្រើន ចំណែកស្រុកដែលមានចៅហ្វាយស្រុកជាជនជាតិយួននោះពុំសូវមានការចំរើននោះទេ។ លទ្ធផលដែលទទួលបានពីទស្សនកិច្ចនេះគឺព្រះសង្ឃ២៩អង្គត្រូវបានរាជការកូសាំងស៊ីនបញ្ជូនមករៀន និងស្នាក់នៅទីវត្តឧណ្ណាលោម។

## ការកកើត ១៩២៩-៤២

លោកអគ្គទេសាភិបាល ឈ្មោះ ប៉ាស្គីយេរ បានធ្វើដំណើរទៅដែនកូសាំងស៊ីនក្នុងខេត្តត្រាវិញ (ព្រះត្រពាំង) និងខេត្តស្រុកត្រាំង (ខេត្តឃ្លាំង) បាសាក់ បន្ទាប់ពីមានសំណើរពីលោកទេសាភិបាលដែនកូសាំងស៊ីនក្រូចឆ្មារ។ អគ្គទេសាភិបាល ប៉ាស្គីយេរ បានផ្ញើលិខិតមួយច្បាប់ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ១៩២៩ ផ្ញើទៅលោករ៉េស៊ីដង់ជាន់ខ្ពស់ប្រចាំកម្ពុជា ដើម្បីទូលថ្វាយព្រះករុណាស៊ីសុវត្ថិមុនីវង្ស ក្នុងគោលបំណងស្នើរបញ្ជូនព្រះសង្ឃមួយអង្គ ដែលចេះភាសាបារាំងដើម្បីជួយសំរបសំរួល និងផ្សព្វផ្សាយឱ្យព្រះសង្ឃ និងឧបាសកឧបាសិកាយល់ពីសារៈសំខាន់នៃការបង្កើតមន្ទីរសំរាប់អ្នកប្រាជ្ញខាងព្រះពុទ្ធសាសនា។

ព្រះគ្រូសង្ឃវិជ្ជា ហួត តាត និងអភិរក្សព្រះរាជបណ្ណាល័យចេញដំណើរទៅកូសាំងស៊ីនតាមសេចក្តីស្នើរ។ ព្រះគ្រូសង្ឃវិជ្ជា ហួត តាត កញ្ញាការប៉ឺឡែស លោកអគ្គទេសាភិបាល ប៉ាស្គីយេរ និងទេសាភិបាលកូសាំងស៊ីនក្រូចឆ្មារ បានជួបជុំគ្នានៅទីលាននៃបរិវេណវត្តកំពង់ធំ ខេត្តត្រាវិញ (ព្រះត្រពាំង) នៅថ្ងៃ ទី១៧ ខែកក្កដា ឆ្នាំ១៩២៩។ តាងនាមឱ្យលោកអគ្គទេសាភិបាល ព្រះគ្រូសង្ឃវិជ្ជា ហួត តាត បានពន្យល់ពីគោលបំណងនៃការជួបជុំ គឺដើម្បីបង្កើតក្រសួងមួយឈ្មោះ "អាំងស្ទីទុយពុទ្ធិក" ដែលមានន័យថា "មន្ទីរសមាគមអ្នកប្រាជ្ញប៉ែកខាងព្រះពុទ្ធសាសនាក្នុងប្រទេសឥណ្ឌូចិនបារាំងសេស" ដែលជាមន្ទីរទីពីរបន្ទាប់ពីបានបង្កើត ព្រះរាជបណ្ណាល័យ និងសាលាបាលីជាន់ខ្ពស់ នៅក្រុងភ្នំពេញ។

គោលបំណងជាចំបងនៃការបង្កើតមន្ទីរនេះ គឺដើម្បីធ្វើឱ្យពុទ្ធសាសនិកថេរវាទមានការរួបរួមគ្នានៅក្នុង

ដែនឥណ្ឌូចិន-បារាំង និងកុំឱ្យមានវិប្បល្លាសផ្នែកភាសាខ្មែរ។ តាមប្រសាសន៍លោកទេសាភិបាល កូសាំងស៊ីន ក្រូឌីមែរ មន្ទីរអាំងស្ទីទុយពុទ្ធិក នេះបង្កើតឡើងក្នុងគោលបំណងដើម្បីជួយឱ្យមានការប្រតិបត្តិរបៀបរបស់អ្នកស្រុក។ ភារកិច្ចជាចំបងទៅអនាគតសំរាប់ មន្ទីរអាំងស្ទីទុយពុទ្ធិក រួមមានការបោះពុម្ពព្រះត្រៃបិដកឱ្យចប់ជាអក្សរជ្រៀងដើម្បីតម្កល់ទុកតាមវត្ត ប្រែព្រះត្រៃបិដកពីភាសាបាលីមកភាសាខ្មែរ ដើម្បីឱ្យអ្នកបួសសិក្សាធម៌ បោះពុម្ពសព្វវចនខ្មែរ ដើម្បីឱ្យបានស្គាល់នូវពាក្យសំដីច្បាស់លាស់ ត្រូវបង្កើតសាលារៀន ដើម្បីឱ្យព្រះសង្ឃបង្រៀនវិជ្ជាភាសាបាលី បង្កើតកន្លែងប្រជុំសំរាប់ទាហានក្រុមពិជ័យសង្គ្រាម និងក្រុមរក្សា ស្រុកដើម្បីកុំឱ្យទាហានមានចិត្តឯកោ និងសំរួលដល់ការធ្វើបុណ្យរបស់ពុទ្ធសាសនិកជន។

មន្ទីរអាំងស្ទីទុយពុទ្ធិកបានទទួលការគាំទ្រពីអគ្គទេសាភិបាលឥណ្ឌូចិន ព្រះករុណាស៊ីសុវត្ថិមុនីវង្ស ព្រះចៅក្រុងកម្ពុជា ព្រះករុណាស៊ីសាវ៉ាងវង្ស ព្រះចៅប្រទេសលាវ លោកទេសាភិបាលដែនកូសាំងស៊ីន និងលោករ៉េស៊ីដង់ជាន់ខ្ពស់ប្រចាំក្រុងកម្ពុជា លោករ៉េស៊ីដង់ជាន់ខ្ពស់ប្រចាំក្រុងលាវ និងមន្ត្រីទាំងឡាយនៃដែនឥណ្ឌូចិន និងអ្នកដែលមានជំនឿលើពុទ្ធសាសនា។

យោងតាមខ្លឹមសារនៃគោលបំណងខាងលើ ស្របនឹងដំណើរទស្សនកិច្ចរបស់កញ្ញាការ៉ីប៉ឡែស និងលោកទេសាភិបាលដែនកូសាំងស៊ីន ក្រូឌីមែរ ទៅបណ្ដាខេត្តក្នុងដែនកូសាំងស៊ីនដើម្បីស្វែងយល់គំនិតរបស់ពុទ្ធសាសនិកជាពិសេសព្រះចៅអធិការតាមវត្តនិមួយៗ អំពីការបង្កើតសាលារៀនតាមវត្តរបស់ខ្លួន និងការបញ្ជូនព្រះសង្ឃពីភ្នំពេញកាលពីឆ្នាំ១៩២៨ ដំណើរប្រព្រឹត្តិទៅនៃគំនិតផ្ដួចផ្ដើមរបស់កញ្ញា ការ៉ីប៉ឡែស បានជំរុញឱ្យលោកទេសាភិបាលកូសាំងស៊ីន ព្រមព្រៀងអនុញ្ញាតឱ្យមានការគិតគូរយ៉ាងទូលាយទៅលើទំនៀមទម្លាប់របស់ស្រុក និងអនុញ្ញាតឱ្យព្រះសង្ឃទៅសិក្សានៅសាលាបាលី បន្ថែមពីលើការព្រមព្រៀងអនុញ្ញាតឱ្យជាតិខ្មែររស់នៅកូសាំងស៊ីនជាវទស្សនាវដ្ដី កម្ពុជសុរិយា តាមទីកន្លែងដែលមានស្រាប់។ ដោយសំរេចបាននូវលទ្ធផលយ៉ាងនេះ ទើបមន្ទីរពុទ្ធសាសនបណ្ឌិត្យ ត្រូវបានបង្កើតនៅថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៣០។



ព្រះតេជគុណ លី ឯម និងក្រុមជំនុំព្រះត្រៃបិដកឆ្នាំ១៩៣៤

ការបង្កើតនេះ មួយផ្នែកក្នុងបំណងសំរេចជោគជ័យរបស់ក្រុម "ឧត្តមសង្គាយនា" ឬ "ក្រុមជំនុំព្រះត្រៃបិដក" ដែលបង្កើតឡើងដោយក្រឹត្យលេខ១០៦ ចុះថ្ងៃ១៤ ខែធ្នូ ឆ្នាំ១៩២៩។ ក្រុមឧត្តមសង្គាយនា មានអធិបតី១រូប និងក្រុមជំនុំច្រើនរូប ហើយក្រោយមកត្រូវបានកែប្រែដោយតាំងឱ្យមានអធិបតី១រូប អធិបតីរង២រូប និងក្រុមជំនុំ៤០រូប ដើម្បីប្រែភាសាបាលី។ ក្រុមឧត្តមសង្គាយនា បែងចែកជា៥ក្រុមដែលរួមមាន ក្រុមសរសេរចម្លង ក្រុមផ្ទៀងភាសាបាលី ក្រុមប្រែជាភាសាខ្មែរ ក្រុមពិនិត្យសេចក្ដីជាភាសាខ្មែរ និងក្រុមពិនិត្យសំរេច។

ស្នាដៃនៃការបកប្រែគម្ពីរព្រះត្រៃបិដកជាភាសាខ្មែរភាគទី១ បានប្រារព្ធពិធីសម្ពោធនៅថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៣១ នៅព្រះទីនាំងទេវាវិនិច្ឆ័យក្នុងព្រះបរមរាជវាំងចតុមុខក្រុងភ្នំពេញ។ ពិធីសម្ពោធចូលរួមដោយលោកអតីតអគ្គទេសាភិបាល ប៉ូលរេយណូទ៍ ព្រះករុណាព្រះបាទស៊ីសុវត្ថិមុនីវង្ស លោកអគ្គទេសាភិបាល ប៉ាស្គីយេរ និងលោករ៉េស៊ីដង់ជាន់ខ្ពស់ ឡាវិត រួមទាំងព្រះសង្ឃមកពីប្រទេសលាវ និងកូសាំងស៊ីន។



ព្រះករុណាព្រះបាទស៊ីសុវត្ថិមុនីវង្សទ្រង់ស្ដេចយាងជាមហាអធិបតីបុណ្យក្នុងព្រះរាជបណ្ណាល័យឆ្នាំ១៩៣៤

សុន្ទរកថារបស់ព្រះករុណា ស៊ីសុវត្ថិមុនីវង្ស បានបង្ហាញពីទឹកចិត្តគាំទ្រដល់ ក្រុមពុទ្ធសាសនបណ្ឌិត្យនិងការទំនុកបំរុងរបស់អាណាព្យាបាលបារាំងក្នុងកិច្ចការបកប្រែគម្ពីរព្រះត្រៃបិដក និងសាសនានៅប្រទេសឥណ្ឌូចិន។ ទន្ទឹមនឹងនេះ ព្រះហឫទ័យរបស់ទ្រង់ សម្ដែងឱ្យឃើញពីចេតនាការពារចំពោះគំនិតរិះគន់អំពីការធ្វើឱ្យបាត់បង់របៀបរៀបរយ និងទំនៀមរបស់អ្នកស្រុកដែលខុសពីសេចក្ដីប្រាថ្នារបស់ពួកគាត់។ ផ្ទុយទៅវិញកិច្ចការទាំងនេះបាន ជំរុញឱ្យ មានការយោគយល់គ្នាទៅវិញទៅមក។

ដើម្បីបំពេញនូវតួនាទីរបស់ពុទ្ធសាសនបណ្ឌិត្យ ក្នុងការជួយលើកកំពស់សីលធម៌សង្គម កញ្ញាការប៉ីឡែស និងព្រះគ្រូសង្ឃវិជ្ជា ហួត តាត បណ្ណារក្ស ជី បានធ្វើដំណើរទៅស្រុកឆ្លូងក្នុងខេត្តក្រចេះ នៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ១៩៣៣។ ការប៉ីឡែសបានជួបជុំជាមួយក្រុមពិជ័យសង្គ្រាមជាតិខ្មែរ ឯព្រះគ្រូសង្ឃវិជ្ជា ហួត តាត បានសម្តែងធម្មទេសនាដល់ក្រុមពិជ័យសង្គ្រាម ក្នុងគោលបំណងជំរុញឱ្យកងទ័ពទាំងនោះមានស្មារតីស្រលាញ់ព្រះពុទ្ធសាសនា និងមានស្មារតីភ្ញាក់រលឹកលះបង់សេចក្តីអាក្រក់។ ក្រៅពីនេះ ព្រះគ្រូ ហួត តាត ក៏បានសម្តែងព្រះធម្មទេសនាដល់ក្រុមអ្នកទោសផងដែរ។ នេះបង្ហាញឱ្យឃើញពីគោលបំណងនៃដំណើរទស្សនកិច្ចរបស់កញ្ញាការប៉ីឡែស និងព្រះគ្រូ ហួត តាត គឺដើម្បីពន្យល់ក្រុមមនុស្សគ្រប់ជំពូកដោយយកគោលនៃលទ្ធិព្រះពុទ្ធសាសនាមកអប់រំ។



សម្តេចព្រះសង្ឃរាជ ជួន ណាត និងសមាជិកពុទ្ធសាសនបណ្ឌិត្យ
ពេលទស្សនាវត្តក្នុងខេត្តក្រចេះឆ្នាំ១៩៣១

ការធ្វើធម្មទេសនាដល់ពួកយោធា ទាហាន ឈ្លបសញ្ជាតិខ្មែរ និងឡាវ ជាបេសកកម្មធំមួយរបស់ពុទ្ធសាសនបណ្ឌិត្យ ក្នុងការកសាងនូវការដុសខាត់ផ្នែកសីលធម៌ និងបញ្ញាស្មារតីរបស់អ្នកកាន់អាវុធទាំងនេះ។ ចាប់តាំងពីការចាប់បដិសន្ធិមក ពុទ្ធសាសនបណ្ឌិត្យ ជារៀងរាល់ខែបានចាត់ឱ្យព្រះសង្ឃធ្វើធម្មទេសនាពិសេសដល់ពួកទាហានខ្មែរ ដែលនៅតាមបន្ទាយដាច់ស្រយាលរហូតដល់តាមបណ្តាខេត្តខ្មែរនៅកូសាំងស៊ីន។ មានពេលខ្លះព្រះសង្ឃដែលជាគ្រូនៅ សាលាបាលីជាន់ខ្ពស់ ចេញទៅធ្វើធម្មទេសនាដោយផ្ទាល់តែម្តង។

ប៉ុន្តែទោះយ៉ាងណា សកម្មភាពនេះត្រូវបានបក្សពួកក្រុមខ្លះជឿថាបណ្តាលឱ្យមានវិវាទនៅក្នុងសាសនាខ្មែរ។ អធិករណ៍នេះបានធ្វើឱ្យការប្រតិបត្តិសាសនានេះមានការធ្លាក់ចុះយ៉ាងខ្លាំង និងមានវិបត្តិសាសនាយ៉ាងច្រើន។ វិប្បវាសផ្នែកសាសនានេះបណ្តាលមកពីការទិតៀនរិះគន់គ្នាទៅវិញទៅមករវាងក្រុមមួយដែលប្រកាន់

ពុទ្ធសាសនបណ្ឌិត្យ
បណ្ណាល័យ
LIBRARY
BUDDHIST INSTITUTE



ព្រះសង្ឃសម័យអាណានិគមឃ្លុំចីវរប្រហែលជាគណៈធម្មយុត្តិ

យកទ្រឹស្តីថ្មី ដែលបានមកពីការណែនាំ ជាពិសេសតាមរយៈការបោះពុម្ពព្រះត្រៃបិដក និងបក្សពួកមួយក្រុមទៀត ដែលប្រកាន់យកការប្រតិបត្តិតាមលក្ខណៈប្រពៃណីដែលអ្នកជំនាន់មុនបានបន្សល់ទុកឱ្យ។ នៅចុងទសវត្សរ៍ឆ្នាំ ១៩៣០ ការទទួលខុសត្រូវសំរាប់ហេតុភេទអាក្រក់នេះធ្លាក់ទៅលើពុទ្ធសាសនបណ្ឌិត្យ និងកញ្ញាការប៉ុីឡែស ដែលជាអគ្គលេខាធិការរបស់វិទ្យាស្ថាន។



ព្រះសង្ឃគង់ក្បែរបល្ល័ង្កព្រះក្នុងសម័យអាណានិគម

ព្រឹត្តិការណ៍មួយថ្មីដែលកើតឡើងបន្ទាប់ពី ក្រុមជំនុំព្រះត្រៃបិដក បានបោះពុម្ពគម្ពីរព្រះត្រៃបិដកជាភាសាខ្មែរដំបូង គឺព្រះសង្ឃ និងពុទ្ធបរិស័ទខ្លះមានការមិនសប្បាយចិត្ត បង្កើតឱ្យមានជាការតវ៉ាឡើង។ នៅខែធ្នូ ឆ្នាំ១៩៣៣ កញ្ញាការប៉ិឡែស និងព្រះគ្រូសាសនសោភ័ណ ជួន ណាត ជាចាងហ្វាងរងសាលាបាលីជាន់ខ្ពស់ បានធ្វើដំណើរទៅស្រុកទ្រាំងក្នុងដែនកូសាំងស៊ីន ដើម្បីត្រួតមើលដំណើរការនៃសាលារៀនដែលទើបបានបង្កើត។ ព្រះគ្រូសាសនសោភ័ណ ជួន ណាត លើកឡើងអំពីបញ្ហាចំរូងចំរាស់ក្នុងសំណាក់សាសនា ដោយហេតុថា មានព្រះសង្ឃមួយចំនួនបានធ្វើការទិតៀនព្រះសង្ឃដែលចាកសិក្ខាបទហើយមកធ្វើជាគ្រូបង្រៀននៅសាលាវត្ត។ អ្នករិះគន់ទាំងនេះយល់ថា ទង្វើបែបនេះជាការដកហូតនូវអំណាចពីព្រះសង្ឃដែលគង់នៅទីអារាម និងការព្យាយាមបំបែកសាលារៀនចេញពីព្រះសង្ឃ និងការផ្គត់ផ្គង់របស់ពុទ្ធបរិស័ទចំណុះជើងវត្ត។



ព្រះតេជគុណ ជួន ណាត ហួត តាត និងកញ្ញា ការប៉ិឡែស
ថតរូបនៅកូសាំងស៊ីនក្នុងឆ្នាំ១៩៣៩

គោលបំណងទី២ គឺដើម្បីពន្យល់នូវមន្ទិលសង្ស័យ នូវការបកប្រែគម្ពីរព្រះត្រៃបិដកជាភាសាខ្មែរ។ ព្រះគ្រូសាសនសោភ័ណ ជួន ណាត ពន្យល់ថា ការប្រែព្រះត្រៃបិដកមិនបាននាំឱ្យសាបរលាបដល់ព្រះពុទ្ធសាសនាឡើយ។ លោកយល់ថា មានមនុស្សតិចណាស់ដែលចេះភាសាបាលី អ្នកមានការសិក្សាជ្រៅជ្រះទើបអាចយល់ពីឱវាទរបស់ព្រះពុទ្ធបាន។ សេចក្តីពន្យល់នេះបានធ្វើឱ្យពុទ្ធបរិស័ទយល់ និងព្រមទទួលយកសាលាដែលអាណាព្យាបាលបារាំង និងកញ្ញា ការប៉ិឡែស ជាដើមបានគាំទ្រ។

ចំណែកប្រទេសលាវ ក្រោយពីមានបំណងចង់បង្កើតឱ្យមានមន្ទីរមួយ ដែលមានលំនាំដូចគ្នានឹងមន្ទីរនៅប្រទេសខ្មែរ បានបង្កើត "ពុទ្ធសាសនបណ្ឌិត្យលាវ" ជាផ្លូវការនៅឆ្នាំ១៩៣២។ ព្រះអង្គម្ចាស់ ពេជ្ររតន៍ និងកញ្ញា ការប៉ិឡែស ជាមនុស្សសំខាន់ក្នុងការភ្ជាប់ទំនាក់ទំនងរវាងប្រទេសលាវ និងប្រទេសកម្ពុជា តាមរយៈ

មន្ទីរពុទ្ធសាសនបណ្ឌិត្យ និងព្រះរាជបណ្ណាល័យខ្មែរ។ ព្រះអង្គម្ចាស់ ពេជ្ររតន៍ ដែលក្រោយមកមាននាទីជាអធិបតី "ពុទ្ធសាសនបណ្ឌិត្យលាវ" បានមកទស្សនកិច្ចម្ដងទៀតនៅកម្ពុជានៅថ្ងៃទី១៦ ខែមីនា ឆ្នាំ១៩៣៥ ក្នុងគោលបំណង ពិនិត្យមើលកិច្ចការដែលមន្ទីររបស់ខ្មែរបានធ្វើ។



ពិធីសម្ពោធពុទ្ធសាសនបណ្ឌិត្យនៅប្រទេសលាវ

ការជួបជុំគ្នានៃក្រុមការងាររបស់ មន្ទីរពុទ្ធសាសនបណ្ឌិត្យ បង្ហាញឱ្យឃើញពីជំហានដំបូងនៃការរំលែក និងពង្រឹងការសិក្សាផ្នែកសាសនា និងអក្សរសាស្ត្រ។ ទំនាក់ទំនងរវាងពុទ្ធសាសនបណ្ឌិត្យ និងសាលាបាលីនៃប្រទេសលាវ និងកម្ពុជានាគ្រានោះបានជំរុញឱ្យព្រះសង្ឃ ព្រះសីរីវង្ស ជាគណៈសង្ឃក្រុមប្រែព្រះត្រៃបិដក អនុញ្ញាតឱ្យ មានការសិក្សាភាសាលាវ( គឺអក្សរថាង )នៅសាលាបាលីជាន់ខ្ពស់។



ព្រះអង្គម្ចាស់ពេជ្ររតន៍ នៃប្រទេសលាវ

និងព្រះអង្គម្ចាស់រណេឫទ្ធិអធិបតីពុទ្ធសាសនបណ្ឌិត្យ ឆ្នាំ១៩៣៥

ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៣៣ ពិធីចែករង្វាន់ប្រគេនព្រះសង្ឃមកពីកូសាំងស៊ីនចំនួន២១អង្គ ដែលបានប្រឡងជាប់ ប្រារព្ធធ្វើឡើងជាលើកដំបូងនៅទីព្រះរាជបណ្ណាល័យ ។ មានការចូលរួមលើកទឹកចិត្តពីសម្តេចក្រុមព្រះវរចក្ររណឫទ្ធិ អធិបតីពុទ្ធសាសនបណ្ឌិត្យ លោកសេនាបតីក្រសួងសិក្សាធិការក្រុមហ្លួងស៊ីសុវត្ថិសុភាណុវង្ស រួមទាំងអគ្គលេខាធិការពុទ្ធសាសនបណ្ឌិត្យ កញ្ញា ការប៉ុឡែស និងចាងហ្វាងសាលាបាលីជាន់ខ្ពស់ ។

មន្ទីរព្រះរាជបណ្ណាល័យ និងមន្ទីរពុទ្ធសាសនបណ្ឌិត្យ បានក្លាយទៅជាមន្ទីរទស្សនកិច្ចជាផ្លូវរដ្ឋសំរាប់មន្ត្រីអាណាព្យាបាល និងភ្ញៀវនៃប្រទេសក្នុងដែនឥណ្ឌូចិន។ លោក ហ្វែរណង ឡាវិត ដែលជារ៉េស៊ីដង់ជាន់ខ្ពស់ប្រចាំកម្ពុជាក្នុងដំណើរទស្សនកិច្ចមុនត្រឡប់ទៅប្រទេសបារាំង បានបង្ហាញសេចក្តីប៉ងប្រាថ្នារបស់កញ្ញាការប៉ុឡែស ដើម្បីបង្កើត មន្ទីរពុទ្ធសាសនបណ្ឌិត្យ។ កញ្ញា ការប៉ុឡែស បានសុំឱ្យលោកឡាវិត ធ្វើការពិគ្រោះការណ៍នេះជាមួយរាជការអាណាព្យាបាលធំដែលគ្រប់គ្រងឥណ្ឌូចិន។ លោកអគ្គទេសាភិបាលឥណ្ឌូចិន រ៉ីណេរោបាំង បានមកទស្សនកិច្ចនៅទីលាន ព្រះរាជបណ្ណាល័យ និងមន្ទីរពុទ្ធសាសនបណ្ឌិត្យ កាលពីថ្ងៃទី២៧ ខែកក្កដា ឆ្នាំ១៩៣៤ ដោយពិនិត្យលើកិច្ចការក្រុមជំនុំព្រះត្រៃបិដក និងពិនិត្យមើលរថយន្តផ្ទុកសៀវភៅរបស់ពុទ្ធសាសនបណ្ឌិត្យ។ មុននេះមួយខែនៅឆ្នាំដដែល លោកអគ្គទេសាភិបាលស្តីទីឥណ្ឌូចិន ក្រាហ្វីយ ជាមួយលោករ៉េស៊ីដង់ជាន់ខ្ពស់ ស៊ីលវែស្រ្ត បានមកពិនិត្យមន្ទីរទាំងពីរ។



លោកអគ្គទេសាភិបាល រ៉ីណេរោបាំង រួមជាមួយមន្ត្រីបារាំង-ខ្មែរ
ទស្សនារថយន្តផ្ទុកសៀវភៅពុទ្ធសាសនបណ្ឌិត្យ នៅទីសួនព្រះរាជបណ្ណាល័យ ឆ្នាំ១៩៣៤

ដោយមានទំនាក់ទំនងល្អរវាងប្រទេសលាវ និងកម្ពុជា រាជការបារាំងបានអញ្ជើញព្រះអង្គម្ចាស់ សាវ៉ាង ដែលជាព្រះរាជឱរសរជ្ជទាយាទ ចូលរួមបុណ្យសម្ពោធព្រះពុទ្ធរូបសិលានៅទីក្រុងមហានគរ នៅថ្ងៃទី១៧ ខែឧសភា ឆ្នាំ១៩៣៥ ។ គោលបំណងទី២ របស់ព្រះអង្គម្ចាស់ គឺស្តេចអាចយាងទតព្រះរាជបណ្ណាល័យ និងមន្ទីរ

ពុទ្ធសាសនបណ្ឌិត្យ ជាពិសេសទៅលើកិច្ចការជំរះ និងប្រែព្រះត្រៃបិដកដែល ពុទ្ធសាសនបណ្ឌិត្យ បានធ្វើ និងទតការបោះពុម្ពផ្សាយ របស់ព្រះរាជបណ្ណាល័យ និងការសិក្សាវិជ្ជានៅសាលាបាលីជាន់ខ្ពស់ ។



ព្រះអង្គម្ចាស់សាវ៉ាងនៃប្រទេសលាវ ព្រះអង្គម្ចាស់មុនីរ៉េត ព្រះតេជគុណ លី្វ ឯម ជួន ណាត
និងក្រុមជំនុំបិដក ថតរូបនៅពុទ្ធសាសនបណ្ឌិត្យក្នុងឆ្នាំ១៩៣៥

ក្រោយការបង្កើត មន្ទីរពុទ្ធសាសនបណ្ឌិត្យ មន្ទីរនេះមានគោលនយោបាយមួយថ្មី គឺត្រូវធ្វើកិច្ចសហប្រតិបត្តិការជាមួយ ព្រះរាជបណ្ណាល័យ ដោយ ព្រះរាជបណ្ណាល័យ ដើរតួជាអ្នកបោះពុម្ពផ្សាយសៀវភៅខាងលោកីយ៍ បន្ថែមទៅលើការផ្តល់ទីកន្លែងសំរាប់ឱ្យខ្ចីសៀវភៅ កន្លែងតម្កល់ថាស ម៉ាស៊ីនថតប្រមាណ៣០០ មានកន្លែងសិក្សាភ្លេង ដែលមានច្រើនភាសាសំរាប់សិក្សារៀនសូត្រ និងមានពេលវេលាសំរាប់បញ្ចាំងកុនជាភាសាខ្មែរថែមទៀត។ ក្រៅពីមន្ទីរព្រះរាជបណ្ណាល័យ មន្ទីរពុទ្ធសាសនបណ្ឌិត្យ បានបង្កើតឱ្យមានការរៀបចំជាបណ្ណាល័យចល័តសំរាប់ការអប់រំដល់ថ្នាក់មូលដ្ឋាន។

រថយន្តផ្ទុកទៅដោយសៀវភៅដែលព្រះរាជបណ្ណាល័យបានបោះពុម្ព មានបំពាក់ទាំងម៉ាស៊ីនបញ្ចាំងកុន និងម៉ាស៊ីនច្រៀង សំរាប់ជាគ្រឿងទាក់ទាញដល់បណ្តារាស្ត្រទៀតផង។ ដំណើររបស់បណ្ណាល័យចល័តមានរយៈពេល៨ខែក្នុងមួយឆ្នាំ សំរាប់ធ្វើដំណើរទៅតាមបណ្តាខេត្តក្នុងស្រុកខ្មែរ និងកូសាំងស៊ីន ជារៀងរាល់ឆ្នាំ។ លើសពីនេះ វាក៏មានបំណងឱ្យប្រជាជន ដែលនៅទីដាច់ស្រយាលក្នុងដែនខេត្តក្រៅៗបានជ្រួតជ្រាបអំពីការងារក៏ដូចជាពតិមានផ្សេងៗ ដែលទាក់ទងនឹង សាសនាជាតិរបស់ខ្លួននោះ។ រាល់ការធ្វើដំណើរទៅតាមបណ្តាខេត្តនីមួយៗ ពុទ្ធសាសនបណ្ឌិត្យ តែងតែពាក់ព្រះសង្ឃធំណាមួយនៅក្នុងខេត្ត ដើម្បីទូលលោកជួយសំរួលរក

ទីវត្តអារាមដើម្បីជួបជុំ និងប្រមូលផ្តុំប្រជាជន ក៏ដូចជាព្រះសង្ឃមកស្តាប់ការឃោសនា អានសៀវភៅ ក៏ដូចជាជាវសៀវភៅ។ បណ្ណាល័យនេះបានធ្វើដំណើរទៅដល់កូសាំងស៊ីន និងនៅឆ្នាំ១៩៣៨ បានធ្វើដំណើរទៅដល់ហ្លួងព្រះបាង និងភាគខាងត្បូងនៃប្រទេសលាវទៀតផង។ ថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩៤៧ ដំណើររបស់បណ្ណាល័យចល័តត្រូវផ្អាក ដោយមកពីមូលហេតុថា រថយន្តមានសភាពចាស់ពេក ហើយជួសជុលពុំបាន បញ្ហាសង្គ្រាម និងអសន្តិសុខ។



កាលលោកអគ្គទេសាភិបាលស្តីទី ព្រាហ្វីយ អញ្ជើញមកទស្សនា
ការព្រះរាជបណ្ណាល័យ កំពុងមើលរថយន្តផ្ទុក សៀវភៅ ឆ្នាំ១៩៣៤

ក្នុងយុទ្ធនាការផ្សព្វផ្សាយព្រះពុទ្ធសាសនា ពុទ្ធសាសនបណ្ឌិត្យ រួមជាមួយ ព្រះរាជបណ្ណាល័យ បានបោះពុម្ពព្រឹត្តិបត្រដោយឡែកមួយទៀត ដែលនិយាយអំពីពុទ្ធសាសនាសុទ្ធ ដែលមានឈ្មោះថា "សាសនាកិច្ចានុក្រម"។ ព្រឹត្តិបត្រនេះ នៅឆ្នាំ១៩៤២ ត្រូវបានគេផ្អាកទាំងស្រុង ហើយពត៌មានដែលធ្លាប់បោះពុម្ពនៅទីនេះ ត្រូវលើកទៅបញ្ចូលក្នុងការផ្សាយរបស់កម្ពុជសុរិយាវិញ។

តាមរយៈការបោះពុម្ព និងការប្រែគម្ពីរព្រះត្រៃបិដក ព្រមជាមួយនឹងការចែកផ្សាយយ៉ាងទូលាយនោះ កេរ្តិ៍ឈ្មោះរបស់ ពុទ្ធសាសនបណ្ឌិត្យ បានរីកសាយភាយយ៉ាងខ្លាំង ទាំងក្នុងនិងក្រៅប្រទេស។ ស្ថាប័នមួយចំនួនដែលមានការចាប់អារម្មណ៍អំពីព្រះពុទ្ធសាសនានៅប្រទេសស្រីលង្កា ប្រទេសឥណ្ឌា ប្រទេសអ៊ីតាលីជាដើម បានធ្វើទំនាក់ទំនងជាមួយ ពុទ្ធសាសនបណ្ឌិត្យ ពិសេសដើម្បីផ្លាស់ប្តូរពត៌មានដែលទាក់ទងនឹងសាសនា ដូចជាការស្នើរសុំព្រះត្រៃបិដកប្រែ និងទស្សនាវដ្តីកម្ពុជសុរិយាជាដើម។ ដូច្នេះយើងឃើញថា ឥទ្ធិពលនៅក្រៅប្រទេសបានធ្វើឱ្យប្រទេសដទៃស្គាល់អំពីអរិយធម៌ កំលាំងបញ្ញា និងសាសនារបស់ខេមរជនយ៉ាងពិតប្រាកដ។

ក្នុងបំណងរក្សាទូវមរតកប្រពៃណីរបស់ខេមរជន "ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ" មួយត្រូវបានបង្កើតតាម

រាជប្រកាសលេខ១២ ចុះថ្ងៃទី២៥ឆ្នាំ១៩៣៤។ ដើម្បីធានាឱ្យមានការរីកចំរើនខាងវិស័យវប្បធម៌ ក្រុមជំនុំទំនៀមទម្លាប់ មានភារកិច្ចជាចំបង ជាអ្នកតម្កល់ទុកនូវឯកសារដែលទាក់ទងនឹងទំនៀមទម្លាប់ខ្មែរ និងបោះពុម្ពផ្សាយនូវឯកសារ ដែលទាក់ទងនឹងទំនៀមទម្លាប់ និងពិធីបុណ្យខ្មែរផ្សេងៗ ឱ្យជនបរទេសបានស្គាល់។ ក្នុងទិសដៅនេះ កិច្ចការដែលក្រុមជំនុំទំនៀមទម្លាប់បានធ្វើត្រូវអនុវត្តតាមវិធីសាស្ត្រសំខាន់ៗមួយចំនួន រួមមានការចាត់ឱ្យមានការកត់ត្រារាល់ពិធីបុណ្យផ្សេងៗ ធ្វើការចំលងឡើងវិញនូវក្រាំងបុរាណ ជាពិសេសគឺក្រាំងដែលកម្រ ជំរុញឱ្យមានអ្នកឆ្លើយឆ្លងតាមភូមិ ដើម្បីប្រមូលរឿងរ៉ាវដែលទាក់ទងនឹងទំនៀមរបស់ស្រុកនីមួយៗ និងរៀបចំឱ្យមានការប្រកួតដោយសេរីនូវស្នាដៃ អក្សរសាស្ត្រ និងវប្បធម៌។



ព្រះអង្គម្ចាស់ និងអ្នកអង្គម្ចាស់ឡេអូប៉ូលដឹទស្សនាព្រះរាជបណ្ណាល័យ ឆ្នាំ១៩៣២

ជារៀងរាល់ឆ្នាំ ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ តែងតែផ្សព្វផ្សាយឱ្យមានការប្រកួតដោយសេរីនូវអត្ថបទដែលទាក់ទងនឹងប្រពៃណី និងពិធីបុណ្យផ្សេងៗ។ វិធីសាស្ត្រដែលគេធ្វើគឺស្នាដៃដែលជាប់លេខត្រូវទទួលបានការលើកទឹកចិត្តជាប្រាក់ និងទទួលបានសៀវភៅផ្សេងៗដោយឥតគិតលុយ។ តួយ៉ាងជារៀងរាល់ឆ្នាំ ក្រុមជំនុំទំនៀមទម្លាប់តែងតែជូនរង្វាន់ដល់បេក្ខជនដែលបានផ្ញើអត្ថបទប្រកួតប្រជែងអំពីពិធីបុណ្យប្រចាំភូមិរបស់ខ្លួន។

ស្របនឹងការឡើងសោយរាជ្យរបស់ព្រះករុណាព្រះបាទ នរោត្តម សីហនុ និងការទន្ទ្រានអំណាចពីកងទ័ពជប៉ុនមកលើបារាំងផងនោះ ប្រទេសថៃបានឆ្លៀតឱកាសប្រើនូវប្រព័ន្ធផ្សព្វផ្សាយដើម្បីផលប្រយោជន៍

នយោបាយ ។ ចំណែកមន្ទីរពុទ្ធសាសនបណ្ឌិត្យ តាមរយៈការចុះផ្សាយរបស់ទស្សនាវដ្ដីកម្ពុជសុរិយា បានបញ្ចេញនូវប្រតិកម្មឆ្លើយតបនឹងការផ្សាយរបស់ថៃនោះ ។

ផ្ទុយទៅវិញ នៅទីព្រះរាជបណ្ណាល័យ មានកម្មវិធីទទួលយុវសិស្សសាលាថៃដែលបានទទួលប្រកាសនីយប័ត្រពីមហាវិទ្យាល័យ បានប្រារព្ធធ្វើនៅថ្ងៃទី ២៤ ខែសីហា ឆ្នាំ១៩៣៩ ដោយមានកញ្ញា ការប៉ុឡែសជាអ្នករៀបចំ ។ ការផ្លាស់ប្តូររបៀបនៃសេចក្តីស្វាគមន៍ និងតាមរយៈវប្បធម៌នៃចំរៀងជាពួករវាងគ្នា បានយកមកប្រើដើម្បីជំរុញឱ្យមានការប្រាស្រ័យទាក់ទងយោគយល់គ្នារវាងគណៈស្ត្រីថៃ និងគណៈស្ត្រីខ្មែរ ។ ការជួបជុំគ្នានេះជាការភ្ជាប់គ្នារវាងយុវសិស្សថៃ និងយុវសិស្សខ្មែរដើម្បីនឹងសំដែងទឹកចិត្តរបស់យុវសិស្សជំនាន់ថ្មី ក្នុងឋានៈជាជាតិមួយ ។ ក្រុមស្ត្រីក្រុងបាងកកដដែលនេះបានធ្វើដំណើរទៅកូសាំងស៊ីន ពិសេសទៅទស្សនាមន្ទីរឃោសនាការរបស់ក្រសួងអាណានិគមនៅក្រុងព្រៃនគរ ។



រូបគណៈស្ត្រីប្រកាសនីយប័ត្រមហាវិទ្យាល័យសៀម ថតរូបជាមួយពួកយុវសាលាខ្មែរ
នៅមាត់ជណ្តើរ ព្រះរាជបណ្ណាល័យខាងជើងកាលពីថ្ងៃទី២៤ ខែសីហា ឆ្នាំ១៩៣៩

គោលបំណងនៃទស្សនកិច្ច ក៏ដើម្បីទស្សនាស្រុកទាំងឡាយនៅឥណ្ឌូចិន ។ ក្រៅពីនេះ ក៏ចង់ជំរុញឱ្យមានការរួបរួមគ្នារវាងជាតិនៅឥណ្ឌូចិន ជាមួយនឹងជនជាតិថៃ ដើម្បីបើកឱកាសឱ្យមានការសិក្សារវាងប្រទេសទាំងពីរទៅវិញទៅមក ។ ខ្លឹមសារនៅក្នុងសុន្ទរកថារបស់លោកនាយកប្រទេសរាជ្យ បង្ហាញពីសេចក្តីរំភើប និងចេតនាចង់ឱ្យរំលាយបង់នូវសេចក្តីវិវាទដែលកើតឡើងរវាងប្រទេសទាំងពីរ ។

លោក សឺង ង៉ុកថាន់ បានចូលបំរើការនៅ ពុទ្ធសាសនបណ្ឌិត្យ នៅឆ្នាំ១៩៣៥ ហើយដែលបន្ទាប់ពីនោះមកស្ថាប័ននេះបានចូលប្រលូកក្នុងរឿងនយោបាយ ។ នៅឆ្នាំ១៩៣៦ ក្រោមការដឹកនាំរបស់ សឺង ង៉ុកថាន់ សារពត៌មានអ្នកជាតិនិយមមួយឈ្មោះថា "នគរវត្ត" ត្រូវបានបង្កើតឡើងដើម្បីដាស់ស្មារតីរបស់ខេមរជនទាំងអស់ឱ្យភ្ញាក់ឡើង

ប្រឆាំងនឹងការសង្កត់សង្កិនរបស់បារាំង។ លោក ប៉ាច ឈឺន ដែលជាចាងហ្វាងកាសែតនេះមានភារៈចុះទៅមើលស្ថានភាពនយោបាយនៅតាមទីជនបទ ចំណែកអ្នកចេះដឹងមួយចំនួនទៀតមាន លោក សឺង ង៉ុកថាន់ ស៊ឹម វ៉ា ពិទូរក្រសេម ជុំ មួង ញ៉ុក ថែម ទទួលខុសត្រូវច្រើនលើការនិពន្ធអត្ថបទដោយលួចលាក់ ព្រោះថានៅសម័យនោះអ្នករាជការមិនមានសិទ្ធិធ្វើនយោបាយទេ។

ដោយនៅសម័យនោះ ពុទ្ធសាសនបណ្ឌិត្យ មានតួនាទីជាអ្នកចាត់ព្រះសង្ឃឱ្យទៅធ្វើធម្មទេសនា ចំពោះទាហានជើងខ្មៅ ជើងក្រហមនោះ ព្រះសង្ឃក៏បានចូលប្រឡូកក្នុងចលនាជាតិនិយមនេះដែរ។ លោក សឺង ង៉ុកថាន់ អគ្គលេខាធិការរងពុទ្ធសាសនបណ្ឌិត្យ ដែលទទួលបន្ទុកចាត់ចែងព្រះសង្ឃឱ្យទៅទេសនា បានជ្រើសរើសយកតែព្រះសង្ឃណាដែលមាននិន្នាការដូចគ្នា ដូចជាអាចារ្យ ហែម ចៀវ សាស្ត្រាចារ្យបាលី អាចារ្យ ប៉ាង ខាត់ សាស្ត្រាចារ្យសំស្ក្រឹត អាចារ្យ អ៊ុក ជា អាចារ្យ ខៀវ ជុំ មកពីវត្តលង្កា និងអាចារ្យ សូ ហាយ ក្រុមជំនុំបិដកជាដើម។ ទោះជាអ្នកស្នេហាជាតិទាំងនេះត្រូវជួបនូវវាសនាអាក្រក់នៅពេលនោះក៏ដោយ ក៏សាវតាររបស់អ្នកទាំងនេះ ព្រមទាំងអ្នកចូលរួមដទៃទៀត ត្រូវបានគេចារទុក ពិសេសចំពោះឧត្តមគតិក្នុងការថែរក្សានូវអត្តសញ្ញាណជាតិ ដូចជា អក្សរខ្មែរដែលរៀបនឹងបាត់បង់តាំងពីឆ្នាំ១៩៤២ ពេលបារាំងចង់ធ្វើការកែប្រែនោះ។

ក្នុងឆ្នាំ១៩៤១ នៅពេលដែលដឹងពីសេចក្តីទុក្ខវេទនានៃបណ្តាជនដែលចាកចេញពីតំបន់ អាល់សាឡូរ៉ែននេះ ព្រះសិរីសម្មតិវង្ស ឯម រាជការនិងព្រះសង្ឃនៃព្រះរាជបណ្ណាល័យ ក្រុមពុទ្ធសាសនបណ្ឌិត្យ និងពួកសាលាបាលីជាន់ខ្ពស់បានបរិច្ចាកទ្រព្យដើម្បីជួយបន្ធូរបន្ថយដល់សេចក្តីទុក្ខរបស់អ្នកទាំងនោះ។ ប៉ុន្តែសំរាប់ពួកពុទ្ធសាសនិកជននៅកូសាំងស៊ីនវិញ ត្រលប់ជាមានសេចក្តីរីករាយយ៉ាងខ្លាំង ដោយសាររាជការស្រុកនោះមានមេត្តាធម៌ដោយបានបញ្ចូលការគ្រប់គ្រងគណៈសង្ឃរួមជាមួយប្រទេសកម្ពុជា។



ព្រះសង្ឃចំរើនបរិត្តជូនដល់មហាទាហានគរបារាំងសែស នៅមន្ទីរព្រះរាជបណ្ណាល័យ
កាលពីថ្ងៃ១០ ខែកញ្ញា ឆ្នាំ១៩៣៩

ព្រះរាជបណ្ណាល័យ ត្រូវភ្ជាប់ទៅ ពុទ្ធសាសនបណ្ឌិត្យ តាមប្រកាសអារ៉េតេចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ ១៩៣៩។ កំនែទំរង់របស់ពុទ្ធសាសនបណ្ឌិត្យនៅឆ្នាំ១៩៤២ បានធ្វើឱ្យព្រះរាជបណ្ណាល័យលែងក្លាយជាស្ថាប័នដាច់ពីគេទៀតហើយ។ ការងារ និងបុគ្គលិកទាំងអស់ត្រូវផ្ទេរទៅពុទ្ធសាសនបណ្ឌិត្យ ដោយបង្កើតឱ្យមានបណ្ណាល័យផ្នែកបូព៌ានៅពុទ្ធសាសនបណ្ឌិត្យ ហើយសម្បត្តិដើមដែលជាគម្ពីរ សាស្ត្រា និងក្រាំងយកពីក្នុងព្រះរាជវាំងមកនោះ ត្រូវប្រគល់ជូនទៅបណ្ណាល័យព្រះបរមរាជវាំងវិញ។ ការប្រមូលផ្តុំបុគ្គលិកត្រូវបញ្ចប់ដោយការភ្ជាប់ សាលាបាលីជាន់ខ្ពស់ ទៅពុទ្ធសាសនបណ្ឌិត្យ។ ទីបំផុត ព្រះរាជបណ្ណាល័យបានក្លាយជា "បណ្ណាល័យនៃពុទ្ធសាសនបណ្ឌិត្យ" តាមរាជប្រកាសចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ១៩៤៣ ហើយឈ្មោះដើមថា "ព្រះរាជបណ្ណាល័យ" នោះក៏លែងមានតាំងពីពេលនោះមក។

## អន្តរកាល ១៩៤២-១៩៥៤

ដោយហេតុតែ ពុទ្ធសាសនបណ្ឌិត្យ ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៣០ មានទីតាំងនៅជាមួយ ព្រះរាជបណ្ណាល័យ ហើយនៅឆ្នាំ១៩៤៣ព្រះរាជបណ្ណាល័យនេះក៏លែងរក្សាបានទូវនាមដើមរបស់ខ្លួនទៀតនោះ ពុទ្ធសាសនបណ្ឌិត្យជានាមដែលផ្លាស់មកពី ព្រះរាជបណ្ណាល័យកម្ពុជា។



ពុទ្ធសាសនបណ្ឌិត្យក្នុងឆ្នាំ១៩៤៥

ក្នុងនាមជាស្ថាប័នមួយ ដែលប្រមូលផ្តុំទៅដោយអ្នកប្រាជ្ញបណ្ឌិតខ្មែរ ពុទ្ធសាសនបណ្ឌិត្យបានរក្សានូវចំណងទំនាក់ទំនងយ៉ាងល្អជាមួយអ្នកចេះដឹងស្រុកអាយ និងបារាំងដែលខ្វាយខ្វល់អំពីជោគវាសនានៃ វប្បធម៌ខ្មែរ។ សម័្តន្ធភាពនេះ មានការចូលរួមពីសំណាក់អ្នកជាតិនិយមសញ្ជាតិកម្ពុជាក្រោម ដែលបញ្ចប់ការសិក្សាមកពីប្រទេសបារាំងដូចជាលោក សឺង ង៉ុកថាន់ រួមជាមួយតួអង្គសំខាន់ៗក្នុងសាលាបាលីជាន់ខ្ពស់ ក្រុមកាសែតនគរវត្ត ក្រុមយុវសាលា ដែលជាកន្លែងផ្តល់ការជួបជុំសំរាប់បញ្ញវន្តខ្មែរពិភាក្សាអំពីបញ្ហាប្រទេសជាតិ ពុទ្ធិកសមាគម

កម្ពុជរដ្ឋ និងសមាគមអតីតមិត្តអនុវិទ្យាល័យស៊ីសុវត្ថិជាដើម។ ដោយសារសាមគ្គីភាពនេះ បីថ្ងៃក្រោយពីការចាប់ផ្សឹកព្រះតេជគុណ ហែម ចៀវ គឺនៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៤២ តួអង្គសំខាន់ទាំងនេះរួមជាមួយនឹងព្រះសង្ឃយ៉ាងច្រើនបានធ្វើបាតុកម្មនៅមុខវិមាន លោករ៉េស៊ីដង់ជាន់ខ្ពស់ ដើម្បីសុំឱ្យមានការដោះលែង ព្រះសង្ឃនាម ហែម ចៀវ។ ប៉ុន្តែជាលទ្ធផល អ្នកលេចធ្លោជាងគេត្រូវចាប់ខ្លួន និងកាត់ទោស ចំណែកការងារ របស់ស្ថាប័នទាំងនេះត្រូវបានផ្អាកមួយរយៈពេល។

នៅក្នុងខណៈពេលដែល ពុទ្ធសាសនបណ្ឌិត្យ កំពុងតែត្រូវបានទទួលស្គាល់ ជាសាធារណៈនោះ កញ្ញាការប៉ុឡែស បានទទួលចូលនិវត្តន៍។ ការចូលនិវត្តន៍នេះ ទាក់ទងនឹងច្បាប់របស់រដ្ឋាភិបាលវីស៊ីរបស់បារាំង (១៩៤០-១៩៤៥) ដែលហាមឃាត់មិនឱ្យជនជាតិជ្វីសណាមួយធ្វើការនៅក្នុងតំណែងរាជការ ការអប់រំ បោះពុម្ពផ្សាយ និងចូលរួមក្នុងសកម្មភាពជាតិនិយមឡើយ។ នៅថ្ងៃទី៨ ខែមិនា ឆ្នាំ១៩៤១ ព្រះសង្ឃ និងលោកអ្នកដែលធ្វើការនៅពុទ្ធសាសនបណ្ឌិត្យ មានព្រះសិរីសម្មតិវង្ស លី ឯម ព្រះពុទ្ធឃោសាចារ្យ ជួន ណាត និងព្រះសក្យវង្ស ហួត តាត ជាដើម បានមកជួបជុំគ្នានៅព្រះរាជបណ្ណាល័យដើម្បីសម្តែងសេចក្តីអាឡោះអាល័យចំពោះ កញ្ញាការប៉ុឡែស ដែលបានបង្កបង្កើតរៀបចំ ព្រះរាជបណ្ណាល័យ ពុទ្ធសាសនបណ្ឌិត្យ ព្រមទាំងជួយទំនុកបំរុងសាលាបាលីជាន់ខ្ពស់។ ក្នុងឱកាសនោះ ព្រះសក្យវង្ស ហួត តាត បានថ្លែងនូវសុន្ទរកថាមួយដែលសម្តែងអំពីមនោសញ្ចេតនាមិនចង់ឱ្យមានការបែកគ្នានេះ និងរៀបរាប់ជាសង្ខេបនូវសកម្មភាព ការខិតខំប្រឹងប្រែងទាំងឡាយរបស់កញ្ញា ការប៉ុឡែស ក្នុងបំណងធ្វើឱ្យមានសេចក្តីចំរើនខាងវិស័យព្រះពុទ្ធសាសនានៅក្នុងដែនកម្ពុជរដ្ឋ ក៏ដូចជាក្នុងតំបន់កូសាំងស៊ីន និងលាវដែរ។ កិច្ចការទាំងអស់របស់កញ្ញាសុទ្ធតែពុំធ្លាប់មានក្នុងប្រទេសកម្ពុជារាប់រយឆ្នាំមកហើយ។



ព្រះតេជគុណ ហួត តាត និមន្តមកដល់កន្លែងតាំងពិពណ៌ពុទ្ធសាសនា
(ភ្នំពេញ ១៩៥១)

លើសពីនេះទៀត តាមរយៈសុន្ទរវាចាដែលចុះផ្សាយក្នុងកាសែតនគរវត្តនោះ ព្រះសក្យវង្ស ហួត តាត បានសំដែងនូវសេចក្តីចងចាំពុំភ្លេចនូវស្នាដៃដ៏ធំធេងរបស់កញ្ញានេះ ដោយទ្រង់បញ្ជាក់ថា "យើងទាំងអស់គ្នាតាំងចិត្តជានិច្ច និងរក្សាកិច្ចការដែលម៉ាដឹមសែល (កញ្ញា) បានធ្វើរួចមកហើយ មិនឱ្យវិនាសបាត់ទៅវិញ ហើយនិងខិតខំប្រឹងធ្វើកិច្ចការទាំងនោះឱ្យបានចំរើនឡើងដោយលំដាប់តទៅខាងមុខ។ ម្យ៉ាងទៀត យើងនឹងស្រង់ដំណឹងកិច្ចការ ទាំងប៉ុន្មាន ដែលមានខាងលើជាកិច្ចដែលជាប់ដោយនាមរបស់ម៉ាដឹមសែលទុកក្នុងសៀវភៅមិនឱ្យបាត់ សំរាប់ពួកយុវជនខាងក្រោយបាននឹកឃើញ និងបានស្គាល់ឈ្មោះម៉ាដឹមសែលតរៀងទៅ"។ កិច្ចការរបស់កញ្ញា ក៏ត្រូវបានបន្តរហូតមកដល់ជំនាន់ក្រោយៗមកទៀតជាប្រាកដមែន។

ឆ្នាំ១៩៤៣ មន្ទីរពុទ្ធសាសនបណ្ឌិត្យ បានរៀបចំកម្មវិធីប្រជុំមហាសន្និបាតប្រចាំឆ្នាំជាលើកដំបូងអំពីចំណូលចំណាយរួមរបស់ មន្ទីរពុទ្ធសាសនបណ្ឌិត្យ ក្រោមអធិបតីរបស់ លោក ដឺឡង ដែលជានាយករាជការអាណាព្យាបាលបារាំងប្រចាំប្រទេសកម្ពុជា និងចូលរួមដោយសម្តេចព្រះពោធិវង្ស សង្ឃនាយកគណៈមហានិកាយព្រះវិន័យធរ អ៊ូច តំណាងសង្ឃនាយកគណៈធម្មយុត្តិ ព្រះពុទ្ធឃោសាចារ្យ ជួន ណាត ចាងហ្វាងសាលាបាលីជាន់ខ្ពស់ អ្នកឧកញ៉ា អឹង ហ៊ំ រដ្ឋមន្ត្រីក្រសួងធម្មការ និងលោកអគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យ ប៉ៀរឌុយប៉ង់ត៍ ដែលប្រារព្ធឡើងជាលើកដំបូងដើម្បីកំណត់ផែនការហិរញ្ញវត្ថុរបស់ មន្ទីរពុទ្ធសាសនបណ្ឌិត្យ នៅក្នុងដែនដីសហព័ន្ធឥណ្ឌូចិន និងកំនែទំរង់កម្មវិធីបង្រៀនជាដើម។ ផែនការនេះរៀបចំឱ្យមានដំណើរការអប់រំសំរាប់សាខាទាំងឡាយនៅដែនដីឥណ្ឌូចិន ជាពិសេសនៅកូសាំងស៊ីន និងនៅប្រទេសលាវ។ បន្ទាប់ពីបានបង្កើតមន្ទីរនេះហើយ មន្ទីរពុទ្ធសាសនបណ្ឌិត្យមានកម្មវិធីអប់រំទីឆ្ងាយៗនៅដែនដីឥណ្ឌូចិន។ ការគ្រប់គ្រង និងចាត់ចែងរួមជាភារកិច្ចរបស់មន្ទីរពុទ្ធសាសនបណ្ឌិត្យ ដែលមានមូលដ្ឋាននៅក្រុងភ្នំពេញទៅលើមន្ទីរពុទ្ធសាសនបណ្ឌិត្យនៅប៉ាក់សេ (ប្រទេសលាវ) និងមន្ទីរពុទ្ធសាសនបណ្ឌិត្យនៅត្រាវិញ (កម្ពុជាក្រោម)។ យោងតាមប្រសាសន៍របស់លោកនាយករាជការអាណាព្យាបាលមានបំណងរៀបចំឱ្យមានគោលចារឹកនៃរបៀបគ្រប់គ្រងរួម។ លោកមានប្រសាសន៍សង្កត់ធ្ងន់ថា របៀបចាត់ចែងថ្មីរបស់ពុទ្ធសាសនបណ្ឌិត្យក្រុងភ្នំពេញមិនត្រូវតាមរបៀប ពុទ្ធសាសនបណ្ឌិត្យ ដទៃទៀតទោះជាប្រទេសលាវ ឬកូសាំងស៊ីនក្តី ប៉ុន្តែពុទ្ធសាសនបណ្ឌិត្យក្រុងភ្នំពេញនឹងជួយទំនុកបំរុងរបៀបរៀបចំថ្មីតាមតែពុទ្ធសាសនបណ្ឌិត្យឯទៀតត្រូវការ។

លោកនាយកអាណាព្យាបាលនៃប្រទេសកម្ពុជាបានមានប្រសាសន៍ថា នៅប្រទេសកម្ពុជា ដោយការរៀបចំរបៀបរបបថ្មីនៃការគ្រប់គ្រងបានសំរេចបញ្ចូលផ្នែកផ្សេងៗនៅ ពុទ្ធសាសនបណ្ឌិត្យ ឱ្យរួមគ្នាជាក្រសួងមួយរួមទាំងរៀបចំទៅលើប្រាក់ចំនូលចំណាយផង។ ជាពិសេសព្រះរាជបណ្ណាល័យ ដែលមានគោលចារឹកគ្រប់គ្រងច្បាស់លាស់នោះឥឡូវរាជការបានបែងចែកជាពីរចំណែក គឺមួយផ្នែកត្រូវបានបញ្ចូលទៅក្នុងការគ្រប់គ្រងរបស់

ពុទ្ធសាសនបណ្ឌិត្យ និងមួយផ្នែកទៀតស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងព្រះរាជនិពន្ធ ក្នុងព្រះបរមរាជវាំង។ គំនិតរបស់លោកនាយកអាណាព្យាបាលមានបំណងឱ្យពិចារណាទៅលើ ក្រុមជំនុំព្រះត្រៃបិដក ដើម្បីឱ្យមានលទ្ធភាពរៀបចំជាក្រសួងមួយរបស់រាជការ។ ម្យ៉ាងទៀត សាលាបាលីជាន់ខ្ពស់ក៏បានរៀបចំដើម្បីភ្ជាប់ជាមួយពុទ្ធសាសនបណ្ឌិត្យ ។

សាលាបាលីជាន់ខ្ពស់ ត្រូវបានផ្ទេរមកឱ្យរដ្ឋាភិបាលខ្មែរនៅថ្ងៃសុក្រទី៣១ ខែធ្នូ ឆ្នាំ១៩៤៨ ដោយរាជការអាណាព្យាបាលបារាំង។ បន្ទាប់ពីការគ្រប់គ្រងអស់រយៈពេល៣០ឆ្នាំ ទើបមានពិធីប្រគល់ការគ្រប់គ្រងសាលាបាលី ជាផ្លូវការក្រោមអធិបតីរបស់លោក ហ្វ្រង់ស្វ័រ ម៉ារទីនី ជាទីប្រឹក្សា ក្រសួងធម្មការ និងជាអគ្គលេខាធិការនៃមន្ទីរពុទ្ធសាសនបណ្ឌិត្យ ជូនមករាជការខ្មែរ។ នាពេលសម្ពោធ លោកកុង្ស៊ីយ៍ក្រសួងសាធារណៈបានមានប្រសាសន៍រំលឹកពីមូលហេតុជាចំបងនៃការបង្កើតសាលាបាលីនេះឡើង ព្រោះព្រះសង្ឃខ្មែរ និងជាតិលាវតែងតែទៅបន្តការសិក្សាផ្នែកសាសនារបស់ខ្លួននៅប្រទេសសៀម។

ចំណែក មន្ទីរពុទ្ធសាសនបណ្ឌិត្យ ត្រូវបានផ្ទេរមកឱ្យរដ្ឋាភិបាលខ្មែរនៅថ្ងៃទី១៤ ខែតុលា ឆ្នាំ១៩៥០ ក្រោមអធិបតីនៃព្រះករុណាជីវិតតំកល់លើត្បូង។ ពិធីនេះកើតឡើងបន្ទាប់ពីមានសន្ធិសញ្ញាបារាំង-ខ្មែរ ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ១៩៤៩ ដែលអំណាចមួយចំនួនត្រូវបានប្រគល់មកឱ្យរដ្ឋាភិបាលវិញ។ មន្ទីរពុទ្ធសាសនបណ្ឌិត្យបានបំពេញភារកិច្ចរបស់ខ្លួនលើកិច្ចការសាសនា និងវប្បធម៌អស់រយៈកាលយ៉ាងយូរ ពេលនេះភារកិច្ចគ្រប់គ្រងបន្តត្រូវទទួលខុសត្រូវដោយខ្លួនឯង។ ក្រោយពីការផ្ទេរនោះមក លោក យឿន ចឹម ដែលធ្លាប់ធ្វើការនៅទីនេះតាំងពីយូរមកហើយនោះបានឡើងជានាយកវិជ្ជាឋាននេះ។

ក្រោយពីការប្រគល់ មន្ទីរពុទ្ធសាសនបណ្ឌិត្យ ឱ្យទៅរដ្ឋាភិបាល ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ ដែលមានតម្កល់ ឯកសារ៩៩ប្រភេទ បានរៀបចំរបៀបប្រមូលឯកសាររបស់ខ្លួនតាមរយៈវិធីសាស្ត្រសំខាន់៧មានដូចជាឱ្យមានការយល់ព្រមទទួលធ្វើជាសមាជិកឆ្លើយឆ្លងរបស់ក្រុមជំនុំទំនៀមទម្លាប់ និងព្រមទទួលសរសេរទំនៀមណាមួយ ដែលទាក់ទងបញ្ជីរាយឈ្មោះថតទាំង៩៩ ដើម្បីផ្ញើមកកាន់ក្រុមជំនុំ ទទួលធ្វើជាបេក្ខជនសរសេរឯកសាររឿងទំនៀមទម្លាប់ផ្ញើទៅប្រឡងតាមកាលបរិច្ឆេទ ដែលក្រុមជំនុំបើកឱកាសឱ្យមានការប្រឡងប្រជែង និងទទួលធ្វើជាបេក្ខជនសរសេរចម្លងរឿងទំនៀមទម្លាប់ផ្ញើទៅឱ្យក្រុមជំនុំ។

ផ្អែកលើវិធីសាស្ត្រខាងលើ ពេលវេលានៃការប្រកួតប្រជែងនៅ ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ រៀបរៀងជារៀងរាល់៦ខែម្តងជារៀងរាល់ឆ្នាំ។ ចំណែកពួកសមាជិកឆ្លើយឆ្លងដែលបានសរសេរអត្ថបទមក ត្រូវបានក្រុមជំនុំសំរេចជ្រើសរើស និងពិនិត្យផ្តល់រង្វាន់ដល់សមាជិកទាំងនោះក្នុងពេលជាមួយនោះដែរ។ វិធីសាស្ត្រដែលបានយក

មកប្រើក្នុងការលើកទឹកចិត្តគឺ ក្រុមជំនុំនឹងស្រង់យកឈ្មោះអ្នកទាំងនោះចុះក្នុងសារពត៌មានកម្ពុជា ទស្សនាវដ្តីកម្ពុជសុរិយា ឬសៀវភៅរបស់ក្រុមជំនុំរៀបរៀងពីអរិយធម៌ខ្មែរ។



ពុទ្ធសាសនបណ្ឌិត្យក្នុងឆ្នាំ១៩៤៥

## សម័យឯករាជ្យ ១៩៥៤-១៩៧៥

ក្នុងសម័យឯករាជ្យនេះ ពុទ្ធសាសនបណ្ឌិត្យ ត្រូវស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងធម្មការ ត្រួតត្រាដោយក្រុមប្រឹក្សាភិបាលមួយ និងដឹកនាំផ្ទាល់ដោយអគ្គលេខាធិការមួយរូប។ ស្ថាប័ននេះជា មជ្ឈមណ្ឌលអក្សរសាស្ត្រ និងវប្បធម៌ និងហាក់ដូចជាមានការតម្កើងឋានៈជា "វិជ្ជាឋាន"។ ជារៀងរាល់ឆ្នាំ "វិជ្ជាឋានពុទ្ធសាសបណ្ឌិត្យ" បានដាក់លក់សៀវភៅពី ៤០០.០០០ ទៅ ៥០០.០០០ ក្បាលក្នុងតំលៃសមល្មម ក្នុងបំណងរួមចំណែកអភិវឌ្ឍផ្នែកបញ្ញា។ សៀវភៅទាំងនេះ បោះពុម្ពជាភាសាខ្មែរ សំស្ក្រឹត និងភាសាបរទេស ដែលផ្តោតលើផ្នែកអក្សរសាស្ត្រ សិល្បៈ បុរាណវិទ្យា និងប្រវត្តិព្រះពុទ្ធសាសនា។ ក្រៅពីនេះក៏មានការដាក់លក់វចនានុក្រមខ្មែរ ព្រះត្រៃបិដក និងទស្សនាវដ្តីកម្ពុជសុរិយា ដែលជាប្រភពសំខាន់ក្នុងការសិក្សាអំពី អក្សរសាស្ត្រ និងសាសនារបស់ខ្មែរផងដែរ។

លើសពីនេះទៀតក៏មានការចុះផ្សាយអត្ថបទជាភាសាខ្មែរតាមសារពត៌មាន ក៏ដូចជាតាមវិទ្យុ សំរាប់ជួយផ្សព្វផ្សាយវប្បធម៌ខ្មែរ។ អ្នកអាន ទាំងគ្រហស្ថ ទាំងបព្វជិត ក៏អាចអានសៀវភៅនៅបណ្ណាល័យពុទ្ធសាសនបណ្ឌិត្យ មានរហូតដល់ ១៥.០០០ ចំណងជើងជាភាសាខ្មែរ បារាំង អង់គ្លេស សៀម លាវ ភូមាជាដើម ដែលនិយាយអំពីនិរុត្តិវិទ្យា សាសនា ប្រវត្តិវិទ្យា បុរាណវិទ្យា និងប្រធានបទដទៃទៀត។ ពុទ្ធសាសនបណ្ឌិត្យ មិនត្រឹមតែមាននាទី រក្សាឯកសារបោះពុម្ពលើក្រដាសប៉ុណ្ណោះទេ គឺថែមទាំងរក្សាទូវសាស្ត្រាស្លឹករឹត សរសេរជាភាសាបាលី និងភាសាខ្មែរ ដែលនិយាយពីធម៌អាថ៌ រឿងព្រេងប្រជាប្រិយ ប្រពៃណី វប្បធម៌ អរិយធម៌

ប្រវត្តិសាស្ត្រ សិល្បៈ របាំ ចម្រៀង។ ក្រៅអំពីសៀវភៅឯកសារ បណ្ណាល័យមានតម្កល់ទស្សនាវដ្ដី ទាំងភាសាខ្មែរ និងបរទេស ព្រឹត្តិបត្រ សំរាប់ឱ្យអ្នកអាន និងអ្នកស្រាវជ្រាវប្រើប្រាស់ជារៀងរាល់ថ្ងៃ។ ក្រៅពីនេះទៀត បណ្ណាល័យវិទ្យាស្ថាននេះ ថែមទាំងមានសទ្ទពិម្ពាល័យ (ទូរដាក់ថាសសំលេង) មួយ និងឆាយវិត្រាល័យ (កន្លែងទុករូបថត)មួយទៀតផងដែរ។ បណ្ណាល័យនេះ ជាប្រភពតែមួយគត់ក្នុងប្រទេសខ្មែរ ដែលមានឯកសារ និងពត៌មានស្ដីអំពីសាសនា និងអក្សរសាស្ត្រ។



សហជីវិន អនុរដ្ឋលេខាធិការ អ៊ុក ម៉ូត លើកព្រះត្រៃបិដក
ប្រគេន សម្ដេចព្រះសង្ឃនាយកជានិមិត្តរូប មុននឹងចេញក្បួនហែរឆ្នាំ១៩៦៩

អ្វីដែលជាមោទនភាពប្រសើរបំផុតមួយទៀត សំរាប់ ពុទ្ធសាសនបណ្ឌិត្យ ក្នុងសម័យឯករាជ្យនេះ គឺការប្រារព្ធពិធីសម្ពោធព្រះត្រៃបិដក។ ក្រោយពីចំណាយពេលចំនួន៣៩ឆ្នាំក្នុងការចងក្រង និងបកប្រែព្រះត្រៃបិដក ក្រុមព្រះសង្ឃិតិកាចារ្យ (ក្រុមជំនុំព្រះត្រៃបិដក) បានបញ្ចប់កិច្ចការរបស់ខ្លួនយ៉ាងគួរជាទីមោទនៈជាស្ថាពរនៅឆ្នាំ១៩៦៨។ នៅឆ្នាំចុងក្រោយនេះ ពុទ្ធសាសនបណ្ឌិត្យបានធ្វើការបោះពុម្ពផ្សាយគម្ពីរព្រះត្រៃបិដក ដែលមានសរសេរជាភាសាបាលី-ខ្មែរ ពីដើមដល់ចប់បានចំនួន ១១០ ភាគ។ រហូតដល់ថ្ងៃទី១ ខែមេសា ឆ្នាំ១៩៦៩ ពិធីសម្ពោធព្រះត្រៃបិដកត្រូវបានធ្វើឡើងនៅគ្រប់វត្តអារាមទាំងអស់ ទូទាំងព្រះរាជាណាចក្រ យ៉ាងឱឡារិក។ ពិធីសម្ពោធដ៏អធិកអធម ដែលមានការចូលរួមពីថ្នាក់ដឹកនាំជាតិ ទាំងគ្រហស្ថ ទាំងព្រះសង្ឃ ដើម្បី

រំលឹកដល់ស្នាព្រះហស្ថ និងស្នាដៃដ៏មហិមារបស់កវីបណ្ឌិតជាតិខេមរៈ និងជាការសំដែងឱ្យឃើញនូវបីតិសោមនស្សរបស់ប្រជាជាតិខ្មែរ ដែលគោរពព្រះពុទ្ធសាសនា ដោយមានគម្ពីរទាំងអស់នេះជាពុទ្ធវចនៈស្រាប់។



សម្ដេចព្រះប្រមុខរដ្ឋទ្រង់ប្រគេនគ្រឿងឥស្សរិយយស មហាសិរីវឌ្ឍន៍សុវត្ថារា
ចំពោះសម្ដេចព្រះពោធិវង្ស ហួត តាត ឆ្នាំ១៩៦៩

ជាមួយគ្នានេះដែរ ពុទ្ធសាសនបណ្ឌិត្យ ក៏បានពង្រីកនូវទំនាក់ទំនងវប្បធម៌យ៉ាងទូលំទូលាយជាមួយបណ្ដាប្រទេសក្នុងសកលលោក ក្រោមព្រះរាជូបត្ថម្ភដ៏ខ្ពង់ខ្ពស់របស់សម្ដេចព្រះនរោត្តមសីហនុ ជាព្រះប្រមុខរដ្ឋ។ ក្រោមព្រះអគ្គមគ្គុទ្ទេសក៏ដ៏ឆ្នើមរបស់ព្រះអង្គ ពុទ្ធសាសនបណ្ឌិត្យ ក៏ដូចជាសាសនាជាតិទាំងមូល រឹងរឹតតែមានសេចក្ដីចំរើនជាដរាបរៀងមក។ សម្ដេចព្រះសង្ឃរាជ ជួន ណាត នៅឆ្នាំ១៩៥៤ បានដឹកនាំគណៈប្រតិភូខ្មែរមួយក្រុមនិមន្តចូលរួមនៅក្នុងសង្គាយនាលើកទី៦ នៅប្រទេសភូមាទៀតផង នៅក្នុងឱកាសនោះហើយដែល ប្រទេសភូមាបានប្រទានងារជា "អគ្គមហាបណ្ឌិត"ដល់សម្ដេចព្រះសង្ឃរាជខ្មែរ ដោយគេទទួលស្គាល់នូវគតិបណ្ឌិតរបស់ព្រះអង្គ។ លើសពីនេះ នៅខែឧសភា ឆ្នាំ១៩៥៧ ព្រះរាជាណាចក្រកម្ពុជាបានប្រារព្ធធ្វើបុណ្យគម្រប់ ២៥០០ ព្រះវស្សា របស់ព្រះពុទ្ធសាសនា នៅទីក្រុងភ្នំពេញ ដោយមានការនិមន្តចូលរួមពីប្រជាពលរដ្ឋ និងព្រះសង្ឃទាំងក្នុង និងក្រៅប្រទេសយ៉ាងច្រើនកុះករ។



ព្រះអង្គម្ចាស់នរោត្តម សីហនុ ព្រះប្រមុខរដ្ឋ
ព្រះប្រទានសញ្ញាប័ត្របណ្ឌិតអក្សរសាស្ត្រខ្មែរដល់សម្ដេច
ព្រះសង្ឃរាជ ជួន ណាត ក្នុងថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៦៧

## ការបិទទ្វារ ១៩៧៥-១៩៩២

វិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យ ត្រូវបានបិទទ្វារទាំងស្រុងក្នុងឆ្នាំ១៩៧៥ ។ ក្នុងរបបប្រល័យពូជសាសន៍ ចន្លោះឆ្នាំ១៩៧៥-១៩៧៩ ជំនឿសាសនាផ្នែកប្រតិបត្តិត្រូវបានហាមឃាត់ ។ លំដាប់ក្រោយមក ពេលដែលរបបទមិឡនេះដួលរលំទៅហើយនោះ វិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យ ក៏ពុំទាន់ត្រូវបានគេស្តារឡើងវិញភ្លាមដែរ ហើយការប្រតិបត្តិព្រះពុទ្ធសាសនាក៏មិនត្រូវបានគេផ្តល់សេរីភាពច្រើននោះទេ មានការដាក់ល័ក្ខខ័ណ្ឌចំពោះការបួសជាដើម ។ ស្ថាប័នសិក្សាស្រាវជ្រាវលើព្រះពុទ្ធសាសនា និងអក្សរសាស្ត្រប្រពៃណីខ្មែរមួយនេះ មានជីវិតឡើងវិញក្រោយពីមានកិច្ចព្រមព្រៀងទីក្រុងប៉ារីសឆ្នាំ១៩៩១ ។

## ការចាប់បដិសន្ធិឡើងវិញ ១៩៩២-២០០៥

ពុទ្ធសាសនបណ្ឌិត្យ បានចាប់បដិសន្ធិឡើងវិញនៅឆ្នាំ១៩៩២ នៅពេលដែលរដ្ឋសភានៃរដ្ឋកម្ពុជាបានអនុម័តច្បាប់បង្កើតឱ្យមានក្រសួងធម្មការឡើងវិញ ។ ចាប់តាំងពីដើមឆ្នាំ១៩៩២ រៀងមក ពុទ្ធសាសនបណ្ឌិត្យបានខិតខំស្តារសមត្ថភាព និងលទ្ធភាពរបស់ខ្លួនឡើងវិញ សំដៅចាប់យកនូវភាពរុងរឿងរបស់ខ្លួនឡើងវិញដោយបានសំរេចការងារដ៏ជោគជ័យគួរឱ្យកត់សំគាល់មួយចំនួនគួរជាទីមោទនៈ ។ រចនាសម្ព័ន្ធរបស់ខ្លួនពីអតីតត្រូវបានស្តារឡើងវិញ ដើម្បីសំរួលដល់គុណភាពនៃការគ្រប់គ្រង និងប្រសិទ្ធិភាពការងារ ។ វិទ្យាស្ថាននេះរួមបញ្ចូលនូវការិយាល័យរដ្ឋបាល ក្រុមជំនុំព្រះត្រៃបិដក ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ បណ្ណាល័យ និងគណៈកម្មការកម្ពុជសុរិយា និងបោះពុម្ពផ្សាយ ។

នៅក្នុងសម័យអាណាព្យាបាលបារាំង ពុទ្ធសាសនបណ្ឌិត្យទទួលបាននូវការគាំទ្រពីសំណាក់រដ្ឋាភិបាលបារាំង ។ ក្រោយពីការផ្ទេរមកឱ្យរដ្ឋាភិបាលខ្មែរ ស្ថាប័ននេះត្រូវទទួលបានការលើកទឹកចិត្តពីក្រសួងធម្មការ ដែលជាអាណាព្យាបាលរបស់ខ្លួន ។ ប្រពៃណីនេះ បានបន្តរហូតដល់បច្ចុប្បន្ន ខុសគ្នាតែត្រង់ថា វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ចាប់តាំងពីឆ្នាំ១៩៩២ រហូតដល់បច្ចុប្បន្ន ទទួលបាននូវការផ្តល់ជំនួយពីអង្គការសប្បុរសធម៌មួយចំនួនថែមទៀត ជាពិសេសមកពីមូលនិធិហៃនរិចបូល របស់ប្រទេសអាល្លឺម៉ង់ និងពីបណ្តាអង្គការមួយចំនួនរបស់ជប៉ុន ។ ជំនួយនេះហើយ ដែលជាកំលាំងធំមួយធ្វើឱ្យវិទ្យាស្ថាននេះប្រព្រឹត្តទៅដោយរលូនរហូតមក ។

បុគ្គលិកបំរើការក្នុងផ្នែកនានានៃរចនាសម្ព័ន្ធថ្មីនេះ បានទទួលការបណ្តុះបណ្តាលជំនាញ និងការឧបត្ថម្ភលើកទឹកចិត្តពីអង្គការផ្តល់ជំនួយ និងស្ថាប័នជាតិដទៃទៀត ។ បុគ្គលិកមួយចំនួនក៏មានសមត្ថភាពធានាការងារបានជាមូលដ្ឋានដូចជាបោះពុម្ពត្រឹមត្រូវមិនភ្លាំងភ្លាត់បាលី សម្រាយ ចេញផ្សាយឡើងវិញនូវទស្សនាវដ្តីកម្ពុជសុរិយា

ក្នុងឆ្នាំ១៩៩៤ ដំណើរការស្រាវជ្រាវប្រពៃណី ទំនៀមទម្លាប់ នឹងបន្តការបកប្រែគម្ពីរពីភាសាបាលីមកជាភាសាជាតិ គឺបកប្រែគម្ពីរមង្គលត្ថទីបនីទាំងបួនភាគ ដោយធ្វើតាមលំនាំការបកប្រែព្រះត្រៃបិដក គឺបាលីនៅទំព័រម្ខាង និងម្ខាងទៀតជាសេចក្ដីបកប្រែ ។

ក្រោមជំនួយជាថវិកាពីអង្គការសាសនា និងមនុស្សធម៌របស់ជប៉ុន ពុទ្ធសាសនបណ្ឌិត្យបានបោះពុម្ពឡើងវិញនូវសៀវភៅសិក្សាភាសាបាលី សៀវភៅធម៌ សៀវភៅអក្សរសាស្ត្របានចំនួនជិត២០ចំណងជើង ហើយនិងមានចំនួនជាច្រើនម៉ឺនក្បាល ។ ចំនួននេះអាចបំរើតាមសំណូមពរចង់ចេះដឹងរបស់ព្រះសង្ឃ ព្រមទាំងពុទ្ធសាសនិកជនទូទៅបានឡើងវិញជាបណ្ដើរៗ ។ ការបោះពុម្ព ដ៏សំខាន់មួយទៀត គឺការបោះពុម្ពគម្ពីរព្រះត្រៃបិដកឡើងវិញចំនួន១២០០០ច្បាប់ ។ ពិធីប្រគល់ព្រះត្រៃបិដកនេះ ប្រព្រឹត្តទៅនៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៩៥ ក្រោមព្រះរាជាធិបតីដ៏ខ្ពង់ខ្ពស់របស់ព្រះករុណាជាអង្គម្ចាស់តម្កល់លើត្បូង និងព្រះរាជអគ្គមហេសី ដោយមាន ការយាង និងអញ្ជើញចូលរួមពីភាគីជប៉ុនយ៉ាងច្រើន ។ ការឧបត្ថម្ភនេះបានជួយឱ្យអក្សរសាស្ត្រពុទ្ធសាសនាមានស្ថេរភាព យ៉ាងល្អ បើទោះជាចំនួនបោះពុម្ពនេះ មិនទាន់បំរើសំណូមពរព្រះសង្ឃ និងពុទ្ធសាសនិកជនបានគ្រប់វត្តអារាមក៏ដោយ ហើយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ នឹងបន្តសុំការឧបត្ថម្ភបោះពុម្ពព្រះត្រៃបិដកជាថ្មីទៀត នាពេលខាងមុខ ។

ការឧបត្ថម្ភជាសម្ភារៈ ក៏បានធ្វើឱ្យពុទ្ធសាសនបណ្ឌិត្យ មានឧបករណ៍ប្រើប្រាស់គ្រប់គ្រាន់ សំរាប់ការងារបោះពុម្ព សំរាប់ការងារសោតទស្សន៍ សំរាប់ដំណើរការងារការិយាល័យ និងមានថវិកាសមល្មមធ្វើឱ្យពុទ្ធសាសនបណ្ឌិត្យ ប្រព្រឹត្តទៅបានស្រួល ។ ជំនួយទាំងអស់នេះ ថែមទាំងបានជួយឱ្យមាននិរន្តភាពដល់ដំណើរការប្រចាំថ្ងៃ កិច្ចការប្រមូលផ្ដុំឯកសារសំរាប់បណ្ណាល័យ ក៏ដូចជាការរៀបចំបង្កើតសាខាខេត្ត-ក្រុងពីចំនួន ១៨ ទៅ ២៥ កន្លែង និងបំផុសឱ្យមានសកម្មភាពវប្បធម៌ ដូចជាធម្មសាកច្ឆាប្រចាំខែ ។

លើសពីនេះទៀត ជាមួយនឹងការឧបត្ថម្ភទាំងឡាយចាប់តាំងពីពាក់កណ្ដាលឆ្នាំ ១៩៩៣ រហូតមកពុទ្ធសាសនបណ្ឌិត្យ ទទួលបាននូវថាមពលថ្មីមួយទៀត គឺការលើកស្ទួយកំរិតចេះដឹងរបស់បុគ្គលិក ខាងគណនេយ្យ ខាងភាសាអង់គ្លេស និងខាងជំនាញកុំព្យូទ័រ ព្រមទាំងជំនាញគ្រប់គ្រងខាងបណ្ណាល័យ និងខាងការគ្រប់គ្រងទូទៅផងដែរ ។ សារពត៌មាន និងទស្សនាវដ្ដីក្នុងស្រុកស្ទើរតែទាំងអស់ ក៏ត្រូវបានជាវជាប្រចាំឡើងវិញ ហើយចងក្រងទុកទៅតាមក្រុមតាមជំពូកយ៉ាងរៀបរយ ។ សៀវភៅប្រមាណ ១.២០០ ចំណងជើងត្រូវបានទិញ និងបញ្ជូនឱ្យរួចជាស្រេច ។ ក្នុងការងារទំនាក់ទំនង ប្ដូរឯកសារគ្នា សំដៅចែករំលែកចំណេះដឹង និងបទពិសោធន៍ទៅវិញទៅមករវាងបណ្ណាល័យ ស្ថាប័នសិក្សាស្រាវជ្រាវជាតិ និងអន្តរជាតិ នៅមានដំណើរការសហការជាបន្តបន្ទាប់ ។

ដោយមានប្រភពធនធានឧបត្ថម្ភដូចបានជម្រាបខាងលើ ពុទ្ធសាសនបណ្ឌិត្យ កាន់តែមានលទ្ធភាពធំទូលាយ ក្នុងការបំពេញការងាររបស់ខ្លួនក្នុងស្ថានភាពល្អបង្គួរ ដោយមិនលើកយកបញ្ហាចម្រូងចម្រាស គ្មានហេតុផលល្អៗដែលបានកើតមានឡើងមកធ្វើជាឧបសគ្គទេ។ វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ឈ្មោះដែលគេប្រើជាផ្លូវការក្នុងអាណត្តិក្រោយនេះ កំពុងធ្វើដំណើរទៅចាប់យកនីតិឋានចាស់របស់ខ្លួនឱ្យបានប្រសើរ។ ផ្អែកលើប្រភពធនធាននេះ វិទ្យាស្ថានមានលទ្ធភាពជំរុញការគោរពប្រតិបត្តិធម៌អាថ៌ និងការសិក្សារបស់ព្រះសង្ឃ តាមរយៈការចុះដល់មូលដ្ឋានចែកផ្សាយដោយឥតគិតថ្លៃ នូវសៀវភៅធម៌ និងសៀវភៅសិក្សាភាសាបាលីមួយចំនួន ដែលបោះពុម្ពនៅក្នុងស្រុក និងក្រៅស្រុកដល់គ្រប់វត្តទូទាំងប្រទេស។ សៀវភៅទាំងនេះមានជាអាទិ៍ សត្តបរិត្ត ភាណវារៈបាលី ប្រស្នាវិន័យបិដក បទានុក្រមបាលី អភិធានប្បទីបិកា បទានុក្រមធម្មបទជាដើម។

តាមការរៀបរាប់ពីសកម្មភាពខាងដើម គេអាចមានសេចក្តីពេញចិត្ត ចំពោះការរស់ឡើងវិញដ៏ឆាប់របស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ក្នុងរយៈពេលដ៏ខ្លី គឺក្នុងអំឡុងពេលប្រមាណបួនឆ្នាំមកនេះ។ ស្ថាប័ននេះបានដើរតួយ៉ាងសំខាន់ក្នុងដំណើរកសាង និងជួសជុលឡើងវិញនូវវប្បធម៌ និងពុទ្ធសាសនាជាតិ។ ទោះបីសមិទ្ធិផលទាំងនេះបានកកើតឡើងយ៉ាងយឺតៗ ហើយមានចំនួនតិចតួចក្តី ក៏គេបានចាត់ទុកថា នោះគឺជាជំហានដ៏សំខាន់ឆ្ពោះទៅរកការកសាងគ្រឹះរបស់ពុទ្ធសាសនបណ្ឌិត្យឡើងវិញ ដែលត្រូវបានកំទេចដល់ឫសកែវដោយសារសង្គ្រាម។

ជំនួយរបស់អង្គការជាមិត្ត ទាំងផ្នែកថវិកា និងសម្ភារៈ ដែលជាវិភាគទានដ៏សំខាន់ក្នុងការជួសជុលអគារសំរាប់ប្រើជាបណ្ណាល័យ និងការិយាល័យ ជាមួយនឹងសាលប្រជុំ ប្រកបដោយសម្ភារៈប្រើប្រាស់ជាច្រើន បានធ្វើឱ្យវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ មានសមត្ថភាពបំពេញមុខងាររបស់ខ្លួន ជាការិយាល័យរដ្ឋបាល និងបោះពុម្ពផ្សាយជាបណ្ណាល័យ និងជាវិទ្យាស្ថានស្រាវជ្រាវ រក្សាទុកឯកសារ។

ការរីកចំរើនរបស់បណ្ណាល័យ ជាក់ស្តែង ចំនួនសៀវភៅកើនពី១.០០០ ចំណងជើង ក្នុងឆ្នាំ១៩៩៤ ដល់៦.០០០ចំណងជើងក្នុងដំណាច់ឆ្នាំ១៩៩៦។ ទស្សនាវដ្តីកម្ពុជសុរិយា ត្រូវបានបោះពុម្ពឡើងវិញជាបន្តបន្ទាប់ និងបានចេញលេខថ្មីតាមលំដាប់លំដោយរហូតមក។ បណ្ណាល័យសាខាចំនួន១៨កន្លែង ត្រូវបានរៀបចំហើយសៀវភៅទាំងឡាយសំរាប់បណ្ណាល័យទាំងនោះ ក៏បានបញ្ជូនទៅហើយដែរ។

ដើមឡើយ ការងារស្រាវជ្រាវធ្វើបានតិចតួចណាស់ ហើយខ្វះទាំងបរិមាណ និងគុណភាពថែមទៀត។ សៀវភៅថ្មីៗ ផ្អែកលើការស្រាវជ្រាវថ្មីពុំទាន់មានបោះពុម្ពច្រើនទេ ថ្វីបើមានអត្ថបទចុះផ្សាយក្នុងកម្ពុជសុរិយាបានផ្អែកលើការស្រាវជ្រាវមានគុណភាពមធ្យមក៏ដោយ។ ការផ្សព្វផ្សាយអំពីបណ្ណាល័យឱ្យបានទូលំទូលាយចូលជ្រៅក្នុងស្រទាប់សាធារណៈជនមិនទាន់ធ្វើបានឡើយ។ ការធ្វើផែនការដើម្បីបង្កើនការប្រើបណ្ណាល័យ និងការប្រើសម្ភារៈស្រាវជ្រាវចងក្រងបានជាអត្ថបទសរសេរជាខ្មែរអាត់ ឬជាខ្សែវីដេអូក៏ពុំទាន់បានអនុវត្តន៍ឱ្យបានទូលំទូលាយដែរ។

រចនាសម្ព័ន្ធ និងនីតិវិធាន ឬទីតាំងច្បាប់របស់វិទ្យាស្ថាន ក៏ពុំទាន់បានរៀបចំច្បាស់លាស់ ដើម្បីឆ្ពោះទៅកាន់ភាពឯករាជ្យម្ចាស់ការមានលក្ខន្តិកៈជាវិទ្យាស្ថានស្វយ័ត និងមានក្រុមប្រឹក្សាភិបាលមួយទូលំទូលាយសំរាប់ជួយតម្រង់ទិសសកម្មភាពរបស់ពុទ្ធសាសនបណ្ឌិត្យ។ ការប្រព្រឹត្តិទៅរបស់ វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យត្រូវការឱ្យមានការប្រជុំទៀងទាត់ ដើម្បីដោះស្រាយការងារ ដាក់ចេញជាផែនការ សកម្មភាព រៀបចំគោលនយោបាយ កម្មវិធីការងារ និងដំណើរការអនុវត្តបានល្អ។ ការខិតខំរៀបចំបែបនេះត្រូវប្រព្រឹត្តទៅដំណាលគ្នានឹងការបណ្តុះបណ្តាលធនធានមនុស្ស ដែលកិច្ចការនេះជាកត្តាចំបង។

ដោយថ្លឹងថ្លែងពីតំណែលអតីត តួនាទីបច្ចុប្បន្ន និងគោលដៅទៅអនាគត វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យបច្ចុប្បន្នតាំងនៅក្នុងសំណង់អគារថ្មីមួយ ដែលគូរប្លង់ដោយលោក លី ចិនតុង ដោយមានលាយបញ្ចូលគ្នានូវលំអដូចវត្តអារាម និងស្ថាបត្យកម្មរបស់ព្រះរាជបណ្ណាល័យ ដើម្បីជាការរំលឹកនូវអតីតកាលរបស់ខ្លួន។ សំណង់អគារថ្មីនេះត្រូវបានសម្ពោធបើកជាផ្លូវការនៅ ថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩៨ លើផ្ទៃដីជាប់ឧទ្យានសម្តេច ហ៊ុន សែន នាមាត់ទន្លេបាសាក់ ក្រោមអធិបតីភាពរបស់សម្តេចជា ស៊ីម ប្រធានព្រឹទ្ធសភា និងជាព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់របស់ព្រះករុណាជាអង្គម្ចាស់ជីវិតតម្កល់លើត្បូង។ ប៉ុន្តែទំនើបកម្មក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះបង្ហាញឱ្យឃើញនូវការប្រឈមមុខថ្មីមួយ ដែលវិទ្យាស្ថានជួបប្រទះក្នុងតំណាក់កាលស្តារ និងចងក្រងឡើងវិញនូវវប្បធម៌ខ្មែរ ហើយនិងធ្វើការស្រាវជ្រាវថ្មីៗ ក្នុងប្រទេសកម្ពុជាដែលកំពុងវិវឌ្ឍន៍ចូលក្នុងសាកលលោក។



អគារពុទ្ធសាសនបណ្ឌិត្យបច្ចុប្បន្ន

បច្ចុប្បន្ននេះ វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យបានដាក់ចេញនូវកាតព្វកិច្ច និងទិសដៅធំៗមួយចំនួនសំដៅ ស្តារឡើងវិញ នូវតួនាទីពីអតីតកាល ក៏ដូចជាដើម្បីលើកស្ទួយនូវការសិក្សា ចងក្រង និងថែរក្សានូវអត្តសញ្ញាណវប្បធម៌របស់ខេមរជនទូទៅដែរ។ ទិសដៅសំខាន់ៗទាំងនោះរួមមាន កសាងឡើងវិញដោយឈរលើតួនាទីអតីតរបស់

វិទ្យាស្ថាន ដែលធ្លាប់ជាមជ្ឈមណ្ឌលជាតិ សំរាប់ការសិក្សា ស្រាវជ្រាវ ប្រមូលចងក្រងឯកសារ និងចែកផ្សាយចំណេះដឹង តាមរយៈការស្រាវជ្រាវបែប វិទ្យាសាស្ត្រ និងឯករាជ្យ។ លើសពីនេះ វិទ្យាស្ថានប្រឹងប្រែងនឹងធ្វើកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នស្រាវជ្រាវដទៃ ក្នុងបំណងផ្លាស់ប្តូរគំនិត និងបទពិសោធន៍គ្នាទៅវិញទៅមក និងផ្សព្វផ្សាយលទ្ធផលស្រាវជ្រាវ ដើម្បីជំរុញឱ្យមានការពង្រឹង និងអភិវឌ្ឍន៍ការយល់ដឹងជាសាធារណៈ ដើម្បីលើកទឹកចិត្តឱ្យមានការថែរក្សាអត្តសញ្ញាណជាតិ។ ទិសដៅទាំងនេះអាចសំរេចទៅបានក៏ត្រូវទាមទារឱ្យមានការស្វះស្វែងរកប្រភពចំណូល ដើម្បីទ្រទ្រង់សកម្មភាពស្រាវជ្រាវ និងការផ្សព្វផ្សាយ។

ក្នុងបំណងឱ្យកិច្ចការទាំងនេះសំរេចបានទៅដោយរលូននោះ វិទ្យាស្ថានក៏បានបង្កើតជាថ្មីម្តងទៀតនូវក្រុមជំនុំស្រាវជ្រាវជាប្រវត្តិសាស្ត្រទាំងពីររបស់ខ្លួនផងដែរ។ ក្រុមជំនុំព្រះត្រៃបិដកកំពុងបន្តគោលបំណង និងការងាររបស់ខ្លួនយ៉ាងសកម្ម ដោយក្នុងនោះរួមទាំងការបន្តការបកប្រែដីកា និងអដ្ឋកថាពីភាសាបាលីមកជា ភាសាខ្មែរ ធ្វើការបោះពុម្ភវចនានុក្រមខ្មែរ-បាលី និងធ្វើពិធីសន្ទនាធម៌ប្រចាំសប្តាហ៍។

ដូចគ្នានេះដែរ ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ កំពុងនឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការស្រាវជ្រាវ និងអភិរក្ស ដើម្បីសំរេចឱ្យបាននូវគោលបំណង និងសកម្មភាពពិសេសៗ រួមមានការថែរក្សាការពារសាស្ត្រាស្លឹករឹតក្នុងប្រទេសកម្ពុជា ការស្រាវជ្រាវដល់ទីកន្លែង ចងក្រង និងការពារប្រពៃណី និងទំនៀមទម្លាប់ខ្មែរ ការចងក្រងស្នាដៃដែលពាក់ព័ន្ធដើម្បីផ្សព្វផ្សាយតាមរយៈប្រព័ន្ធផ្សព្វផ្សាយនានា និងតាមរយៈទស្សនាវដ្តីកម្ពុជសុរិយា និងការបង្កើតក្រុមបកប្រែមួយដើម្បីបកប្រែអត្ថបទសំខាន់ៗ ស្តីអំពីពុទ្ធសាសនា ទំនៀមទម្លាប់ និងប្រពៃណីពីភាសាបរទេសមកជាភាសាខ្មែរ។

ក្រៅពីរក្សានូវធាតុសំខាន់ៗដែលមានពីអតីតកាលទាំងនេះ ពុទ្ធសាសនបណ្ឌិត្យមានភាពបត់បែនយ៉ាងឿនឆ្លើយតបទៅនឹងការប្រឈមមុខផ្នែកបញ្ហាក្នុងសម័យថ្មីនេះ។ ក្រុមជំនុំទាំងពីរត្រូវបានបង្កើតឡើងតាំងពីសម័យអាណានិគមមកដល់ពេលនេះគឺមានរយៈពេលជាង៧០ឆ្នាំហើយ។ បន្តមកទៀត តួនាទីចម្បងរបស់ព្រះសង្ឃនិយមការកែទំរង់ និងអ្នកផ្តួចផ្តើម ក៏ដូចអ្នកគាំទ្រវិទ្យាស្ថានជាជនជាតិបារាំង គឺត្រូវបង្កើតឱ្យមានព្រះពុទ្ធសាសនាដោយឡែកមួយដែលខុសពីសាសនារបស់សៀម និងបង្កើតឱ្យមានការប្រមូលផ្តុំផ្នែកអក្សរសាស្ត្រខ្មែរក្នុងគោលបំណង លើកស្ទួយព្រះពុទ្ធសាសនា និងរួមចំណែកដល់ការអប់រំសីលធម៌ជាសាធារណៈ។ ស្ថាបនាឡើងដើម្បីបន្សាត់បង់ឱ្យអស់នូវការសាបរលាបផ្នែកព្រះពុទ្ធសាសនា ពុទ្ធសាសនបណ្ឌិត្យ ពេលបង្កើតឡើងវិញនៅឆ្នាំ ១៩៩២ ត្រូវប្រឈមមុខមិនត្រឹមតែការកសាងខ្លួនឯងឡើងវិញប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងត្រូវស្តារឡើងវិញនូវព្រះពុទ្ធសាសនា និងវប្បធម៌ ដែលជួបប្រទះនូវបញ្ហាថ្មីៗមួយចំនួនខុសពីពេលមុនមានដូចជា សង្គ្រាម បដិវត្តន៍

ការបំផ្លិចបំផ្លាញ និងការគៀបសង្កត់ជាដើម ។

រយៈពេលជាងមួយទសវត្សរ៍ចុងក្រោយនេះ ចលនាសាកលភាវូបនីយកម្មដ៏រហ័សបាននាំមកនូវបញ្ហាសង្គម និងឧបសគ្គថ្មីៗចំពោះវប្បធម៌ជាច្រើនមកក្នុងប្រទេសកម្ពុជា ។ ក្នុងបំណងកសាងឡើងវិញនូវកេរ្តិ៍ឈ្មោះពីអតីតរបស់វិទ្យាស្ថាន យើងមានការបារម្ភថា ការយកចិត្តទុកដាក់ច្រើនពេកលើរចនាសម្ព័ន្ធស្ថាប័ន អាចធ្វើឱ្យមានការរាំងស្ទះដល់ការតំរង់ទិសផ្នែកស្រាវជ្រាវក្នុងពេលបច្ចុប្បន្ននេះ ។ សំរាប់ជាការឆ្លើយតបទៅនឹងទិដ្ឋភាពដែលកំពុងផ្លាស់ប្តូរ និងសំណូមពរពីមូលនិធិហេនរិចបូល ដែលជាម្ចាស់ជំនួយធំ ពុទ្ធសាសនបណ្ឌិត្យនៅឆ្នាំ២០០៤ បានបង្កើតឡើងនូវរចនាសម្ព័ន្ធទីបីជាផ្លូវការមួយគឺគណៈកម្មការស្រាវជ្រាវ ដើម្បីផ្តល់ការវាយតំលៃ និងមគ្គុទ្ទេសក៏ឯករាជ្យលើទិសដៅស្រាវជ្រាវរបស់វិទ្យាស្ថាន ក៏ដូចជាគម្រោងស្រាវជ្រាវផ្សេងៗដែរ ។ ចាប់តាំងពីឆ្នាំ ២០០៤ មកគម្រោងស្រាវជ្រាវចំនួន៥ត្រូវបានដំណើរការ ដោយក្នុងនោះគម្រោងនីមួយៗមានការចូលរួមពីមន្ត្រីចាស់ និងនិស្សិតថ្នាក់បរិញ្ញាប័ត្រជាន់ខ្ពស់ដែលទើបបណ្តុះបណ្តាល ។ ប្រធានបទទាំងនេះរួមមាន យេនឌ័រ និងព្រះពុទ្ធសាសនាផលប៉ះពាល់នៃសាកលភាវូបនីយកម្មលើការព្យាបាលបែបបុរាណ ការផ្សៀងផ្ទាត់ និងវិភាគលើរឿងព្រេង ដែលទិទានសព្វថ្ងៃ និងប្រវត្តិព្រះពុទ្ធសាសនាក្នុងប្រទេសខ្មែរនៅសតវត្សរ៍ទី២០ ដែលនឹងបន្តពីការបោះពុម្ពនេះ ។

ដូចដែលបានបង្ហាញរួចមកហើយ ពុទ្ធសាសនបណ្ឌិត្យ មិនធ្លាប់ជាស្ថាប័នស្រាវជ្រាវជាន់ខ្ពស់នោះទេ ។ ប្រការមួយ ដែលបង្ហាញអំពីការបង្កើតឡើងវិញនូវតួនាទីពីមុនក្នុងឋានៈជាមជ្ឈមណ្ឌលនៃការសិក្សាអំពីវប្បធម៌គឺការបង្កើតការិយាល័យសមាគមអក្សរសិល្ប៍ទូហាច ក្នុងខែ ឧសភា ឆ្នាំ២០០៥ និងក្លឹបយុវជនស្ម័គ្រចិត្តដែលមានសកម្មភាពមមាញឹក ។ វេទិកាទាំងពីរនេះបានផ្តល់មកនូវការជួបជុំផ្លោះប្តូរគំនិតរវាងមនុស្សគ្រប់ជំនាន់ និងឆ្លងទ្វីបទៀតផង ។ ដូច្នេះ យើងអាចឃើញអំពីគន្លងប្រវត្តិសាស្ត្រថា ផ្នែកទាំងពីរនេះជាការបំពងសំលេងបន្តពីវត្តមានរបស់អ្នកនិពន្ធ គីម ហាក់ និង ញ៉ុក ថែម និងយុវសាលា ដែលត្រូវបង្កើតឡើងដោយព្រះរាជបណ្ណាល័យនៅចុងទសវត្សរ៍ ១៩៣០ ។ ក្នុងបំណងលើកឡើងអំពីការបន្ត និងខ្សែប្រវត្តិសាស្ត្រ និងបុគ្គលមួយចំនួនព្រមទាំងគោលនយោបាយដែលបានកំណត់នូវជោគវាសនារបស់វិទ្យាស្ថានក្នុងពេលកន្លងមក គម្រោងស្រាវជ្រាវប្រវត្តិសាស្ត្រនេះសង្ឃឹមថានឹងស្តារឡើងវិញនូវខ្លឹមសារសំខាន់ ក្នុងការបន្តវេនផ្នែកបញ្ញាញាណ និងបង្ហាញនូវទស្សនវិស័យដែលមានស្រាប់ដែលអាចជួយកំណត់នូវអនាគតរបស់វិទ្យាស្ថាន ។

# សេចក្តីសន្និដ្ឋាន

ក្នុងរយៈពេល៧៥ឆ្នាំមកនេះ ពុទ្ធសាសនបណ្ឌិត្យ បានកសាងនូវសមិទ្ធិផលដ៏ច្រើន ក្នុងភារៈខ្លួនជាអ្នកដឹកនាំផ្សព្វផ្សាយសាសនា និងសិក្សាអំពីអក្សរសាស្ត្រជាតិ។ ចាប់តាំងពីការកកើតនៅឆ្នាំ១៩៣០មក ពុទ្ធសាសនបណ្ឌិត្យ បានបំពេញនូវតួនាទីរបស់ខ្លួនយ៉ាងសកម្មខាងផ្នែកវប្បធម៌ ដោយមានការចូលរួមពីស្ថាប័នពាក់ព័ន្ធដទៃទៀតមានសាលាបាលីជាន់ខ្ពស់ និងព្រះរាជបណ្ណាល័យ។ ស្ថាប័នទាំងនេះ ដើមឡើយស្ថិតក្រោមការគ្រប់គ្រងដោយឡែកពីគ្នា ប៉ុន្តែក្រោយមកត្រូវស្ថិតនៅក្រោមការចាត់ចែងរបស់ពុទ្ធសាសនបណ្ឌិត្យ។

ដោយត្រូវបានបង្កើតឡើងក្រោមការយល់ព្រមរបស់រាជរដ្ឋាភិបាលបារាំង ពុទ្ធសាសនបណ្ឌិត្យ មានភារៈធ្វើការស្រាវជ្រាវផ្នែកពុទ្ធសាសនានិកាយថេរវាទ ក្នុងចំណោមជនជាតិនៅដែនឥណ្ឌូចិនទាំងមូល។ គ្រឹះស្ថាននេះត្រូវធ្វើការគ្រប់គ្រងលើការចាត់ចែងបោះពុម្ពព្រះត្រៃបិដក និងជួយមើលការខុសត្រូវ លើការបង្រៀនព្រះត្រៃបិដកដែលជាអាជ្ញាធររបស់សាលាបាលីជាន់ខ្ពស់។ ថ្នាលបណ្តុះបណ្តាលព្រះសង្ឃ ខាងគម្ពីរព្រះបរិយត្តិធម៌ និងភាសាបាលីសំស្ក្រឹតនេះ បានបង្កើតនៅទីក្រុងភ្នំពេញតាំងពីឆ្នាំ១៩១៤ ក្នុងបំណងរាំងខ្ទប់មិនឱ្យព្រះសង្ឃទៅសិក្សានៅប្រទេសសៀម។ ចំណែក ព្រះរាជបណ្ណាល័យ ទីដ្ឋានសំរាប់រក្សា និងប្រមូលនូវរាល់វត្ថុទាំងឡាយដែលទាក់ទងនឹងពុទ្ធសាសនា ដែលមានអ្នកដឹកនាំរួមជាបុគ្គលិកមកពីសាលាបារាំងចុងបូព៌ាជាមួយនឹងពុទ្ធសាសនបណ្ឌិត្យ បានរួមចំណែកយ៉ាងសកម្មក្នុងការអភិរក្សសម្បត្តិវប្បធម៌ និងផ្សព្វផ្សាយព្រះពុទ្ធសាសនា និងអក្សរសាស្ត្រជាតិ។ សម័យនោះ ស្ថាប័ននេះបានក្លាយជាកន្លែងប្រមូលផ្តុំនូវបញ្ញវន្តខ្មែរ ទាំងព្រះសង្ឃ ទាំងគ្រហស្ថ ដែលជាហេតុធ្វើឱ្យការរួមចំណែករក្សានូវវប្បធម៌ប្រពៃណីជាតិកាន់តែមានកិត្តិស័ព្ទល្បីល្បាញ និងស្ថិតក្រោមការត្រួតពិនិត្យ អង្កេតពីអាណាព្យាបាលបារាំង។

ការចែកផ្សាយនូវចំណេះដឹងអំពីខេមរជនទាំងឡាយ ត្រូវធ្វើឡើងតាមរយៈការប្រមូលចងក្រង បោះពុម្ព និងចែកផ្សាយទៅវិញតាមរយៈការលក់ និងមធ្យោបាយផ្សព្វផ្សាយដទៃទៀត។ ក្នុងនោះទស្សនាវដ្តី កម្ពុជសុរិយា ដែលបោះពុម្ពឡើងដោយស្ថាប័ននេះ បានធ្វើការផ្សព្វផ្សាយជាអត្ថបទខាងគតិលោក គតិធម៌។ ចំណែកព្រឹត្តិបត្រមួយទៀតឈ្មោះថាសាសនាកិច្ចានុក្រម ក៏មានរួមចំណែកផ្សព្វផ្សាយខាងពតិមានទាក់ទងនឹងពុទ្ធសាសនាមួយរយៈពេលដែរ។ ក្រៅពីនេះក៏មានការលក់សៀវភៅគ្រប់ប្រភេទដល់ប្រជាជនទូទាំងដែនឥណ្ឌូចិន តាមរយៈបណ្ណាល័យចល័តរបស់ពុទ្ធសាសនបណ្ឌិត្យផងដែរ។ កិច្ចការទាំងនេះបានធ្វើឱ្យ ពុទ្ធសាសនបណ្ឌិត្យ មានប្រជាប្រិយភាពយ៉ាងខ្លាំងក្នុងស្រទាប់ប្រជាជនគ្រប់ជាន់ថ្នាក់។

ក្រៅពីកិច្ចខាងផ្នែកអក្សរសាស្ត្រ និងសាសនា ពុទ្ធសាសនបណ្ឌិត្យ ក៏បានដើរតួធ្វើជាអ្នកអភិរក្សនូវកេរមរតកផ្នែកប្រពៃណីរបស់ខេមរជន ទាំងចាស់ ទាំងថ្មីផងដែរ។ ក្រុមជំនុំទំនៀមទម្លាប់ខ្មែរមួយត្រូវបានបង្កើត

ឡើងក្នុងបំណងប្រមូលចងក្រងនូវទំនៀមទម្លាប់ទាំងឡាយដែលទាក់ទងនឹងប្រជាជនខ្មែរ មានដូចជាជំនឿអរូបី រឿងព្រេង និងការប្រារព្ធពិធីដទៃទៀត។ ស្នាដៃខាងប្រពៃណីទាំងនេះត្រូវបានប្រមូលមក រក្សាទុក បោះពុម្ព និងចែកផ្សាយយ៉ាងទូលាយដល់សាធារណៈជន។ តួនាទីទាំងអស់នេះបានបន្តរហូតមកដល់សម័យឯករាជ្យ និងសម័យក្រោយៗទៀត លើកលែងពីចន្លោះដើមទសវត្សរ៍ឆ្នាំ ១៩៧០ និង ១៩៩០ ដែលជាសម័យសង្គ្រាមស៊ីវិល។ ក្រោយពីការរស់រានមានជីវិតឡើងវិញនៅឆ្នាំ១៩៩២ ពុទ្ធសាសនបណ្ឌិត្យបានខិតខំត្រដររស់រហូតមកដល់សព្វថ្ងៃនេះ ក្រោមការខិតខំរបស់ខ្លួនផ្ទាល់ និងជំនួយរបស់បណ្តាអង្គការនៃប្រទេសជាមិត្ត។ ស្របពេលជាមួយគ្នានេះ ការយកចិត្តទុកដាក់ទៅលើតួនាទីពីអតីតកាលរបស់ខ្លួន គឺជាកត្តាអត្ថិភាពដើម្បីលើកតម្កើងកិត្តិស័ព្ទរបស់ពុទ្ធសាសនបណ្ឌិត្យឡើងវិញ។ ដោយហេតុដូច្នេះហើយ ការសិក្សាទៅលើការវិវឌ្ឍ និងតួនាទីជាប្រវត្តិសាស្ត្រ ពិតជានឹងមានសារៈសំខាន់សំរាប់ដំណើរការរបស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យក្នុងពេលបច្ចុប្បន្ន និងអនាគត។

# ជីវប្រវត្តិ







# ជីវប្រវត្តិសង្ខេប
# បុគ្គលសំខាន់មួយចំនួនទាក់ទងនឹងពុទ្ធសាសនបណ្ឌិត្យ

## លោក គីម ហាក់ ឬនេង ហាក់ (១៩០៥-?)

ក្នុងឋានៈជាបុគ្គលិកព្រះរាជបណ្ណាល័យ លោក គីម ហាក់ ជាអ្នកនិពន្ធមិនចេះនឿយហត់មួយរូប ដែលបូជាសំរាប់អក្សរសាស្ត្រជាតិ ដូចដែលយើងអាចឃើញស្នាដៃរបស់លោកជាច្រើនចុះផ្សាយនៅក្នុងទស្សនាវដ្ដីកម្ពុជសុរិយា។ លោកបានបញ្ចប់ការសិក្សានៅសាលាបឋមសិក្សាជាន់ខ្ពស់ នៅអនុវិទ្យាល័យស៊ីសុវត្ថិ។ នៅក្នុងឆ្នាំ ១៩២៤ លោកបានធ្វើជាអភិបាលត្រួតពិនិត្យ (កុងត្រូលល័រ) ក្នុងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។ លោក គីម ហាក់ បានត្រូវតែងតាំងជាអភិរក្សរងព្រះរាជបណ្ណាល័យកម្ពុជា ជំនួសលោក សឹង ង៉ុកថាន់ ដែលត្រូវបានផ្ទេរទៅធ្វើជាតុលាការីនៅខេត្តពោធិសាត់។ នៅឆ្នាំ ១៩៤៣ តាមសេចក្ដីស្នើរសុំរបស់រដ្ឋាភិបាលខ្មែរ លោកបានផ្លាស់ទៅធ្វើការនៅ ក្រសួងអប់រំជាតិ ដើម្បីកាន់ការជានាយកការិយាល័យឃោសនា និងវិចិត្រសិល្បៈ ហើយពេលនោះ លោកក៏មានតួនាទីជាចាងហ្វាងសារពត៌មាន "កម្ពុជា" ផងដែរ។ នៅឆ្នាំ១៩៤៤-៤៥ លោកបានបំពេញនាទីជាអគ្គលេខាធិការនៃគណៈកម្មការវប្បធម៌ និងសមាគមអាយ៉ូនីញ៉េ។ ស្នាដៃសំខាន់មួយរបស់គាត់នោះគឺ ប្រលោមលោករឿង "ទឹកទន្លេសាប" ដែលបានបោះពុម្ពដោយព្រះរាជបណ្ណាល័យ ក្នុងទស្សនាវដ្ដី "កម្ពុជសុរិយា" ដែលក្រោយមកត្រូវបានគេចាត់ទុកថាជាស្នាដៃ ប្រលោមលោកដំបូងរបស់ខ្មែរ។



សម្ដេចព្រះសង្ឃរាជ ជួន ណាត

## សម្ដេចព្រះសង្ឃរាជ ជួន ណាត (១៨៨៣-១៩៦៩)

សម្ដេចជោតញ្ញាណោ ជួន ណាត បានដើរតួនាទីយ៉ាងសំខាន់ ក្នុងយុទ្ធនាការផ្សព្វផ្សាយសាសនា និងអក្សរសាស្ត្រជាតិ ក្នុងនោះសម្ដេចបានផ្សាយនូវសៀវភៅក្បួនខ្នាតជាច្រើន ទាំងខាងគតិធម៌ ទាំងខាងគតិលោក ជាភាសាជាតិ ដើម្បីជំរុញឱ្យមានការរៀបចំព្រះសង្ឃគណៈមហានិកាយ និងអក្សរសាស្ត្រ។ លោកបានប្រលងជាប់ជាសាស្ត្រាចារ្យនៅសាលាបាលីជាន់ខ្ពស់ក្នុងឆ្នាំ១៩១៥។ ហើយចាប់ពីឆ្នាំ១៩១៩មក លោកត្រូវបានជ្រើសរើសឱ្យធ្វើជាសមាជិកនៃគណៈកម្មការបង្កើតវចនានុក្រមខ្មែរ។ នៅក្នុងឆ្នាំ ១៩២២ - ២៣ លោកបាននិមន្តទៅរៀនភាសាសំស្ក្រឹត

និងសិលាចារឹកខ្មែរនៅទីក្រុងហាណូយ ក្រោមការអនុញ្ញាតរបស់ចាងហ្វាងសាលាបារាំងចុងបូព៌ា។ លោកត្រូវបានតែងតាំងជា ចាងហ្វាងរងនៃសាលាបាលីជាន់ខ្ពស់ ក្នុងឆ្នាំ១៩៣០ ។ក្នុងឆ្នាំដដែលនោះដែរ លោកបានទទួលខុសត្រូវក្នុងការកែវចនានុក្រមខ្មែរឱ្យចប់សព្វគ្រប់ដើម្បីធ្វើការបោះពុម្ពជាលើកដំបូង។ នៅឆ្នាំ១៩៤៤ លោកត្រូវបានតែងតាំងជាចៅអធិការវត្តឧណ្ណាលោម និងជាអធិបតីនៃថេរសភាក្នុងឆ្នាំបន្ទាប់។ ឆ្នាំ ១៩៤៧ លោកបាន ក្លាយទៅជាចាងហ្វាងរងនៃគណៈកម្មការវប្បធម៌ ហើយនៅឆ្នាំ១៩៤៨ លោកបានត្រូវតែងតាំងជាព្រះមហាសុមេធាធិបតីសង្ឃរាជគណៈមហានិកាយបណ្តោះអាសន្ន និងពេញសិទ្ធិនៅឆ្នាំ១៩៥០។ នៅពេលដឹកនាំគណៈប្រតិភូទៅចូលរួមសង្គាយនាក្នុងឆ្នាំ១៩៥៤ លោកត្រូវបានផ្តល់នាមឱ្យថាជា ព្រះ"អគ្គមហាបណ្ឌិត" និងនៅឆ្នាំ ១៩៥៧ នាមជា "អភិធជមហារដ្ឋគុរុ" ពីសហភាពភូមា។ ដល់ឆ្នាំ១៩៦៤ លោកបានទទួលឋានៈជា ព្រះអគ្គនិពន្ធអក្សរសាស្ត្រខ្មែរ និងជាសមាជិកកិត្តិយសរបស់សមាគមអ្នកនិពន្ធខ្មែរ។ សម្តេចព្រះបាទនរោត្តម សីហនុ ព្រះប្រមុខរដ្ឋបានប្រទានដល់សម្តេច នូវឋានៈជាសម្តេចព្រះសង្ឃរាជថ្នាក់ទី១ក្នុងឆ្នាំ១៩៦៣ និងសញ្ញាប័ត្រ បណ្ឌិតអក្សរសាស្ត្រ ក្នុងនាមមហាវិទ្យាល័យអក្សរសាស្ត្រ និងមនុស្សសាស្ត្រនៅឆ្នាំ១៩៦៧។


លោក ជួន ណុត និងភរិយា

## លោក ជួន ណុត

គាត់ជាប្អូនប្រុសរបស់សម្តេចសង្ឃរាជ ជួន ណាត។ គាត់បានធ្វើការក្នុងមុខតំណែងជាអ្នកគិតលុយអស់រយៈពេល ១៣ឆ្នាំ នៅក្នុងព្រះរាជបណ្ណាល័យ ក្នុងសាលាបាលីជាន់ខ្ពស់ និងមន្ទីរពុទ្ធសាសនបណ្ឌិត្យ ហើយគាត់ក៏បានធ្វើការងារនៅក្នុងក្រុមជំនុំព្រះត្រៃបិដកតាំងពីពេលបង្កើតដំបូងមកដែរ។ នៅពេលកញ្ញា ការប៊ីឡែសអញ្ជើញទៅកាន់ខេត្តត្រាវិញ ពីថ្ងៃទី១៧ ទៅដល់ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ១៩៣៩ លោកបានកាន់កាប់ពុទ្ធសាសនបណ្ឌិត្យជំនួស។

បណ្ណាល័យ LIBRARY BUDDHIST INSTITUTE

## លោក ង៉ុំ ម៉ៅ (១៩០០-១៩៤៤)

លោកបានសិក្សានៅសាលាអនុវិទ្យាល័យស៊ីសុវត្ថិបាន១ឆ្នាំ ហើយក៏ឈប់រៀនដើម្បីប្រលងចូលសាលាច្បាប់ជាមួយ និងអ្នកអង្គម្ចាស់សិង្ហរា ក្នុងឆ្នាំ១៩១៩ និងប្រលងចេញនៅឆ្នាំ១៩២១ ភ្លាមនោះ ក៏ត្រូវចាត់ឱ្យធ្វើជាស្មៀននៅខេត្តស្ទឹងត្រែង។ នៅឆ្នាំ១៩២៣ លោកបានផ្លាស់មកធ្វើការនៅសាលាឃុនភ្នំពេញរួចទើបផ្លាស់ទៅសាលាក្រុមចោទ។ ក្រោយពីនោះមក លោកបានប្រលងជាប់ជាទីក្រមការនៅឆ្នាំ១៩២៦។ ពេលកញ្ញាការប៉ុឡែសឃើញលោកចេះជ្រៅជ្រះខាងអក្សរសាស្ត្រខ្មែរ ក៏សុំឱ្យផ្លាស់ទៅធ្វើការក្រៅតំណែងនៅទី ព្រះរាជបណ្ណាល័យ រហូតដល់ឆ្នាំ១៩៣៤។ នៅទីនោះ លោកបានធ្វើការនៅក្នុងក្រុមជំនុំវចនានុក្រមខ្មែរ។ លោកបានទទួលភារៈជាលេខានុការនៃក្រុមជំនុំព្រះត្រៃបិដកចាត់ការបោះពុម្ព ព្រះត្រៃបិដក ទៀតផង។ បន្ទាប់មកបានកាន់កាប់ខាងទស្សនាវដ្ដីកម្ពុជសុរិយា។ លោកជាមនុស្សមានសមត្ថភាពណាស់ ដោយគាត់ចេះអក្សរ ភាសាខ្មែរ បារាំង លាវ និងសៀម។ លោកបានតែង និងប្រែរឿងរ៉ាវជាច្រើន ចុះនៅក្នុងទស្សនាវដ្ដីកម្ពុជសុរិយាទៀតផង។

បន្ទាប់ពីឆ្នាំ១៩៣៤ មកគាត់បានឈប់ធ្វើការនៅពុទ្ធសាសនបណ្ឌិត្យ ហើយទៅធ្វើការងារជាច្រើនទៀតដូចជាចៅហ្វាយស្រុក រលាប្អៀរ ខេត្តកំពង់ឆ្នាំង ជាភូឈួយសម្ដេច ចៅវាំងជូន នៅព្រះបរមរាជវាំងក្នុងរាជ្យព្រះករុណាខត្តិយកោដ្ឋ ឋានន្តរជាឧកញ៉ា ប្រសើរសូរ្យសក្តិ ចៅហ្វាយស្រុកបាកាន ខេត្តពោធិសាត់ ជាចៅហ្វាយស្រុកស្វាយទាប ខេត្តស្វាយរៀង។ ក្រោយបំផុត លោកបានឡើងថ្នាក់ជាអនុមន្ត្រីលេខ៣ត្រូវផ្លាស់ពីស្រុកស្វាយទាបមកធ្វើការនៅទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចក្នុងឆ្នាំ១៩៤៤។

## ព្រះមហាពិទូរ ឈឹម ក្រសេម

លោក ឈឹម ក្រសេម ធ្វើការនៅព្រះរាជបណ្ណាល័យអស់រយៈពេល១២ឆ្នាំ។ ដោយហេតុថាលោកមានចំណេះដឹងខាងភាសាសៀម លោកបានប្រែរឿងមួយចំនួនបោះពុម្ពនៅកម្ពុជសុរិយា។ ក្រៅពីនេះលោកបានសរសេរអំពីប្រវត្តិព្រះពុទ្ធសាសនានៅដែនសុវណ្ណភូមិ សាសនា ទំនៀមទម្លាប់ជាដើម ដើម្បីធ្វើការចុះផ្សាយ។



លោក ញ៉ុក ថែម

## លោក ញ៉ុក ថែម (១៩០៣-១៩៧៤)

ញ៉ុក ថែម គឺជាអ្នកនិពន្ធដែលបានបន្សល់ទុកនូវស្នាដៃយ៉ាងច្រើន ពិសេសនោះគឺប្រលោមលោករឿងកូលាបប៉ៃលិន និងថែមទាំងបានចុះផ្សាយអត្ថបទមួយចំនួនធំក្នុងកម្ពុជសុរិយាផងដែរ។ ដោយលោកមានចំណេះដឹងច្រើន ទាំងអក្សរសាស្ត្រជាតិ និងភាសាបរទេស លោក ញ៉ុក ថែម បានបំពេញនាទីសំខាន់ៗជាច្រើនក្នុងការរៀបចំព្រះត្រៃបិដក ក៏ដូចជាអភិវឌ្ឍនភាពនៃវិស័យអក្សរសាស្ត្រជាតិ។ ពេលមានអាយុ១៦ឆ្នាំ លោកបានបន្តវិជ្ជាព្រះពុទ្ធសាសនានៅបាងកករហូតដល់ឆ្នាំ១៩៣០ បានត្រឡប់មកមាតុភូមិវិញ និងបានចូលបំរើការងារនៅក្រុមជំនុំបកប្រែព្រះត្រៃបិដកក្រោមអធិបតីព្រះធម្មលិខិត ល្វី ឯម។ លោកបាន ក្លាយជានិពន្ធនាយកទស្សនាវដ្ដីកម្ពុជសុរិយានៅព្រះរាជបណ្ណាល័យក្នុងឆ្នាំ១៩៣៨។

ដើមខែកុម្ភៈ ឆ្នាំ១៩៣៩ រាជការបានចាត់ឱ្យធ្វើព្រះរាជតំណាងសម្ដេចព្រះរាជអយ្យកោនរោត្តម សុធារស ព្រះអធិបតីនៃពុទ្ធសាសនបណ្ឌិត្យកម្ពុជា។ ឆ្នាំ១៩៤៣ លោកធ្វើជាតំណាងឱ្យអគ្គលេខាធិការ ព្យែរ ឌុយប៉ង់តី ដើម្បីរៀបចំកម្មវិធីសិក្សាភាសាបាលី និងរៀបចំបង្កើតពុទ្ធសាសនបណ្ឌិត្យនៅខេត្តប៉ាក់សេប្រទេសលាវ។ ឆ្នាំបន្ទាប់មក លោកបានទទួលនាទីជាអ្នកការទូតប្រចាំសហភាពឥណ្ឌូចិន ក្នុងឋានៈជាអ្នកបកប្រែផ្សព្វផ្សាយតាមវិទ្យុពីភាសាបារាំង មកភាសាថៃ និងខ្មែរ។

ខែមករា ឆ្នាំ១៩៤៧ ក្រសួងអប់រំជាតិបានតែងតាំងលោកជាសមាជិកនៃគណៈកម្មការវប្បធម៌ ហើយលោកបានសុំលាឈប់ពីពុទ្ធសាសនបណ្ឌិត្យនៅចុងឆ្នាំ១៩៤៩។ បន្ទាប់ពីនោះមក លោក ញ៉ុក ថែម បានបន្តធ្វើជាសាស្ត្រាចារ្យជាប់កិច្ចសន្យារហូតដល់ឆ្នាំ១៩៥៦។ លោកក៏ជាស្ថាបនិកមួយរូបនៃសមាគមអ្នកនិពន្ធខ្មែរដែលបានបង្កើតឡើងក្នុងឆ្នាំ១៩៥៥។ ក្នុងចន្លោះឆ្នាំ១៩៥៦-១៩៥៧ លោកផ្លាស់ទៅធ្វើការនៅវិទ្យាល័យព្រះមុនីវង្សនាក្រុងបាត់ដំបង ប៉ុន្តែនៅឆ្នាំ១៩៥៨ត្រូវត្រឡប់មកធ្វើការនៅវិទ្យាស្ថានជាតិគរុកោសល្យ តាមសេចក្ដីស្នើរសុំពីក្រសួងអប់រំជាតិវិញ។

## ព្រះមហាវិមលធម្ម ថោង (១៨៦២-១៩២៧)

ព្រះមហាវិមលធម្ម ថោង បានដើរតួនាទីយ៉ាងសំខាន់ក្នុងការរៀបចំព្រះពុទ្ធសាសនា និងជំរុញឱ្យមាន

ការប្រតិបត្តិពុទ្ធវចនៈតាមរយៈការអប់រំព្រះសង្ឃ។ នៅក្នុងឆ្នាំ១៩១៤ ព្រះអង្គត្រូវបានតែងតាំងជាចាងហ្វាងទី១នៃសាលាបាលីនៅក្នុងទីក្រុងភ្នំពេញ ដោយព្រះមហាក្សត្រព្រះបាទស៊ីសុវត្ថិ និងមានការយល់ព្រមពីរដ្ឋាភិបាលអាណាព្យាបាល។ បន្ទាប់មកទៀត លោកត្រូវតែម្លើងតំណែងជា ក្រុមជំនុំវចនានុក្រមខ្មែរ។ ព្រះមហាវិមលធម្ម ថោង ជាអ្នកមានចំណេះដឹងផ្នែកភាសាច្រើនរួមមាន ភាសាបាលី ភាសាថៃ ភាសាឡាវ ហើយលោកអាចអានអក្សរភូមា និងស្រីលង្កាបានទៀតផង។ លោកមានឧបការៈខ្ពង់ខ្ពស់ណាស់ ក្នុងការជួយជំរុញឱ្យព្រះពុទ្ធសាសនាបានរីកចំរើន ដូចជានៅពេលដែលប្រទេសខ្មែរពុំទាន់មានឯកសារសិក្សាច្រើននោះ លោកបានធ្វើដំណើរទៅជាវសាស្ត្រាព្រះត្រៃបិដកបាលីអក្សរខ្មែរ (តួអក្សរខមដែលគេសរសេរជាភាសាបាលីនៅសម័យនោះ) នៅប្រទេសថៃ ដើម្បីឱ្យកូនសិស្សបានសិក្សារៀនសូត្រ។ លោកទទួលបាននូវការគោរពយ៉ាងខ្ពង់ខ្ពស់អំពីព្រះសង្ឃ និងគ្រហស្ថ ដែលជាជនជាតិខ្មែរ និងបរទេស។ ក្នុងនោះព្រះសង្ឃដែលមានឋានៈ និងមានចំណេះចេះដឹងខ្ពស់រួមមាន ព្រះតេជគុណ ល្វី ឯម ព្រះតេជគុណ ជួន ណាត ព្រះតេជគុណ ហួត តាត ព្រះតេជគុណ ម៉ី ជាដើម ក៏ធ្លាប់ជាកូនសិស្សរបស់លោកដែរ។

## លោក ប៊ូជូ ឡាំង

លោកធ្លាប់ធ្វើជារ៉េស៊ីដង់ប្រចាំខេត្តកំពង់ចាម និងក្រោយមកក្លាយជារ៉េស៊ីដង់ជាន់ខ្ពស់នៅស្រុកខ្មែរ ក្នុងចន្លោះឆ្នាំ (១៩១៤-១៩២០)។ មនុស្សមួយចំនួនគិតថា លោកជាអ្នកដែលបានផ្តួចផ្តើមគំនិតក្នុងការបង្កើតព្រះរាជបណ្ណាល័យកម្ពុជា ហើយបានជួយទំនុកបំរុងយ៉ាងមាំមួនឥតអាក់ខានពីបឋមរៀងមក បានចំរើនដូចសេចក្តីប្រាថ្នានៅក្នុងព្រះរាជបណ្ណាល័យ។ បន្ទាប់មក លោកបានទទួលចូលនិវត្តន៍ត្រលប់ទៅស្រុកបារាំងវិញ និងបានត្រូវតែងតាំងជាអគ្គទេសាភិបាលកិត្តិយស។

## ព្រះតេជគុណ ប៉ាង ខាត់ (? - ១៩៧៦)

លោកជាព្រះសង្ឃដែលមានចំណេះដឹងមួយរូបដែរ។ លោកធ្លាប់ធ្វើឱ្យមានជាប្រយោជន៍ច្រើន កាលធ្វើការនៅសាលាបាលី ព្រោះលោកទទួលបាននូវចំណេះដឹងជ្រៅជ្រះខាងភាសាសំស្ក្រឹតពីក្រុងសាយហ្គន និងបានចូលធ្វើជាសមាជិក ក្រុមជំនុំព្រះត្រៃបិដក នៅក្នុងអំឡុងទសវត្សរ៍ទី៤០ ហើយលោកក៏ជាព្រះសង្ឃមួយអង្គដែលចូលរួមធ្វើបាតុកម្មដើម្បីទាមទារឱ្យមានការដោះលែងព្រះតេជគុណ ហែម ចៀវ ដែរ។ ក្រោយពីបាតុកម្មនេះ ព្រះគ្រូ ប៉ាង ខាត់ បានលាចាកព្រះផ្នួស ហើយបានចូលខ្លួនឱ្យគេចាប់ និងត្រូវបញ្ជូនទៅកាត់ទោសនៅ

កូសាំងស៊ីន ប៉ុន្តែដោយរកពុំឃើញថាមានទោសអ្វីនោះ ព្រះគ្រូក៏ត្រូវតែដោះលែងមកវិញ និងសុំបួសជាបព្វជិតជាថ្មីម្តងទៀតក្រោមការជួយជ្រោមជ្រែងពីលោកអគ្គលេខាធិការពុទ្ធសាសនបណ្ឌិត្យ ។ នៅក្នុងសម័យឯករាជ្យ លោកបានបង្រៀន ទស្សនវិជ្ជាពុទ្ធសាសនានៅមហាវិទ្យាល័យអក្សរសាស្ត្រ និងបានបោះពុម្ពនូវស្នាដៃមួយចំនួនទៀតផង ជាពិសេសគឺសៀវភៅស្រីហិតោបទេស ។ លោកត្រូវបានគេសំលាប់នៅក្នុងរបបខ្មែរក្រហម ។


លោក ប៉ាច ឈឿន

## លោក ប៉ាច ឈឿន (១៨៩៦-១៩៧១)

លោកជាពាណិជ្ជករ និងជាបញ្ញវន្តមួយរូប ដែលមានគំនិតស្នេហាជាតិខ្ពស់ និងបានចូលរួមចំណែកសំខាន់ក្នុងចលនាប្រឆាំងពួកអាណានិគម ។ លោក ប៉ាច ឈឿន នៅក្នុងអំឡុងពេលនៃសង្គ្រាមលោកលើកទីមួយ ដែលជាអ្នកបកប្រែឱ្យកងទ័ពខ្មែរបានធ្វើដំណើរទៅជួយច្បាំងបារាំងនៅអឺរ៉ុប ។ នៅពេលត្រលប់មកវិញ គាត់បានធ្វើការនៅក្នុងយានដ្ឋានមួយនៅទីក្រុងភ្នំពេញ ។ បន្ទាប់មក នៅឆ្នាំ១៩៣៦ គាត់ជាមួយលោក សឹង ង៉ុក ថាន់ បានបង្កើតជាកាសែតជាតិនិយមខ្មែរដំបូងបង្អស់ ដែលផ្សាយជាភាសាខ្មែរ ។ កាសែតរបស់គាត់ ដែលមាននាមថា "នគរវត្ត" បានជួយដាស់តឿនឱ្យខ្មែរចេះរកស៊ី ចេះខំប្រឹងប្រែងរៀនសូត្រ និងមានឧត្តមគតិស្នេហាជាតិ ។ ប៉ុន្តែដោយមានការយល់ឃើញថាកាសែតរបស់លោកមានចំនុចខ្លះចុះផ្សាយទៅបានប៉ះពាល់ដល់បារាំងនោះ ទើបពួកអាណានិគមបារាំងបានធ្វើការត្រៀបសង្កត់ ដោយមិនឱ្យមានការចុះផ្សាយចំនុចណា ដែលគេយល់ថាមិនល្អ ។ នៅក្នុងឆ្នាំ១៩៣៩ លោក ប៉ាច ឈឿន រួមទាំងលោក សឹង ង៉ុក ថាន់ និងបក្សពួកដទៃទៀត បានធ្វើដំណើរទៅកាន់ទីវត្តនានាដើម្បីជំរាបប្រជាជន អំពីការភ្ញាក់រលឹករបស់បញ្ញវន្តខ្មែរ និងទិតៀនឱ្យមានការប្រុងប្រយ័ត្នចំពោះការគ្រប់គ្រងរបស់បារាំង ។ លោកត្រូវបានចាប់ខ្លួនពីបទចោទប្រកាន់ថាបានដឹកនាំ ព្រះសង្ឃធ្វើបាតុកម្មដោះលែងអាចារ្យហែមចៀវ នៅក្នុងខែមិថុនា ឆ្នាំ១៩៤២ ។ ដោយសារតួនាទីរបស់លោកក្នុងបាតុកម្ម កាសែត"នគរវត្ត" ត្រូវបានបិទទ្វារ ហើយគាត់ត្រូវបានបញ្ជូនទៅកាន់គុកធំនៅព្រៃនគរ បន្ទាប់មក ត្រូវបានគេកាត់ទោសប្រហារជីវិត ប៉ុន្តែបានត្រូវសម្រាលទោសត្រឹមជាប់គុកអស់មួយជីវិតនៅកោះត្រឡាច ។ លោកត្រូវបានដោះលែងវិញ នៅពេលដែលពួកជប៉ុនធ្វើពលប្រហារពួកបារាំងបានសំរេចនៅឆ្នាំ ១៩៤៥ និងត្រូវបានតែងតាំងជារដ្ឋមន្ត្រីសេដ្ឋកិច្ចនៅក្នុងខែ កក្កដា ប៉ុន្តែបានតែក្នុងរយៈពេលខ្លីប៉ុណ្ណោះ ព្រោះបារាំង និងក្រុមសម្ព័ន្ធមិត្តបានវាយឈ្នះលើពួកជប៉ុន ហើយបានគ្រប់គ្រងលើប្រទេសកម្ពុជាវិញ ។ នៅឆ្នាំ១៩៤៦ លោក

បានត្រូវចាប់ខ្លួនម្ដងទៀត (ឬក៏ចុះចូល) ហើយបានត្រូវគេនិរទេសទៅកាន់ប្រទេសបារាំង។ នៅពេលដែលត្រូវបានគេដោះលែងវិញនោះ លោកបានត្រលប់មកកាន់ប្រទេសកម្ពុជាវិញ ហើយទទួលការតែងតាំងជារដ្ឋមន្ត្រីក្រសួង ពត៌មាន នៅខែតុលា ឆ្នាំ១៩៥១។ លោកជាជនជាតិខ្មែរដំបូងបំផុតដែលមានសមត្ថភាពធ្វើជានាយក នៃបណ្ណាល័យជាតិ និងបណ្ណសារដ្ឋានជាតិ។

## លោក ប៊ូ ប៉ូ (១៩០១-១៩៧០)

លោក ប៊ូ ប៉ូ ត្រូវបានគេស្គាល់ថាជាបញ្ញវន្តមួយរូបបំរើការនៅពុទ្ធសាសនបណ្ឌិត្យ និងតែងមានសេចក្ដីព្យាយាមក្នុងការលើកស្ទួយអក្សរសាស្ត្រវប្បធម៌ជាតិ។ ភិក្ខុ ប៊ូ ប៉ូ បានប្រឡងជាប់សញ្ញាប័ត្រជា ព្រះមហាបរិយត្តិ នៅគ្រិស្តសករាជ១៩២៥។ នៅថ្ងៃទី១ ខែមករា ឆ្នាំ១៩៣០ ភិក្ខុ ប៊ូ ប៉ូ បានចូលមកបំរើការងារនៅក្រុមជំនុំព្រះត្រៃបិដក ជាដំបូងនៅព្រះរាជបណ្ណាល័យ។ បន្ទាប់មក លោកបានលាចាកសិក្ខាបទ ហើយបានរៀបអាពាហ៍ពិពាហ៍ជាមួយកញ្ញា ហ៊ុន សឹងអ៊ីម។ លោក ប៊ូ ប៉ូ ធ្វើការនៅក្រុមជុំនុំព្រះត្រៃបិដក ក្នុងចន្លោះឆ្នាំ ១៩៣០-១៩៤២ និងបានផ្លាស់មកកាន់ខាងបណ្ណាល័យវិញ ក្នុងចន្លោះឆ្នាំ ១៩៤៣-១៩៥៧។ ក្នុងរវាងឆ្នាំ ១៩៥៨-១៩៥៩ បន្ទាប់ពីលោកគ្រប់អាយុត្រូវចូលនិវត្តន៍ លោក ប៊ូ ប៉ូ បានបំរើការជាមន្ត្រីជាប់កិច្ចសន្យានៅពុទ្ធសាសនបណ្ឌិត្យ។

## លោក ព្យែរ ឌុយប៉ង់ត៍ (១៩០៨-១៩៥៥)

បន្ទាប់ពីកញ្ញា ស៊ុយសាន ការប៉ុឡែស លោក ព្យែរ ឌុយប៉ង់ត៍ ជាជនជាតិបារាំងដែលបំពេញនាទីជាអគ្គលេខាធិការពុទ្ធសាសនបណ្ឌិត្យក្នុងរយៈពេលយូរ និងខិតខំជំរុញឱ្យស្ថាប័ននេះមានដំណើរការដ៏គាប់ប្រសើរ។ លោកគឺជាអ្នកប្រាជ្ញម្នាក់ដែលមានចំណេះដឹង និងបានទទួលសញ្ញាប័ត្រក្នុងវិស័យជាច្រើន មានដូចជាខាងផ្នែកអក្សរសាស្ត្រ បុរាណវត្ថុវិទ្យាក្រិច សិល្បៈសម័យថ្មី នរវិទ្យា ចំណេះដឹងអំពីជនជាតិឥណ្ឌា សាសនាសាស្ត្រ។ ដោយបានទទួលការតែងតាំងនៅសាលាបារាំងដោយអារ៉ែតេចុះថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៣៦ គាត់បានធ្វើដំណើរមកសាយហ្គននៅថ្ងៃទី២៧ ខែមេសា ហើយបន្ទាប់មក បានមកស្នាក់នៅអង្គរវត្ត។ លោកបានទទួលកេរ្តិ៍ឈ្មោះខ្លាំងក្នុងវិស័យបុរាណវត្ថុវិទ្យា និងធ្លាប់បានធ្វើកំណាយជាច្រើននៅក្នុងប្រទេសថៃ និងឥណ្ឌូចិន។ ចាប់ពីខែសីហា ឆ្នាំ១៩៤១ លោកបានស្នាក់នៅទីក្រុងភ្នំពេញ។ ពេលនោះ លោកបានត្រូវតែងតាំងជាអគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យ។ ពីរឆ្នាំក្រោយមក លោកត្រូវបានគេបន្ថែមមុខងារមួយទៀត ជាអ្នកអភិរក្សប្រាសាទអង្គរ។

កូសាំងស៊ីន ប៉ុន្តែដោយរកពុំឃើញថាមានទោសអ្វីនោះ ព្រះគ្រូក៏ត្រូវតែដោះលែងមកវិញ និងសុំបួសជាបព្វជិតជាថ្មីម្តងទៀតក្រោមការជួយជ្រោមជ្រែងពីលោកអគ្គលេខាធិការពុទ្ធសាសនបណ្ឌិត្យ ។ នៅក្នុងសម័យឯករាជ្យ លោកបានបង្រៀន ទស្សនវិជ្ជាពុទ្ធសាសនានៅមហាវិទ្យាល័យអក្សរសាស្ត្រ និងបានបោះពុម្ពនូវស្នាដៃមួយចំនួនទៀតផងជាពិសេសគឺសៀវភៅស្រីហិតោបទេស ។ លោកត្រូវបានគេសំលាប់នៅក្នុងរបបខ្មែរក្រហម ។


លោក ប៉ាច ឈឿន

## លោក ប៉ាច ឈឿន (១៨៩៦-១៩៧១)

លោកជាពាណិជ្ជករ និងជាបញ្ញវន្តមួយរូប ដែលមានគំនិតស្នេហាជាតិខ្ពស់ និងបានចូលរួមចំណែកសំខាន់ក្នុងចលនាប្រឆាំងពួកអាណានិគម ។ លោក ប៉ាច ឈឿន នៅក្នុងអំឡុងពេលនៃសង្គ្រាមលោកលើកទីមួយ ដែលជាអ្នកបកប្រែឱ្យកងទ័ពខ្មែរបានធ្វើដំណើរទៅជួយច្បាំងបារាំងនៅអឺរ៉ុប ។ នៅពេលត្រលប់មកវិញ គាត់បានធ្វើការនៅក្នុងយានដ្ឋានមួយនៅទីក្រុងភ្នំពេញ ។ បន្ទាប់មក នៅឆ្នាំ១៩៣៦ គាត់ជាមួយលោក សឺង ង៉ុក ថាន់ បានបង្កើតជាកាសែតជាតិនិយមខ្មែរដំបូងបង្អស់ ដែលផ្សាយជាភាសាខ្មែរ ។ កាសែតរបស់គាត់ ដែលមាននាមថា "នគរវត្ត" បានជួយដាស់តឿនឱ្យខ្មែរចេះរកស៊ី ចេះខំប្រឹងប្រែងរៀនសូត្រ និងមានឧត្តមគតិស្នេហាជាតិ ។ ប៉ុន្តែដោយមានការយល់ឃើញថាកាសែតរបស់លោកមានចំនុចខ្លះចុះផ្សាយទៅបានប៉ះពាល់ដល់បារាំងនោះ ទើបពួកអាណានិគមបារាំងបានធ្វើការត្រៀបសង្កត់ ដោយមិនឱ្យមានការចុះផ្សាយចំនុចណា ដែលគេយល់ថាមិនល្អ ។ នៅក្នុងឆ្នាំ១៩៣៩ លោក ប៉ាច ឈឿន រួមទាំងលោក សឺង ង៉ុក ថាន់ និងបក្សពួកដទៃទៀត បានធ្វើដំណើរទៅកាន់ទីវត្តនានាដើម្បីជំរាបប្រជាជន អំពីការភ្ញាក់រលឹករបស់បញ្ញវន្តខ្មែរ និងទិតៀនឱ្យមានការប្រុងប្រយ័ត្នចំពោះការគ្រប់គ្រងរបស់បារាំង ។ លោកត្រូវបានចាប់ខ្លួនពីបទចោទប្រកាន់ថាបានដឹកនាំ ព្រះសង្ឃធ្វើបាតុកម្មដោះលែងអាចារ្យហែមចៀវ នៅក្នុងខែមិថុនា ឆ្នាំ១៩៤២ ។ ដោយសារតួនាទីរបស់លោកក្នុងបាតុកម្ម កាសែត"នគរវត្ត" ត្រូវបានបិទទ្វារ ហើយគាត់ត្រូវបានបញ្ជូនទៅកាន់គុកធំនៅព្រៃនគរ បន្ទាប់មក ត្រូវបានគេកាត់ទោសប្រហារជីវិត ប៉ុន្តែបានត្រូវសម្រាលទោសត្រឹមជាប់គុកអស់មួយជីវិតនៅកោះត្រឡាច ។ លោកត្រូវបានដោះលែងវិញ នៅពេលដែលពួកជប៉ុនធ្វើពលប្រហារពួកបារាំងបានសំរេចនៅឆ្នាំ១៩៤៥ និងត្រូវបានតែងតាំងជារដ្ឋមន្ត្រីសេដ្ឋកិច្ចនៅក្នុងខែ កក្កដា ប៉ុន្តែបានតែក្នុងរយៈពេលខ្លីប៉ុណ្ណោះ ព្រោះបារាំងនិងក្រុមសម្ព័ន្ធមិត្តបានវាយឈ្នះលើពួកជប៉ុន ហើយបានគ្រប់គ្រងលើប្រទេសកម្ពុជាវិញ ។ នៅឆ្នាំ១៩៤៦ លោក

បានត្រូវចាប់ខ្លួនម្តងទៀត (ឬក៏ចុះចូល) ហើយបានត្រូវគេនិរទេសទៅកាន់ប្រទេសបារាំង។ នៅពេលដែលត្រូវបានគេដោះលែងវិញនោះ លោកបានត្រលប់មកកាន់ប្រទេសកម្ពុជាវិញ ហើយទទួលការតែងតាំងជារដ្ឋមន្ត្រីក្រសួង ពត៌មាន នៅខែតុលា ឆ្នាំ១៩៥១។ លោកជាជនជាតិខ្មែរដំបូងបំផុតដែលមានសមត្ថភាពធ្វើជានាយក នៃបណ្ណាល័យជាតិ និងបណ្ណសារដ្ឋានជាតិ។

## លោក ប៊ូ ប៊ូ (១៩០១-១៩៧០)

លោក ប៊ូ ប៊ូ ត្រូវបានគេស្គាល់ថាជាបញ្ញវន្តមួយរូបបំរើការនៅពុទ្ធសាសនបណ្ឌិត្យ និងតែងមានសេចក្តីព្យាយាមក្នុងការលើកស្ទួយអក្សរសាស្ត្រវប្បធម៌ជាតិ។ ភិក្ខុ ប៊ូ ប៊ូ បានប្រឡងជាប់សញ្ញាប័ត្រជា ព្រះមហាបរិយត្តិ នៅគ្រឹស្តសករាជ១៩២៥។ នៅថ្ងៃទី១ ខែមករា ឆ្នាំ១៩៣០ ភិក្ខុ ប៊ូ ប៊ូ បានចូលមកបំរើការងារនៅក្រុមជំនុំព្រះត្រៃបិដក ជាដំបូងនៅព្រះរាជបណ្ណាល័យ។ បន្ទាប់មក លោកបានលាចាកសិក្ខាបទ ហើយបានរៀបអាពាហ៍ពិពាហ៍ជាមួយកញ្ញា ហ៊ុន សឹងអ៊ឹម ។ លោក ប៊ូ ប៊ូ ធ្វើការនៅក្រុមជុំនុំព្រះត្រៃបិដក ក្នុងចន្លោះឆ្នាំ ១៩៣០-១៩៤២ និងបានផ្លាស់មកកាន់ខាងបណ្ណាល័យវិញ ក្នុងចន្លោះឆ្នាំ ១៩៤៣-១៩៥៧។ ក្នុងរវាងឆ្នាំ ១៩៥៨-១៩៥៩ បន្ទាប់ពីលោកគ្រប់អាយុត្រូវចូលនិវត្តន៍ លោក ប៊ូ ប៊ូ បានបំរើការជាមន្ត្រីជាប់កិច្ចសន្យានៅពុទ្ធសាសនបណ្ឌិត្យ ។

## លោក ព្យែរ ឌុយប៉ុំត៍ (១៩០៨-១៩៥៥)

បន្ទាប់ពីកញ្ញា ស៊ុយសាន ការប៉ុឡែស លោក ព្យែរ ឌុយប៉ង់ត៍ ជាជនជាតិបារាំងដែលបំពេញនាទីជាអគ្គលេខាធិការពុទ្ធសាសនបណ្ឌិត្យក្នុងរយៈពេលយូរ និងខិតខំជំរុញឱ្យស្ថាប័ននេះមានដំណើរការដ៏គាប់ប្រសើរ។ លោកគឺជាអ្នកប្រាជ្ញម្នាក់ដែលមានចំណេះដឹង និងបានទទួលសញ្ញាប័ត្រក្នុងវិស័យជាច្រើន មានដូចជាខាងផ្នែកអក្សរសាស្ត្រ បុរាណវត្ថុវិទ្យាក្រិច សិល្បៈសម័យថ្មី នរវិទ្យា ចំណេះដឹងអំពីជនជាតិឥណ្ឌា សាសនាសាស្ត្រ។ ដោយបានទទួលការតែងតាំងនៅសាលាបារាំងដោយអាវ៉ែតេចុះថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៣៦ គាត់បានធ្វើដំណើរមកសាយហ្គននៅថ្ងៃទី២៧ ខែមេសា ហើយបន្ទាប់មក បានមកស្នាក់នៅអង្គរវត្ត។ លោកបានទទួលកេរ្តិ៍ឈ្មោះខ្លាំងក្នុងវិស័យបុរាណវត្ថុវិទ្យា និងធ្លាប់បានធ្វើកំណាយជាច្រើននៅក្នុងប្រទេសថៃ និងឥណ្ឌូចិន។ ចាប់ពីខែសីហា ឆ្នាំ១៩៤១ លោកបានស្នាក់នៅទីក្រុងភ្នំពេញ។ ពេលនោះ លោកបានត្រូវតែងតាំងជាអគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យ។ ពីរឆ្នាំក្រោយមក លោកត្រូវបានគេបន្ថែមមុខងារមួយទៀត ជាអ្នកអភិរក្សប្រាសាទអង្គរ។

លើសពីនេះទៀត នៅខែកុម្ភៈ ឆ្នាំ១៩៤៤ លោកបានទទួលតំណែង ជាអ្នកអភិរក្សសារមន្ទីរអាល់បែរសារ៉ូល៍។ នៅពេលជប៉ុនធ្វើពលប្រហារ បានជ័យជំនះនៅថ្ងៃទី៩ ខែមីនា ឆ្នាំ១៩៤៥ ជប៉ុនបានចេញអាវ៉ែតមួយ ដើម្បីដាក់ឃុំឃាំងលោក ព្យែរ ឌុយប៉ង់ត៍ និងបារាំងដទៃទៀតនៅទីក្រុងភ្នំពេញ។ ប៉ុន្តែក្រោយមក លោកត្រូវបានគេដោះលែង និងតែងតាំងដោយរដ្ឋាភិបាលថ្មី ជាទីប្រឹក្សាអមក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដែលលោកអាចមានសិទ្ធិគ្រប់គ្រងលើពុទ្ធសាសនបណ្ឌិត្យ និងធ្វើការអភិរក្សប្រាសាទខ្មែរបន្តទៅទៀតរហូតដល់ចុងឆ្នាំ១៩៤៦។

## ព្រះធម្មលិខិត ម៉ឹង សែស (១៨៩០-១៩៧០)

ព្រះធម្មលិខិតអង្គនេះ ក៏ល្បីល្បាញដោយសារតួនាទីរបស់លោកនៅក្នុងការចងក្រង និងបកប្រែព្រះត្រៃបិដកដែរ។ លោកបួសជាសាមណេរនៅអាយុ១៧ឆ្នាំ នៅវត្តម្ហូព្រៃ និងទទួលឧបសម្បទាជាភិក្ខុនៅវត្តដដែល។ ព្រះធម្មលិខិត ម៉ឹង សែស ត្រូវបានតែងតាំងជាសមាជិកនៃក្រុមជំនុំព្រះត្រៃបិដកនៅឆ្នាំ១៩៣១។ ឆ្នាំ១៩៤៤ លោកត្រូវបានតែងតាំងជាគ្រូសូត្រឆ្វេងនៅវត្តឧណ្ណាលោមដោយមាន សាមណស័ក្តិជា ព្រះទេពមុនី ហើយបានក្លាយជាចៅអធិការវត្តមហាមន្ត្រីនៅឆ្នាំដដែល និងបន្ទាប់មក ត្រូវបានតែងតាំងជាព្រះឧបលិវង្សជាក្រុមជំនុំសង្ឃថេរសភា ជាព្រះឃោសធម្ម ជាអធិបតីថេរសភា និងជាព្រះធម្មលិខិតនៅឆ្នាំ១៩៥៨។


លោក យឿន ចឹម

## លោក យឿន ចឹម (១៩០៩-១៩៧០)

លោក យឿន ចឹម ជាជាតិខេមរៈម្នាក់ដែលមានអំណត់ក្នុងការងារ និងបំពេញនាទីនៅទីពុទ្ធសាសនបណ្ឌិត្យក្នុងរយៈពេលយ៉ាងយូរ តាំងពីឋានៈទាបរហូតឡើងដល់នាទីជាអគ្គលេខាធិការ។ នៅអាយុ១៨ ឬ ១៩ ឆ្នាំ លោកបានប្រឡងចូលធ្វើការនៅក្រសួងពេទ្យសត្វ ហើយជាបន្តបន្ទាប់លោកបានផ្លាស់ទៅធ្វើការនៅចំការកៅស៊ូ កំពង់ចាម និងនៅរោងកុនអេដេនក្រុងភ្នំពេញ។ នៅថ្ងៃទី១ ខែកញ្ញា ឆ្នាំ១៩៣០ ក្នុងអាយុ២១ឆ្នាំ លោក យឿន ចឹម ត្រូវបានតែងតាំងជាអ្នកវាយអង្គុលីលេខនៅព្រះរាជបណ្ណាល័យ និងនៅពុទ្ធសាសនបណ្ឌិត្យ។ នៅឆ្នាំ១៩៤៣ លោកត្រូវតែងតាំងជាអគ្គលេខាធិការរងនៃពុទ្ធសាសនបណ្ឌិត្យ។ ចុងឆ្នាំ១៩៥០ ខណៈពេលដែល

បារាំងប្រគល់ពុទ្ធសាសនបណ្ឌិត្យឱ្យរដ្ឋាភិបាល លោកត្រូវបានតែងតាំងជា អគ្គលេខាធិការនាយកវិជ្ជាឋាន ពុទ្ធសាសនបណ្ឌិត្យ រហូតដល់ថ្ងៃទី១ ខែមករា ឆ្នាំ១៩៦៥ ពេលដែលលោកត្រូវចូលនិវត្តន៍ និងជំនួសដោយលោក រ៉ាយ ប៊ុក។


លោក លាង ហ័ប អាន

## លោក លាង ហ័ប អាន (១៩៣៨-?)

លោក លាង ហ័ប អាន បានដើរតួនាទីយ៉ាងសំខាន់ក្នុងការថែរក្សា និងអភិវឌ្ឍន៍អក្សរសាស្ត្រ និងវប្បធម៌ខ្មែរក្នុងសម័យឯករាជ្យ។ លោកទទួលបានបរិញ្ញាប័ត្រអក្សរសាស្ត្រខ្មែរ និងធ្វើជាសាស្ត្រាចារ្យមធ្យមសិក្សាបឋមភូមិ។ លោកជាអ្នកបង្កើតសមាគមអ្នកនិពន្ធខ្មែរ និងបានជាប់ឆ្នោតជាសមាជិកក្រុមអភិបាលសមាគមជាច្រើនលើកទៀតផង។ មិនតែប៉ុណ្ណោះ លោកបានក្លាយទៅជានាយកវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យនៅឆ្នាំ១៩៦៥ បន្ទាប់ពីលោក រ៉ាយ ប៊ុក។ ក្នុងនាមជានាយកវិជ្ជាឋាន លោក លាង ហ័ប អាន បានបំពេញការងារយ៉ាងច្រើន ដូចជាបោះពុម្ពទស្សនាវដ្ដីកម្ពុជសុរិយាជាថ្មីឡើងវិញជាដើម។ ក្រៅពីនេះ នៅឆ្នាំ១៩៦៦ និង១៩៦៧ លោក លាង ហ័ប អាន បានផ្ដួចផ្ដើមឱ្យមានជាការធ្វើបុណ្យរំលឹកខួបកំណើតគម្រប់៣៦ និង៣៧ ឆ្នាំរបស់ពុទ្ធសាសនាបណ្ឌិត្យផងដែរ។ លោកបានបំពេញនាទីនេះ រហូតដល់ឆ្នាំ១៩៧៣ ពេលដែលតំណែងនេះត្រូវផ្ទេរទៅឱ្យលោក អ៊ុក សាម៉ន ហើយលោកប្រហែលជាត្រូវតែងតាំងឱ្យធ្វើជារដ្ឋលេខាធិការក្រសួងមហាផ្ទៃទទួលបន្ទុកខាងផ្នែកសាសនា។

## លោក លី ធាមតេង (១៩៣០-?)

លោកជាអ្នកបង្កើតសមាគម និងបានជាប់ឆ្នោតជាសមាជិកក្រុមអភិបាលនៃសមាគមអ្នកនិពន្ធខ្មែរចំនួន ១៥លើក តាំងពីបង្កើតមក។ ក្រោយមក លោកបានក្លាយទៅជានាយកស្រាវជ្រាវនៅវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ ក្រសួងធម្មការ និងជាសមាជិកក្រុមជំនុំទំនៀមទម្លាប់ខ្មែរទៀតផង។ លោកមានការយកចិត្តទុកដាក់ច្រើនលើវិស័យវប្បធម៌ ក៏ដូចជាអក្សរសាស្ត្រខ្មែរ និងតែងចុះផ្សាយនូវស្នាដៃរបស់លោកតាមព្រឹត្តិបត្រផ្សេងៗ ដើម្បីឱ្យសាធារណៈជនបានជ្រាប និងយកទៅសិក្សារៀនសូត្រ។

## លោក ល្វី ហ្វីណូត៍ (១៨៦៤-១៩៣៥)

បារាំងរូបនេះ ក៏បានរួមចំណែកអភិរក្សប្រពៃណីទំនៀមទម្លាប់ សាសនា និងអក្សរសាស្ត្រខ្មែរ។ នៅឆ្នាំ១៩១៥ លោក ល្វី ហ្វីណូត៍ ក្នុងនាមជាចាងហ្វាងសាលាបារាំង បានសំរេចឱ្យមានការបង្កើតនូវគណៈកម្មការតែងវចនានុក្រមខ្មែរមួយ តាមសំណើររបស់លោក ហ្សក សឺដែស។ លោកជាអ្នកចេះដឹងជ្រៅជ្រះក្នុងផ្នែកជាច្រើន ដូចជាខាងសិលាចារឹក ភាសាសំស្ក្រឹត បុរាណវត្ថុវិទ្យា ប្រវត្តិសាស្ត្រ ទស្សនវិជ្ជា និងសាសនាជាដើម។ នៅឆ្នាំ១៩២២ លោកបានអញ្ជើញមកប្រទេសខ្មែរ និងបានពិភាក្សាគ្នាជាមួយលោករ៉េស៊ីដង់ជាន់ខ្ពស់អំពីការសិក្សានៅស្រុកខ្មែរ ដោយលោកផ្តល់ជាយោបល់សុំកុំឱ្យសិស្សខ្មែររៀនភាសា ឡាតាំង គួរតែឱ្យរៀនភាសាបាលី និងសំស្ក្រឹតនៅសាលាធំវិញ ព្រោះភាសាខ្មែរមានលាយឡំ និងភាសាបាលី និងសំស្ក្រឹតច្រើនណាស់។ ពេលនោះលោករ៉េស៊ីដង់ជាន់ខ្ពស់ក៏បានយល់ព្រម និងឱ្យគេចាត់ព្រះតេជគុណ ជួនណាត និងហួតតាត ទៅក្រុងហាណូយរៀនពីភាសាសំស្ក្រឹត សិលាចារឹក និងព្រះពុទ្ធសាសនា ជាមួយនិងលោក ល្វី ហ្វីណូត៍ ថែមទៀតផង។ លោកក៏បានដើរតួនាទីក្នុងការជួយសំរួលឱ្យមានការងាយស្រួលក្នុងការបោះពុម្ពសៀវភៅនៅសាលាបាលីជាន់ខ្ពស់ ដោយបង្កើតឱ្យមានគណៈកម្មការមួយ ដែលមានជាតិបារាំងម្នាក់ជាអធិបតី។ លើសពីនេះទៀត លោកបានបង្កើតឱ្យមានការសិក្សាភាសាសំស្ក្រឹតនៅស្រុកខ្មែរក្នុងឆ្នាំ១៩២៤។ តំណែងរបស់លោកជាចាងហ្វាងសាលាបារាំងចុងបូព៌ាបានត្រូវជំនួសដោយលោក សឺដែស ចាប់ពីឆ្នាំ ១៩៣៣ រហូតមក។


សម្តេចព្រះធម្មលិខិត ល្វី ឯម

## សម្តេចព្រះធម្មលិខិត ល្វី ឯម (១៨៧៩-១៩៥៧)

ក្រៅពីសម្តេចជួន ណាត និងហួត តាត ព្រះធម្មលិខិត ល្វី ឯម បានចូលរួមចំណែកដ៏ធំក្នុងការរៀបចំព្រះពុទ្ធសាសនាខាងគណៈមហានិកាយ។ នៅឆ្នាំ ១៩០២ ព្រះសង្ឃរាជបានចាត់លោកឱ្យទៅធ្វើជាចៅអធិការវត្តស៊ីធរ នៅស្រុកស៊ីធរ ខេត្តព្រៃវែង។ ព្រះបាទសម្តេចព្រះស៊ីសុវត្ថិមុនីវង្ស ស្នើរទៅលោកគ្រូព្រះមហាវិមលធម្មថោង អញ្ជើញព្រះគ្រូចៅអធិការ ឯម មកធ្វើចៅអធិការវត្តលង្កា នៅឆ្នាំ១៩១១។

លោកត្រូវបានប្រលងជាប់ជាសាស្ត្រាចារ្យសាលាបាលីជាន់ខ្ពស់ នៅឆ្នាំ១៩១៥ និងបានឡើងឋានៈជាចាងហ្វាងសាលាបាលីជាន់ខ្ពស់នៅឆ្នាំ ១៩២៩។ ព្រះតេជគុណជាអ្នកសំខាន់ម្នាក់ក្នុងការពិគ្រោះយោបល់ជាមួយអ្នកអង្គម្ចាស់ នរោត្តមសិង្ហរា និងព្រះបាទសម្តេច ព្រះស៊ីសុវត្ថិមុនីវង្ស ដើម្បីថ្វាយជូនទៅសម្តេច ព្រះស៊ីសុវត្ថិ ព្រះចៅក្រុងកម្ពុជា ដើម្បីស្នើរបកប្រែ និងបោះពុម្ពផ្សាយគម្ពីរព្រះត្រៃបិដកជាភាសាសម្រាយ និងជាអ្នកផ្តួចផ្តើមស្នើរឱ្យបង្កើតសាលាពុទ្ធិកបឋមសិក្សាជាផ្លូវការនៅទូទាំងប្រទេស និងបានយល់ព្រមទទួលសមណសិស្សជាតិលាវ និងកូសាំងស៊ីន រួមទាំងជាអ្នកជំរុញឱ្យមានការបង្កើត សាលាបាលីនៅស្រុកលាវ និងកូសាំងស៊ីនផងដែរ។ ដោយមានការដកទំនុកចិត្តពីបារាំង ព្រះតេជគុណបានសុំលាឈប់ពីតំណែងចាងហ្វាងសាលាបាលីជាន់ខ្ពស់ និងអធិបតីក្រុមជំនុំបិដកនៅឆ្នាំ១៩៤២ គឺនៅពេលដែលលោកបានទទួលឋានៈជា ព្រះធម្មលិខិត។



ព្រះមុនីកោសល សួរ ហាយ

## ព្រះមុនីកោសល សួរ ហាយ (១៩០៥-?)

ព្រះមុនីកោសល សួរ ហាយ បានចូលរួមចំណែកក្នុងការចងក្រងព្រះត្រៃបិដក ក៏ដូចជាការអប់រំដល់សមណសិស្សដែរ។ លោកបានត្រូវនិមន្តមកធ្វើជាសមាជិកក្រុមជំនុំព្រះត្រៃបិដក នៅខែតុលា ឆ្នាំ១៩៣៣។ នៅឆ្នាំ១៩៤៧ លោកក៏បានជ្រើសរើស ចូលជាសមាជិក នៃគណៈកម្មការវប្បធម៌ផ្នែក "ក" បន្ថែមទៀត ហើយមួយឆ្នាំបន្ទាប់មក ចូលជាសមាជិកថេរសភា។ នៅឆ្នាំ១៩៥៩ លោកបានទទួលតំណែងជាអធិបតីរងនៃក្រុមជំនុំព្រះត្រៃបិដក និងបានទទួលតំណែងជាចៅអធិការវត្តនិរោធរង្សីក្នុងឆ្នាំ១៩៦១។

## ស្តេចក្រុមហ្លួងស៊ីសុវត្ថិសុត្ថារោស ខេមរិន្ទ (១៨៨៧-១៩៥១)

ទ្រង់ជាព្រះរាជបុត្ររបស់ព្រះបាទសម្តេចស៊ីសុវត្ថិព្រះបរមរាជានុកោដ្ឋ ព្រះមាតាព្រះនាម (ឃុន) ព្រះម៉ែម្នាងបុប្ផាសី។ កាលនៅព្រះរាជកុមារទ្រង់បានយាងទៅសិក្សានៅប្រទេសបារាំងអស់ចំនួន៦ឆ្នាំ ទើបទ្រង់យាងមកប្រទេសខ្មែរវិញ និងទទួលឧបសម្បទាជាភិក្ខុភាវក្នុងវត្តបទុមវតីរាជវរារាម។ លុះលាចាកសិក្ខាបទមកទ្រង់យាងចូលកាន់តំណែងជាច្រើនក្រសួងរហូតដល់ព្រះជន្មគំរប់ ៥៣វស្សា។ ក្នុងចំណោមតំណែងទាំងនោះទ្រង់ក៏បានកាន់តំណែងជា ទីអគ្គមហាសេនា សេនាបតីក្រសួងមហាផ្ទៃ និងធម្មការដែរ។ បន្ទាប់ពីសម្តេច

កុញ្ញរាធិបតី ប៊ុន ទទួលមរណភាពទៅ ទ្រង់ក៏បានឡើងជំនួសតំណែងរបស់លោកជាចក្រីកុញ្ញរាធិបតី សេនាបតី យុទ្ធនាធិការ យោធាធិការ និងសិក្សាធិការ។ ទ្រង់មានព្រះរាជហឫទ័យជ្រះថ្លាក្នុងព្រះពុទ្ធសាសនាណាស់ ដោយបានជួយទំនុកបំរុងផ្គងផ្ដើមឱ្យមានការសិក្សារៀនសូត្រធម្មវិន័យ ជាពិសេសទ្រង់ក៏ជាអ្នកផ្ដើមគំនិតក្នុងការបង្កើតក្រុមជំនុំព្រះត្រៃបិដក និងជួយអំពាវនាវឱ្យមានការយកឯកសារ និងវត្ថុមានតំលៃខាងពុទ្ធសាសនាមកដាក់តម្កល់នៅព្រះរាជបណ្ណាល័យ ដើម្បីឱ្យព្រះពុទ្ធសាសនាខ្មែររីតតែមានការរីកចំរើនខ្លាំងឡើងថែមទៀតផង។



## កញ្ញា ស៊ុយសាន ការប៉ីឡែស (១៨៩០-១៩៦៨)

កញ្ញា ស៊ុយសាន ការប៉ីឡែស

ទោះជាជនជាតិដើមជ្វីស និងមានសញ្ជាតិបារាំង កញ្ញាការប៉ីឡែសចាប់តាំងពីចាប់ផ្ដើមបំរើការនៅដែនដីឥណ្ឌូចិន ពិសេសនៅកម្ពុជា រហូតដល់ពេលកញ្ញាចូលនិវត្តន៍ តែងមានចេតនាចង់ឱ្យមានការថែរក្សាព្រះពុទ្ធសាសនា និងប្រពៃណីទំនៀមទម្លាប់ល្អរបស់ជាតិខេមរៈ។ ការប៉ីឡែសជាអ្នកមានចំណេះដឹងខាងផ្នែកអក្សរសាស្ត្រ និងអរិយធម៌ឥណ្ឌា ពីសាលាអនុវត្តន៍ការសិក្សាជាន់ខ្ពស់ (Ecole pratique des Hautes Etudes)។ នៅឆ្នាំ១៩១៩ គាត់បានធ្វើការបោះពុម្ពអត្ថបទដំបូង ដែលមានចំណងជើងថា "លោកកេស្វរសតក" (១00 គាថា) ដែលពោលសរសើរគុណរបស់អទិទេពបង្កើតលោក។ គាត់បានចូលជាសមាជិកនៃសាលាបារាំងចុងបូព៌ានៅក្នុងឆ្នាំ១៩២២ និងបានធ្វើដំណើរមកដល់ទីក្រុងហាណូយនៅថ្ងៃទី១ ខែមករា ឆ្នាំ១៩២៣។ នៅក្នុងឆ្នាំ១៩២៥ គាត់បានក្លាយទៅជាអ្នកអភិរក្សដំបូងគេបំផុតនៃព្រះរាជបណ្ណាល័យកម្ពុជា។ នៅក្នុងឆ្នាំ១៩២៩ បន្ទាប់ពីបានធ្វើដំណើរទៅកាន់តំបន់និរតីនៃដែនកូសាំងស៊ីន និងប្រទេសលាវ ដែលជាកន្លែងសម្បូរទៅដោយអ្នកកាន់ព្រះពុទ្ធសាសនា ការប៉ីឡែសបានដាក់សំណើរមួយច្បាប់សុំឱ្យបង្កើតជាមន្ទីរពុទ្ធសាសនបណ្ឌិត្យឡើង។ ការស្នើរសុំរបស់គាត់ក៏បានទទួលនូវជោគជ័យតាមរយៈការអនុញ្ញាតឱ្យបង្កើតមន្ទីរពុទ្ធសាសនបណ្ឌិត្យ នៅថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៣០ នៅក្នុងប្រទេសកម្ពុជា និងក្រោយមកទៀត នៅក្នុងប្រទេសលាវ។ ទន្ទឹមគ្នានោះដែរ គាត់ត្រូវបានតែងតាំងឱ្យធ្វើជា អគ្គលេខាធិការនៃមន្ទីរថ្មីនេះថែមទៀតផង។ ការគ្រប់គ្រងរបស់គាត់នៅព្រះរាជបណ្ណាល័យកម្ពុជា និងមន្ទីរពុទ្ធសាសនបណ្ឌិត្យបានធ្វើឱ្យមានការរីកចំរើនខាងចំណេះដឹងយ៉ាងច្រើននៅក្នុងស្រុកខ្មែរតាមរយៈ

ការបោះពុម្ពនូវសៀវភៅឯកសារខាងព្រះពុទ្ធសាសនា អក្សរសាស្ត្រ ប្រវត្តិសាស្ត្រ រឿងព្រេង វចនានុក្រមខ្មែរ ព្រះត្រៃបិដក និងបានជួយប្រមូលឯកសារ និងវត្ថុមានតំលៃ ខាងពុទ្ធសាសនា និងប្រពៃណីជាច្រើនទៀតផង។ នៅក្នុងខែធ្នូ ឆ្នាំ១៩៣៦ គាត់ត្រូវបានបញ្ចូលសារជាថ្មីជាផ្លូវការជាសមាជិកអចិន្ត្រៃយ៍នៅក្នុងសាលាបារាំងចុងបូពា។ ប៉ុន្តែ នៅក្នុងឆ្នាំ១៩៤១ គាត់បានចូលនិវត្តន៍ ហើយធ្វើដំណើរទៅរស់នៅឯ ប៉ុនឌីឆេរី នៅជិតអាស្រាម ឪ ស្រីអូរូប៊ីដូ។ នៅទីនោះគាត់បានបង្រៀនភាសាបារាំង និងអក្សរសាស្ត្រ ហើយក៏បានបង្កើតឱ្យមានជាសន្និសីទជាច្រើនផងដែរ។ គាត់តែងតែមានទំនាក់ទំនងល្អជាមួយកូនសិស្សជនជាតិឥណ្ឌា និងអ្នកជំនាញខាងអក្សរសាស្ត្រ និងអរិយធម៌ឥណ្ឌាជាច្រើន។ ប៉ុន្តែទោះបីយ៉ាងណាក៏ដោយ ក៏គាត់ពុំដែលបំភ្លេចព្រះពុទ្ធសាសនាដែរ ជាតួយ៉ាង គាត់បានចាកចេញពីប៉ុនឌីឆេរី ទៅកាន់ប្រទេសបារាំង និងទៅកាន់ស្រីលង្កាដែលជាទីកន្លែងគាត់ទៅជួយរៀបចំធ្វើស័ព្ទវចនាធិប្បាយព្រះពុទ្ធសាសនា។

## លោក ស៊ីលវ៉ាំង ឡេវី

លោកស៊ីលវ៉ាំង ឡេវីជាអ្នកប្រាជ្ញធំ១ក្នុងលោក។ លោកបានយកចិត្តទុកដាក់ក្នុងសេចក្តីស៊ីវិល័យនៃអរិយធម៌របស់ស្រុកឥណ្ឌាណាស់។ លោកមានចំណេះដឹងខាងភាសាសំស្ក្រឹត និងបាលីយ៉ាងច្បាស់លាស់ ហើយចេះចាំព្រះពុទ្ធសាសនាដោយមុតមាំទៀតផង។ លោកបានសិក្សាគម្ពីរវេជ្ជការគ្រប់យ៉ាងទាំងអស់ ទាំងមហាយាន ទាំងថេរវាទ ជាភាសាគ្រប់ជាតិនៅក្នុងប្រទេសអាស៊ី។ លោកបានយកចិត្តទុកដាក់ជានិច្ចក្នុងបូពាប្រទេសដែលជំពាក់ក្នុងព្រះពុទ្ធសាសនា។ ព្រះរាជបណ្ណាល័យកម្ពុជាមានសៀវភៅជាច្រើន ដែលជាស្នាដៃរបស់លោក ។


លោក សឹង ង៉ុកថាន់

## លោក សឹង ង៉ុកថាន់ (១៩០៨-១៩៧៦)

ជាអ្នកចេះដឹងមួយរូប ដែលមានកំណើតនៅវៀតណាមខាងត្បូង លោក សឹង ង៉ុកថាន់ ជាអ្នកស្នេហាជាតិដែលលេចធ្លោ ដែលតែងមានគំនិតរំដោះប្រទេសពីបារាំង និងចង់ឱ្យមានវឌ្ឍនភាពជាតិ។ លោកបានទៅសិក្សានៅម៉ុងប៉ុលីយេ និងនៅប៉ារីសប្រទេសបារាំង និងទទួលបានសញ្ញាប័ត្រ ខាងកិច្ចការបង្រៀន ហើយបាន

បន្តការសិក្សាខាងមុខវិជ្ជាច្បាប់បានមួយឆ្នាំ (បីឆ្នាំ?) ទៀត នៅមហាវិទ្យាល័យក្រុងប៉ារីស មុនពេលត្រលប់មកឥណ្ឌូចិនវិញនៅឆ្នាំ១៩៣៣។ គាត់បានធ្វើការជាស្មៀននៅព្រះរាជបណ្ណាល័យកម្ពុជា។ លោកមានចំណេះដឹងខាងព្រះពុទ្ធសាសនា និងទំនៀមទម្លាប់ខ្មែរជ្រៅជ្រះណាស់ ហើយលោកបានជួយបកប្រែឯកសារមួយចំនួនទៅជាភាសាបារាំងថែមទៀតផង។ ប៉ុន្តែជាអកុសល នៅក្នុងឆ្នាំ១៩៣៧ លោកត្រូវគេផ្លាស់ឱ្យទៅធ្វើជាតុលាការីនៅខេត្តពោធិសាត់វិញ។ នៅក្នុងឆ្នាំ១៩៣៨ លោកបានបង្កើតឱ្យមានជា "យុវសាលា" ឡើង។ លោកត្រូវបានតែងតាំងជា អាជ្ញាដែលទទួលបន្ទុកក្នុងការបញ្ជាក់ និងធ្វើរបាយការណ៍ទៅមហាសន្និបាតរោងពុម្ពនគរវត្ត (អាជ្ញា ឬព្រះរាជអាជ្ញានៅក្រុងភ្នំពេញ?) ក្នុងឆ្នាំ១៩៣៩។ នៅឆ្នាំដដែលនេះ នៅពេលដែលការប៉ុឡែសធ្វើដំណើរទៅប្រទេសលាវនោះ គាត់បានត្រូវតែងតាំងជាអគ្គលេខារងពុទ្ធសាសនបណ្ឌិត្យ ជំនួសឱ្យក្រមការជុំម៉ៅដែលផ្លាស់ចេញ។ នៅថ្ងៃទី២៧ ខែមីនា ឆ្នាំ១៩៤១ គាត់បានធ្វើការវាយតប់គ្នាជាមួយនឹងលោកយឿន ចឹម ដែលជាអ្នកវាយអង្គុលីលេខនៅព្រះរាជបណ្ណាល័យ។ លោក សឹង ង៉ុក ថាន់ ជាអ្នកដឹកនាំធំម្នាក់នៅពីក្រោយបាតុកម្មឆ្នាំ១៩៤២ ក្នុងបំណងសុំឱ្យមានការដោះលែងអាចារ្យ ហែម ចៀវ។ បន្ទាប់ពីបាតុកម្មនេះបានបរាជ័យ លោកបានរត់ភៀសខ្លួនទៅប្រទេសថៃ រួចបន្តទៅប្រទេសជប៉ុនទៀត។ នៅពេលដែលជប៉ុនធ្វើពលប្រហារលើបារាំងបានសំរេច និងប្រគល់ឯករាជ្យឱ្យប្រទេសកម្ពុជានោះ គាត់បានត្រូវតែងតាំងជានាយករដ្ឋមន្ត្រីរបស់ប្រទេសខ្មែរបានចំនួន២ខែ ហើយក៏ត្រូវចាប់ខ្លួនដោយក្រុមសម្ព័ន្ធមិត្ត និងត្រូវបានកាត់ទោសឱ្យជាប់គុកចំនួន ២០ឆ្នាំ ប៉ុន្តែក្រោយមកត្រូវសំរាលទោសឱ្យត្រឹមស្ថិតនៅក្នុងការឃ្លាំមើលនៅក្នុងប្រទេសបារាំងដែលជាកន្លែងលោកបានបញ្ចប់ការសិក្សា ផ្នែកច្បាប់។


ព្រះពោធិវង្ស ហួត តាត

## សម្តេចព្រះសង្ឃរាជ ហួត តាត (១៨៩១-១៩៧៥?)

ក្នុងចលនារៀបចំសមណសង្ឃគណៈមហានិកាយឱ្យប្រតិបត្តិតាមពុទ្ធានុញ្ញាត និងលើកតម្កើងអក្សរសាស្ត្រជាតិ ព្រះពោធិវង្ស ហួត តាត បានចំណាយពេលយ៉ាងច្រើនដើម្បីបំរើផលប្រយោជន៍ដល់ជាតិខេមរៈ។ នៅឆ្នាំ១៩១៩ លោកបានត្រូវគេតែងតាំងជាសមាជិកគណៈកម្មការបង្កើតវចនានុក្រមខ្មែរ។ បន្ទាប់ពីត្រលប់មកពីសិក្សាភាសាសំស្ក្រឹត និងសិលាចារឹកនៅហាណូយជាមួយព្រះតេជគុណ ជួន ណាត វិញ លោកបានត្រូវតែងតាំងជា

សាស្ត្រាចារ្យបង្រៀនភាសាសំស្ក្រឹតនៅសាលាបាលីជាន់ខ្ពស់ ។ នៅឆ្នាំ១៩២៨ លោកបានត្រូវបញ្ជូនទៅ កូសាំងស៊ីន រួមជាមួយនឹងអភិរក្សព្រះរាជបណ្ណាល័យកម្ពុជា ដើម្បីធ្វើការផ្សព្វផ្សាយឱ្យព្រះសង្ឃ និងប្រជាជនយកចិត្តទុកដាក់ អំពីប្រពៃណីខ្មែរ ហើយលោកនិមន្តទៅទីនោះម្តងទៀតដើម្បីពន្យល់ពីការបង្កើត និងផលប្រយោជន៍នៃមន្ទីរពុទ្ធសាសនបណ្ឌិត្យ បន្ទាប់មកទៀត លោកបានត្រូវតែងតាំងជាគណៈកម្មការពិនិត្យវចនានុក្រមខ្មែរ និងសមាជិកក្រុមជំនុំព្រះត្រៃបិដក ។ នៅឆ្នាំ១៩៣១ លោកបាននិមន្តទៅទីក្រុងវៀងច័ន្ទ និងហ្លួងព្រះបាង ដើម្បីចូលរួមពិធីសម្ពោធមន្ទីរពុទ្ធសាសនបណ្ឌិត្យប្រទេសលាវ និងពិភាក្សាអំពីការបង្កើតសាលាបាលីជាន់ខ្ពស់នៅប្រទេសនោះទៀតផង ។ លោកជាសមាជិកម្នាក់ក្នុងចំណោមសមាជិកទាំងបួនមានព្រះតេជគុណ ជួន ណាត អ៊ុម ស៊ូរ និងព្រះតេជគុណ មឿង ជាដើម ដែលត្រូវបានតែងតាំងនៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ១៩៣៧ ដើម្បីឱ្យសិក្សាពីភាពខុសប្លែកគ្នារវាងធម៌ចាស់ និងធម៌ថ្មី ហើយនឹងរកមធ្យោបាយដើម្បីបន្សាត់បង់នូវជម្លោះសាសនានេះ ។ នៅក្នុងឆ្នាំ១៩៤៥ លោកត្រូវបានតែងតាំងជាអធិបតីនៃថេរសភា ហើយនៅឆ្នាំ១៩៤៨ លោកត្រូវបានតម្លើងឋានៈជាចាងហ្វាងសាលាបាលីជាន់ខ្ពស់ និងក្រុមជំនុំព្រះត្រៃបិដក ។ នៅក្នុងឆ្នាំ១៩៥៥ លោកបានក្លាយទៅជាអគ្គាធិការនៃពុទ្ធិកសិក្សាក្នុងប្រទេសកម្ពុជា ហើយឆ្នាំ១៩៦៨ លោកបានក្លាយទៅជាសាកលវិទ្យាធិការនៃពុទ្ធិកសាកលវិទ្យាល័យ ។ បន្ទាប់ពីសម្តេចសង្ឃរាជ ជួន ណាត សុគតទៅ លោកបានត្រូវតែងតាំងជាសម្តេចព្រះមហាសុមេធាធិបតី សង្ឃរាជគណៈមហានិកាយ ។ នៅអំឡុងឆ្នាំ ១៩៧៥ ព្រះអង្គត្រូវបានគេជំលៀសជាមួយនឹងព្រះសង្ឃដទៃទៀតទៅ ស្រុកឧដុង្គ ហើយប្រហែលជាត្រូវបានគេធ្វើគតនៅទីនោះ ។

## ព្រះគ្រូអាចារ្យ ហែម ចៀវ (១៨៩៨-១៩៤៣)

ក្នុងនាមជាខេមរបុត្រស្នេហាជាតិមួយរូប ព្រះគ្រូអង្គនេះបានចូលរួមចំណែកយ៉ាងច្រើនក្នុងការអប់រំកុលបុត្រខ្មែរជាទូទៅឱ្យស្រលាញ់ឥស្សរភាព កិត្តិយស និងស្អប់ខ្ពើមការសង្កត់សង្កិនរបស់អាណានិគម ។ នៅពេលដែលលោកមានអាយុសមល្មម ឪពុកម្តាយបានយកលោកឱ្យទៅសំណាក់រៀនសូត្រជាមួយព្រះតេជគុណ ជួន ណាត ។ លោកបានប្រលងជាប់សញ្ញាប័ត្របាលីជាន់ខ្ពស់នៅឆ្នាំ១៩២១ ។ ព្រះតេជគុណ ជួន ណាត ក៏ចាត់ឱ្យអាចារ្យ ហែម ចៀវ ទៅជួយបង្រៀននៅខេត្តកំពត ។នៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ១៩៣២ លោកត្រូវបានតែងតាំងជាសាស្ត្រាចារ្យភាសាបាលី និងជាសមាជិកក្រុមជំនុំព្រះត្រៃបិដក ។ លោកអាចារ្យ ហែម ចៀវ ជាព្រះសង្ឃដែលតែងតែជួយទេសនាដាស់តឿនប្រជាជនខ្មែរឱ្យខំប្រឹងប្រែងរៀនសូត្រ ចេះរកស៊ី និងប្រឆាំងនឹងបារាំង ។ លោកអាចារ្យនេះតែងមានទំនាក់ទំនងជាមួយនឹងអ្នកជាតិនិយមខ្មែរមួយចំនួនដូចជា សឺង ង៉ុកថាន់ ប៉ាច ឈឺន ប៊ុណ្ណចន្ទម៉ុល ជាដើម ។ ដោយសារលោកចូលចិត្តទេសនាបញ្ឆិតបញ្ឆៀងឱ្យមានការប្រឆាំងនឹងបារាំងនេះហើយ អាចារ្យ

ហែម ចៀវ ដែលតែងត្រូវចាត់ឱ្យចេញទៅទេសនា ត្រូវបានពួកគីញ្ញបារាំងតាមដានរហូតដល់ពេលគេចាប់ផ្សឹក នៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៤២ នៅក្រសួងមហាផ្ទៃ និងធម្មការ។ ការចាប់ខ្លួនអាចារ្យ ហែម ចៀវ បាននាំឱ្យមានការធ្វើបាតុកម្មមួយផ្ទុះឡើងនៅថ្ងៃទី២០ ខែកក្កដាក្នុងឆ្នាំដដែល ដើម្បីសុំឱ្យមានការដោះលែង នៅទីរេស៊ីដង់នៅខាងលិចវត្តភ្នំ។ ប៉ុន្តែជាលទ្ធផល សាលាបាលីជាន់ខ្ពស់បានត្រូវបិទទ្វារ ពីថ្ងៃទី១៨ ខែសីហា ឆ្នាំ១៩៤២ រហូតដល់ថ្ងៃទី១ ខែធ្នូ ឆ្នាំ១៩៤២ ចំណែកអ្នកចូលរួមខ្លះត្រូវរត់ទៅប្រទេសថៃ ឯព្រះសង្ឃ និងគ្រហស្ថមួយចំនួនទៀតត្រូវបានចាប់ខ្លួនបញ្ជូនទៅគុកធំនៅព្រៃនគរ។ លោកអាចារ្យ ហែម ចៀវ បានត្រូវគេកាត់ទោសប្រហារជីវិត ប៉ុន្តែត្រូវសំរាលមកត្រឹមជាប់គុកអស់មួយជីវិតវិញ។ នៅខែមីនា ឆ្នាំ១៩៤៣ គេក៏បញ្ជូនលោកអាចារ្យ ហែម ចៀវ និងអ្នកមួយចំនួនទៀតទៅកាន់កោះត្រឡាច ហើយនៅឆ្នាំដដែល នេះលោកក៏សុគតទៅ។ រហូតដល់សម័យក្រោយមក នៅថ្ងៃទី២២ ខែមីនា ឆ្នាំ១៩៧០ គណៈរដ្ឋមន្ត្រីក្រោមអធិបតីភាពលោកសេនាប្រមុខ លុន នល់ ដែលជាប្រធានាធិបតីនៃសាធារណរដ្ឋខ្មែរបានសម្រេចទៅយកអដ្ឋិធាតុរបស់អាចារ្យ ហែម ចៀវ ពីកោះត្រឡាច ហើយតម្លើងឋានៈលោកអាចារ្យជា "រដ្ឋបុរសជាតិ"។

## លោក ប្រាំចំស៊័រ ម៉ារទីនី (១៨៩៥-១៩៦៥)

ជាកូនកាត់ខ្មែរ លោកជាអ្នកបន្តដំណែងជា អគ្គលេខាធិការពុទ្ធសាសនបណ្ឌិត្យ បន្ទាប់ពីលោក ឱុយប៉ង់តេ។ មុនដំបូង លោកបានធ្វើការសិក្សាច្បាប់ និងទស្សនវិជ្ជា ប៉ុន្តែក្រោយមកដោយលោកមានការចាប់អារម្មណ៍ចំពោះផ្នែកភាសា លោកក៏បានចូលសិក្សាភាសាសំស្ក្រឹត និងវិជ្ជាខាងបូព៌ាប្រទេស។ នៅឆ្នាំ១៩២៨ លោកបានក្លាយទៅជាគ្រូបង្រៀនភាសាសៀម និងខ្មែរ។ លោកបានមកកាន់ប្រទេសខ្មែរនៅឆ្នាំ១៩៤៦។ នៅឆ្នាំ១៩៤៧ លោកបានក្លាយទៅជាអគ្គលេខាធិការរបស់ពុទ្ធសាសនបណ្ឌិត្យ និងសមាជិកឆ្លើយឆ្លងរបស់សាលាបារាំង ក្នុងឋានៈជាអ្នកអភិរក្សស្ដីទីនៃប្រាសាទបុរាណខ្មែរ។ ស្នាដៃសំខាន់មួយទៀតរបស់គាត់នោះ គឺការសិក្សាស្រាវជ្រាវអំពីលក្ខណៈវេយ្យាករណ៍ទូទៅនៅឥណ្ឌូចិន និងបានបង្កើតនូវក្បួនសំរាប់ធ្វើការកត់សំគាល់សំលេង និងតួអក្សរនៅឥណ្ឌូចិនទៀតផង។

## លោក ហ្សេក សឺដែស (១៨៨៦-១៩៦៩)

លោក ហ្សេក សឺដែស ទទួលបាននូវកេរ្តិ៍ឈ្មោះយ៉ាងច្រើន ក្នុងនាទីលោកជាអ្នកប្រាជ្ញអំពីខ្មែរ និងឥណ្ឌូចិនទាំងមូល។ លោកបានដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយជំរុញឱ្យមានការចងក្រងវចនានុក្រមខ្មែរ ក្នុងបំណងរៀបចំអក្សរសាស្ត្រខ្មែរឱ្យមានសណ្ដាប់ធ្នាប់។ លោកបានធ្វើការបោះពុម្ពនៅក្នុង ទស្សនាវដ្ដីសាលាបារាំងចុងបូព៌ា នូវស្នាដៃដំបូងរបស់គាត់ស្ដីពីសិលាចារឹកជាភាសាខ្មែរ និងសំស្ក្រឹត តាំងតែលោកអាយុ ១៨ឆ្នាំមកម្លេះ។

នៅឆ្នាំ១៩១១ បន្ទាប់ពីចប់កាតព្វកិច្ចយោធា និងបានទទួលនូវសញ្ញាប័ត្រពីសាលាអនុវត្តន៏សិក្សាជាន់ខ្ពស់ (Ecole pratique des Hautes Etudes) គាត់បានត្រូវគេតែងតាំងជាបុគ្គលិក សាលាបារាំងចុងបូព៌ា ដែលជាហេតុធ្វើឱ្យលោកធ្វើដំណើរមកកាន់ស្រុកខ្មែរក្នុងខែ វិច្ឆិកា។ នៅពេលដែលលោកស្នាក់នៅមួយរយៈ នៅក្នុងទីក្រុងបាងកកនោះ ព្រះអង្គម្ចាស់ ដាំរុង បានសុំឱ្យគាត់ធ្វើជាអ្នកអភិរក្សនៅបណ្ណាល័យជាតិប្រទេសសៀម និងជាអ្នកអភិរក្សប្រាសាទបុរាណ។ ដូចនេះហើយគាត់បានឈប់ពីសាលាបារាំងចុងបូព៌ានៅឆ្នាំ១៩១៨។ ស្នាដៃរបស់គាត់បានទទួលការគាំទ្រយ៉ាងខ្លាំង ពីសំណាក់ប្រជាជាតិសៀម ហើយលោកបានទទួលមុខងារសំខាន់ៗជាច្រើន។ នៅក្នុងឆ្នាំ១៩២៩ គាត់បានធ្វើដំណើរមកកាន់ទីក្រុងហាណូយ ដើម្បីទទួលការងារថ្មីជាចាងហ្វាង សាលាបារាំងចុងបូព៌ារហូតដល់ឆ្នាំ១៩៤៧ ទើបបានគាត់ចូលនិវត្តន៏។ ហើយនៅពេលដែលលោកទៅធ្វើការនៅហាណូយនោះ លោកបានធ្វើឱ្យមានការរីកចំរើនគួរឱ្យកត់សំគាល់ ដូចជាបានបង្កើតឱ្យមានបណ្ណាល័យ ទីពិសោធន៍ រូបភាព សារមន្ទីរ ជាដើម ។

នៅក្នុងអំឡុងពេលមានសង្គ្រាមផ្ទុះឡើង ទោះបីជាមានការលំបាកយ៉ាងណាក៏ដោយ ក៏គាត់ខិតខំធ្វើការសិក្សាស្រាវជ្រាវ និងបោះពុម្ពស្នាដៃជាច្រើនផងដែរ ហើយបន្ទាប់ពីសង្គ្រាមនោះ ស្នាដៃរបស់គាត់បានត្រូវគេទទួលស្គាល់ជាសកល ហើយមុខវិជ្ជានៃប្រទេសនៅអាស៊ីអាគ្នេយ៍ ត្រូវបានគេបញ្ចូលឱ្យសិក្សានៅក្នុងមហាវិទ្យាល័យថែមទៀតផង។ នៅក្នុងឆ្នាំ១៩៤៧ គាត់បានចូលនិវត្តន៍ ហើយក្លាយទៅជាអ្នកអភិរក្សនៅសារមន្ទីរអេនណើរី។ ក្រោយមក គាត់បានក្លាយទៅជាគ្រូបង្រៀននៅសាលាល្បីៗ និងទទួលនូវគ្រឿងឥស្សរិយយសជាច្រើន។

## លោកស្រី អេឌីលីន ប៉ូរេម៉ាស្ស៊ៀរ៍

លោកស្រីជាជនជាតិបារាំងមួយរូប ដែលបានជួយកំណត់នូវជោគវាសនារបស់ពុទ្ធសាសនបណ្ឌិត្យ ពិសេសក្នុងក្រុមជំនុំទំនៀមទម្លាប់ខ្មែរ។ លោកស្រីជាកូនស្រីរបស់លោក ហ្សេកម៉ាស្ស៊េរ៉ូ ដែលជាអភិបាលអាណានិគម។

លោកស្រីបានទទួលសញ្ញាប័ត្រខាងអក្សរសាស្ត្រ និងបានមកកាន់ទីក្រុងភ្នំពេញដោយមានតួនាទីជាអ្នកដឹកនាំនៅក្នុងក្រុមជំនុំទំនៀមទម្លាប់ខ្មែរ។ ការងារនេះបានផ្តល់លទ្ធភាពឱ្យលោកស្រីអាចប្រមូលឯកសារជាច្រើនជាមួយប្តីរបស់គាត់ដើម្បីធ្វើការបោះពុម្ពស្តីពីទំនៀមទម្លាប់ប្រពៃណីខ្មែរ។ បន្ថែមពីនេះទៅទៀត លោកស្រីបានធ្វើការជាអ្នកអភិរក្សសារមន្ទីរភ្នំពេញ ដែលនៅទីកន្លែងនោះគាត់អាចប្រមូលបានឯកសារនវិទ្យាជាច្រើន។ នៅឆ្នាំ១៩៣៧ គាត់បានក្លាយទៅជាសមាជិកឆ្លើយឆ្លងរបស់វិទ្យាស្ថានឥណ្ឌូចិនដើម្បីការសិក្សាអំពីមនុស្ស និងជាសមាជិកជាប់កិច្ចសន្យារបស់សាលាបារាំងចុងបូព៌ា ដើម្បីធ្វើការសិក្សាអំពីនវិទ្យាខ្មែរ។ គាត់បានធ្វើការនេះរហូតដល់ឆ្នាំ១៩៥០ និងបានបោះពុម្ពឯកសារជាច្រើន។ ការងាររបស់លោកស្រីបានបង្ហាញអំពីដើមកំណើតនៃប្រពៃណីរបស់ខ្មែរ និងការចាក់ឫសយ៉ាងមាំនៅក្នុងសង្គមខ្មែរ ។


ព្រះឧត្តមមុនី អ៊ុម ស៊ូរ

## ព្រះឧត្តមមុនី អ៊ុម ស៊ូរ (១៨៨១-១៩៣៩)

ក្នុងឆ្នាំ១៩២៩ រាជការបានតែងតាំងព្រះគ្រូវិមលបញ្ញា អ៊ុម ស៊ូរ ជាអធិបតីរង និងជាអ្នកចាត់ការទទួលខុសត្រូវខ្ពស់ក្នុងក្រុមជំនុំប្រែព្រះត្រៃបិដក ចំពេលដែលរាជការបង្កើតឱ្យមានពុទ្ធសាសនបណ្ឌិត្យ។ នៅឆ្នាំ១៩៣០ ព្រះករុណាទ្រង់ព្រះរាជទានកិត្តិយសជាព្រះឧត្តមមុនីទីរាជាគណៈពិសេស។ ព្រះឧត្តមមុនី អ៊ុម ស៊ូរ ដែលជាអ្នកប្រាជ្ញខ្មែរបានទទួលអនិច្ចកម្ម នៅថ្ងៃទី ២២ ខែកក្កដា ឆ្នាំ១៩៣៩។ ពិធីបូជាព្រះសពរបស់ព្រះអង្គមានការនិមន្តចូលរួមពីសំណាក់ព្រះសង្ឃចំនួន២០០០អង្គ មកពីតាមបណ្តាខេត្តផ្សេងៗ។


លោក ឱម ខែម

## លោក ឱម ខែម (១៩៣៨-២០០៣)

លោក ឱម ខែម ដែលមានចំណេះដឹងច្រើនខាងវិស័យពុទ្ធសាសនា បានរួមចំណែកយ៉ាងច្រើនក្នុងការផ្សព្វផ្សាយ និងលើកស្ទួយអក្សរសាស្ត្រពុទ្ធសាសនាយ៉ាងក្រាស់ក្រែលមុន និងក្រោយរបបខ្មែរក្រហម។ លោក ឱម ខែម

បានបង្រៀននៅសាលាពុទ្ធិកបឋមសិក្សាវត្តទក្ខិណារ៉ាន ឃុំមហាសាំង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ មុនពេលដែលលោកបានចូលបំរើការនៅពុទ្ធិកសមាគមកម្ពុជរដ្ឋ ក្នុងឋានៈជាលេខាធិការ និងជាបណ្ណាធិការ ទស្សនាវដ្ដី "ពន្លឺពុទ្ធចក្រ" ក្នុងចន្លោះឆ្នាំ១៩៦៥-១៩៧៥។ ក្រោយថ្ងៃរំដោះ៧ មករា ១៩៧៩ លោក ឱម ខែម បានចូលមកបំរើការងារនៅមន្ទីរធម្មការ និងសាសនាម្ដងទៀត។ ក្រោយមកមិនយូរប៉ុន្មាន លោកត្រូវបានចាត់តាំងឱ្យមកបំរើការនៅទីស្ដីការក្រុមប្រឹក្សាជាតិរណសិរ្សសាមគ្គីកសាងការពារមាតុភូមិកម្ពុជា នៅនាយកដ្ឋានឃោសនាហ្វឹកហ្វឺននិពន្ធ និងចេញផ្សាយទស្សនាវដ្ដី "រណសិរ្ស ២ ធ្នូ"។

ក្រៅពីកិច្ចការនេះ លោក ឱម ខែម បានស្វះស្វែងប្រមែប្រមូលសៀវភៅផ្សេងៗ មានគម្ពីរព្រះត្រៃបិដកជាដើម ពីរោងចក្រនានា និងពីក្រសួងការបរទេស មកតម្កល់ទុកជាឯកសារនៅវត្តឧណ្ណាលោម សំរាប់ការស្រាវជ្រាវ។ ដោយការខិតខំពីលោក ឱម ខែម និងមិត្តភ័ក្ដិដទៃទៀត ពុទ្ធសាសនបណ្ឌិត្យត្រូវបានបង្កើតឡើងជាជំហានដំបូងនៅវត្តឧណ្ណាលោម ក្រោមការដឹកនាំរបស់ក្រុមប្រឹក្សាជាតិរណសិរ្សសាមគ្គីកសាងការពារមាតុភូមិកម្ពុជា ដែលមានលោក អ៊ុក ម៉ៅ និងលោក ឱម ខែម ជាអ្នកគ្រប់គ្រងផ្ទាល់។ នៅពេលក្រសួងធម្មការ និងសាសនាត្រូវបានបង្កើតឡើងជាផ្លូវការ និងដោយមានការឧបត្ថម្ភពីអង្គការមនុស្សធម៌បរទេស ពុទ្ធសាសនបណ្ឌិត្យមានលទ្ធភាពរៀបចំជាអគារសំរាប់តម្កល់ឯកសារស្រាវជ្រាវ។ លោកត្រូវបានពុទ្ធិកសមាគមកម្ពុជរដ្ឋផ្ដល់កិត្តិយសឱ្យធ្វើជាអគ្គលេខាធិការសមាគម និងបានទទួលមេដាយសំរិទ្ធ និងមេដាយមាសការងារ ក្នុងការសាងសង់អគារពុទ្ធសាសនបណ្ឌិត្យថ្មី។ លោកបានចូលនិវត្តន៍នៅឆ្នាំ ២០០០ ហើយការងារនៅពុទ្ធសាសនបណ្ឌិត្យក៏ត្រូវប្រគល់ជូនលោក ងួន វ៉ាន់ចន្ធី ជាអ្នកគ្រប់គ្រងជំនួសវិញ។ បីឆ្នាំក្រោយមក លោក ឱម ខែម ក៏បានលាចាកលោកនេះទៅ ក្រោមទំនួញសោកស្ដាយពីក្រុមគ្រួសារ សាច់សារលោហិត ក៏ដូចជាសេចក្ដីសោកសង្រេងរបស់អតីតមិត្តរួមការងារដែរ។


លោក ងួន វ៉ាន់ចន្ធី

### លោក ងួន វ៉ាន់ចន្ធី (១៩៥៨-បច្ចុប្បន្ន)

លោកបានមកបំពេញការងារជាប្រធានរបស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ បន្ទាប់ពីលោក ឱម ខែម ។ ក្នុងដំណាក់កាលនោះ ពុទ្ធសាសនបណ្ឌិត្យនៅជាវិទ្យាស្ថានមួយ ដែលមានការងារតិចតួចនៅឡើយ ក្នុងនោះជា

សំខាន់មានការបោះពុម្ពទស្សនាវដ្ដីកម្ពុជសុរិយា និងបោះពុម្ពឡើងវិញនូវសៀវភៅ និងអត្ថបទព្រះពុទ្ធសាសនាប៉ុណ្ណោះ។ ក្នុងការខិតខំប្រឹងប្រែងរបស់លោក ពុទ្ធសាសនបណ្ឌិត្យបានទទួលយកជាបណ្ដើរៗនូវតួនាទីប្រវត្តិសាស្ត្ររបស់ខ្លួន បូករួមទាំងការប្រើប្រាស់នូវបច្ចេកវិទ្យាថ្មីៗទៀតផង។

កង្វះខាតបុគ្គលិកជំនាញជាកត្តាកំណត់មួយដែលរាំងស្ទះដល់ការចំរើនរបស់វិទ្យាស្ថាន។ ដោយហេតុនេះហើយ មានពេលខ្លះ តម្រូវឱ្យមានការស្វែងរកអ្នកជំនាញពីតាមបណ្ដាខេត្តក្រៅៗផងដែរ។ ជាលទ្ធផលនៃការខិតខំប្រឹងប្រែងទាំងនេះ បុគ្គលិករបស់វិទ្យាស្ថានមានការកើនឡើងជាលំដាប់ទាំងផ្នែកក្របខ័ណ្ឌរដ្ឋ ទាំងផ្នែកជាប់កិច្ចសន្យា ដើម្បីបំពេញនូវតម្រូវការចំបាច់ ក្នុងការដំណើរការឡើងវិញរបស់ក្រុមជំនុំទាំងពីររបស់ពុទ្ធសាសនបណ្ឌិត្យ។ ទន្ទឹមជាមួយនេះ ការរីកចំរើនខាងបច្ចេកទេសទាន់សម័យ មានកុំព្យូទ័រជាដើម ក៏បានរួមចំណែកយ៉ាងច្រើន ក្នុងការភ្ជាប់វិទ្យាស្ថានផ្នែកវប្បធម៌អក្សរសាស្ត្រមានប្រវត្តិចំណាស់មួយនេះទៅក្នុងយុគសម័យសាកលភាវូបនីយកម្ម។ គោលដៅទៅថ្ងៃអនាគត គឺធ្វើយ៉ាងណាស្ដារឱ្យបាននូវតួនាទីអតីតរបស់ស្ថាប័ននេះ ពង្រីកបន្ថែមការសិក្សាលើផ្នែកមួយចំនួន ខាងផ្នែកប្រពៃណីរបស់បណ្ដាជនភាគតិច ដែលពុំមានស្ថាប័នដទៃខ្វាយខ្វល់ និងផ្សារភ្ជាប់ជាមួយបច្ចេកវិទ្យាទំនើបផងដែរ។ លើសពីនេះទៀត លោកនឹងព្យាយាមធ្វើយ៉ាងណាប្រែក្លាយស្ថាប័នស្រាវជ្រាវ និងតម្កល់ឯកសារអំពីវប្បធម៌ខ្មែរនេះទៅជាគ្រឹះស្ថានសាធារណៈ ដែលប្រាកដជានឹងជួយជំរុញល្បឿនរីកចំរើនខាងការងារជាមិនខានឡើយ។

## កាលប្បវត្តិ

១៩០៩ សាលាបាលីនៅសៀមរាបត្រូវបានគេបង្កើតឡើងជាលើកដំបូងនៅលើទឹកដីឥណ្ឌូចិន ប៉ុន្តែសាលានេះត្រូវបានបិទទ្វារទៅវិញក្នុងរយៈពេលប្រមាណតែពីរឆ្នាំបន្ទាប់មកប៉ុណ្ណោះ។

១៩១១ សាលាបាលីក្នុងព្រះបរមរាជវាំងនៅទីក្រុងភ្នំពេញ ត្រូវបានតាំងឡើង ជាជំនួសឱ្យសាលាបាលីនៅសៀមរាប។

១៩១៤ ថ្ងៃទី២៤ ខែកញ្ញា តាមរាជប្រកាសលេខ៨៥ តម្រូវឱ្យមានការបង្កើតសាលាបាលីជាន់ខ្ពស់មួយសំរាប់ធ្វើការបង្រៀនភាសាបាលីដែលជាភាសាសំខាន់សំរាប់តែងធម៌វិន័យព្រះពុទ្ធសាសនា។

១៩១៦ ថ្ងៃទី៣០ ខែមីនា សារាចរលេខ៤ បានហាមឃាត់មិនឱ្យព្រះភិក្ខុ សាមណេរ និងគ្រហស្ថទៅធ្វើការសិក្សាព្រះត្រៃបិដកនៅក្រៅប្រទេស និងព្រមទាំងជំរុញឱ្យមកសិក្សានៅសាលាបាលីជាន់ខ្ពស់ ជំនួសវិញ។

១៩២១ ថ្ងៃទី១៥ ខែកុម្ភៈ បណ្ណាល័យមួយដែលមានឈ្មោះថា "ខេមរបណ្ណាល័យ" ត្រូវបានបង្កើតឡើងតាមព្រះរាជក្រិត្យរបស់ព្រះមហាក្សត្រខ្មែរ។

១៩២៥ ថ្ងៃទី១៥ ខែមករា "ខេមរបណ្ណាល័យ" ត្រូវដូរឈ្មោះជា "ព្រះរាជបណ្ណាល័យ" ដែលមានតួនាទី បោះពុម្ពប្រមូល និងអភិរក្សស្នាដៃទាំងពួងដែលស្តីអំពីសាសនា ប្រពៃណីខ្មែរ។

១៩២៦ ទស្សនាវដ្តី "កម្ពុជសុរិយា" ជាខេមរភាសាត្រូវបានចេញផ្សាយជាលើកដំបូង ក្រោមការចាត់ចែងរបស់ព្រះរាជបណ្ណាល័យកម្ពុជា។

១៩២៩ ថ្ងៃទី១៤ ខែធ្នូ តាមព្រះរាជប្រកាសលេខ១០៦ ក្រុមជំនុំមួយដែលមានសមាជិកចំនួន១៤រូប ស្ថិតនៅក្រោមព្រះរាជាធិបតីភាពនៃសម្តេចព្រះអយ្យកោវរចក្ររណេរិទ្ធិ សុធារស ត្រូវបានបង្កើតឡើង ដើម្បីធ្វើការចងក្រង និងបកប្រែព្រះត្រៃបិដក។

១៩៣០ ថ្ងៃទី២៥ ខែមករា "មន្ទីរពុទ្ធសាសនបណ្ឌិត្យ" ដែលមានទីចាត់ការនៅក្នុងបរិវេណ "ព្រះរាជបណ្ណាល័យ" ក្រុងភ្នំពេញ ត្រូវបានបង្កើតឡើង ក្នុងបំណងដឹកនាំការសិក្សាព្រះពុទ្ធសាសនានៅឥណ្ឌូចិន។

១៩៣១ ថ្ងៃទី២២ ខែតុលា ពិធីសម្ពោធស្នាដៃនៃការបកប្រែគម្ពីរព្រះត្រៃបិដកជាភាសាខ្មែរភាគទី១នៅព្រះទីនាំងទេវាវិនិច្ឆ័យក្នុងព្រះបរមរាជវាំងចតុមុខ ក្រុងភ្នំពេញ។

១៩៣២ "ពុទ្ធសាសនបណ្ឌិត្យលាវ" មួយត្រូវបានបង្កើតឡើងជាផ្លូវការ សំរាប់ជួយសំរួលការងារឱ្យពុទ្ធសាសនបណ្ឌិត្យភ្នំពេញ និងសំរាប់ប្រជាជនលាវ។

១៩៣៤ ថ្ងៃទី២៥ ខែមករា ប្រកាសលេខ១២ ស្តីពីការបង្កើតឱ្យមាន "ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ" មួយឱ្យស្ថិតក្រោមអាជ្ញាធររបស់ពុទ្ធសាសនបណ្ឌិត្យ ដើម្បីសិក្សាអំពីទំនៀមទម្លាប់របស់ខេមរជន។

១៩៣៤ ថ្ងៃទី១៩ ខែធ្នូ ព្រះរាជប្រកាសលេខ១៧៩ តម្រូវឱ្យបង្កើត "រោងពុម្ពព្រះរាជទ្រព្យ" ដើម្បីទទួលខុសត្រូវក្នុងការបោះពុម្ពព្រះត្រៃបិដក និងសៀវភៅរបស់ពុទ្ធសាសនបណ្ឌិត្យ។

១៩៣៨ មានការស្នើរឱ្យបង្កើត "មជ្ឈមណ្ឌលវប្បធម៌ខ្មែរ" មួយ ដោយបញ្ចូលនូវស្ថាប័នចំនួនប្រាំ (ពុទ្ធសាសនបណ្ឌិត្យ ព្រះរាជបណ្ណាល័យ សាលាបាលីជាន់ខ្ពស់ ក្រុមជំនុំព្រះត្រៃបិដក និងរោងពុម្ពព្រះរាជទ្រព្យ) ដើម្បីសំរួលដល់ការគ្រប់គ្រងរបស់ពុទ្ធសាសនបណ្ឌិត្យនាពេលនោះ។

១៩៣៨ ខែកញ្ញា មានការបង្កើត "យុវសាលា" សំរាប់ទទួលនិស្សិតដែលចង់ទៅធ្វើការសិក្សាលំហែរជាក្រុមនៅតាមកន្លែងផ្សេងៗ ដោយមានការរៀបចំជាបណ្ណាល័យនៅទីនោះផងដែរ។

១៩៣៩ ថ្ងៃទី៩ ខែឧសភា ប្រកាសអារ៉េតេមួយតម្រូវឱ្យភ្ជាប់ព្រះរាជបណ្ណាល័យទៅពុទ្ធសាសនបណ្ឌិត្យ។

១៩៤១ ថ្ងៃទី៨ ខែមីនា ព្រះសង្ឃ និងអ្នកធ្វើការនៅពុទ្ធសាសនបណ្ឌិត្យបានសម្តែងនូវសេចក្តីអាលោះ អាល័យចំពោះការចូលនិវត្តន៍របស់កញ្ញា ការប៉ុឡែស ដោយរៀបចំឱ្យមានជាពិធីជួបជុំមួយ និងជូនជាអំណោយដល់កញ្ញា។

១៩៤២ ថ្ងៃទី១៧ ខែកក្កដា អាចារ្យ ហែម ចៀវ ត្រូវបានបារាំងចាប់ផ្សឹក ហើយឃុំខ្លួន។

១៩៤២ ថ្ងៃទី២០ ខែកក្កដា មហាបាតុកម្មមួយដែលគេតែងហៅថា "សង្គ្រាមឆត្រ" ត្រូវបានអ្នកស្នេហាជាតិខ្មែររៀបចំឡើង ដោយមានព្រះសង្ឃភ្នំពេញជាច្រើនកាន់ឆត្រចូលរួម ដើម្បីទាមទារឱ្យបារាំងដោះលែងអាចារ្យ ហែម ចៀវ។

១៩៤៣ ថ្ងៃទី១១ ខែកុម្ភៈ ព្រះរាជប្រកាសមួយត្រូវបានចេញផ្សាយ ដើម្បីប្រែឈ្មោះពីព្រះរាជបណ្ណាល័យទៅជាបណ្ណាល័យរបស់ពុទ្ធសាសនបណ្ឌិត្យ។

១៩៤៨ ថ្ងៃទី៣១ ខែធ្នូ "សាលាបាលីជាន់ខ្ពស់" ត្រូវបានផ្ទេរទៅឱ្យរដ្ឋាភិបាលដោយរាជការអាណាព្យាបាលបារាំងក្រោមអធិបតីភាពលោក ប្រង់ស័រ ម៉ារទីនី ជាទីប្រឹក្សាក្រសួងធម្មការ និងជាអគ្គលេខាធិការនៃមន្ទីរពុទ្ធសាសនបណ្ឌិត្យ។

១៩៥០ ថ្ងៃទី១៥ ខែតុលា រាជការបារាំងបានផ្ទេរ "ពុទ្ធសាសនបណ្ឌិត្យ" ឱ្យរាជការខ្មែរគ្រប់គ្រងផ្ទាល់វិញ។

១៩៥០ ព្រះករុណាជាអង្គម្ចាស់ជីវិតលើត្បូងទ្រង់ស្តេចយាងដោយផ្ទាល់ព្រះអង្គ មករៀបចំមន្ទីរពុទ្ធសាសនបណ្ឌិត្យឱ្យនៅរួមជាមួយក្រសួងធម្មការ។

១៩៥២ មានការចុះផ្សាយក្រឹត្យលេខ១២៨ ស្តីពីការរៀបចំឡើងវិញនូវក្រសួងធម្មការ ការបង្រៀនសាសនា និងសាលាវិចិត្រសិល្បៈ។

១៩៥៧ ថ្ងៃទី ៦ ខែ មិថុនា រដ្ឋសភាបានអនុម័តច្បាប់ផ្តល់អំណាចឱ្យពុទ្ធសាសនបណ្ឌិត្យធ្វើការរៀបចំ និងសំរប

សំរួលទូវការសិក្សាពុទ្ធសាសនាខាងហិនយាន ក្នុងចំណោមប្រជាជននៃប្រទេសកម្ពុជា និងក្រុមជនជាតិខ្មែរនៅក្រៅប្រទេស ។

១៩៩២ រដ្ឋសភានៃរដ្ឋកម្ពុជាបានអនុម័តច្បាប់បង្កើតឱ្យមាន ក្រសួងធម្មការឡើងវិញ ហើយពុទ្ធសាសនបណ្ឌិត្យក៏បានចាប់បដិសន្ធិជាថ្មីពីពេលនោះដែរ ។

១៩៩៣ ថ្ងៃទី៥ ខែតុលា រដ្ឋាភិបាលបានអនុញ្ញាតឱ្យ ពុទ្ធសាសនបណ្ឌិត្យ ធ្វើការបោះពុម្ពផ្សាយទស្សនាវដ្ដី "កម្ពុជសុរិយា" ឡើងវិញ ពីឆ្នាំ១៩៩៤ តទៅ ។

១៩៩៨ ថ្ងៃទី២២ ខែឧសភា វេលាម៉ោង ៨ព្រឹក ពិធីសម្ពោធអគារពុទ្ធសាសនបណ្ឌិត្យបច្ចុប្បន្នត្រូវបានបើកសម្ពោធឱ្យប្រើប្រាស់ជាផ្លូវការ ។

## សន្ធានុក្រមឋានន្តរស័ក្តិគណៈសង្ឃខ្មែរមួយចំនួន

**សម្តេចព្រះសង្ឃរាជទី១:** គឺជាងារសម្តេចព្រះសង្ឃរាជមួយព្រះអង្គពិសេសជាងព្រះសង្ឃរាជអង្គដទៃៗ ទៀត។ ងារនេះត្រូវបានព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះរាជទានចំពោះសម្តេចព្រះសង្ឃរាជ ជោតញ្ញាណោ ជួន ណាត តែមួយព្រះអង្គគត់។

**សម្តេចព្រះមហាសុមេធាធិបតីសង្ឃរាជ:** គឺជាងាររបស់សម្តេចព្រះសង្ឃរាជគណៈមហានិកាយ។ ងារនេះត្រូវបានព្រះករុណាព្រះមហាក្សត្រប្រទានតែងតាំងចំពោះ សម្តេចព្រះសង្ឃរាជ ជាពិសេសចាប់តាំងពីសម័យសម្តេច ព្រះសង្ឃរាជ ជួន ណាត (ខាងគណៈធម្មយុត្តិ ហៅងារនេះថា ព្រះសុគន្ធាធិបតី)។

**មហាសង្ឃនាយកៈ** គឺជាងារសំគាល់ព្រះភិក្ខុមួយរូបដែលជាប្រធានសង្ឃក្នុងព្រះរាជាណាចក្រកម្ពុជាទាំងមូល។ ងារនេះ តាមលក្ខណៈជាក់ស្តែងមានតួនាទីស្មើនឹងព្រះសង្ឃរាជដែរ ប៉ុន្តែមានកិត្តិយសទាបជាងព្រះសង្ឃរាជ ឬ សម្តេចព្រះសង្ឃរាជ។ ជាពិសេសនៅពេលដែល ព្រះអង្គមិនទាន់បានទទួលនូវការតែងតាំងជាសម្តេចព្រះសង្ឃរាជពីព្រះករុណាព្រះមហាក្សត្រ។

**ព្រះធម្មលិខិតៈ** គឺជាងារព្រះរាជាគណៈថ្នាក់ឯកក្នុងបណ្តាងាររាជាគណៈថ្នាក់ឯកទាំងបី។ ជាធម្មតាងារព្រះធម្មលិខិតនេះមានតួនាទីជាប្រធានព្រះថេរសភាសង្ឃ។ ជួនកាលងារព្រះធម្មលិខិត នេះបានទទួលនូវ ព្រះរាជទានពីព្រះករុណាព្រះមហាក្សត្រនូវងារជាសម្តេចផងដែរ។

**ថេរសភាៈ** ទទួលបន្ទុកក្នុងការដោះស្រាយ នូវអធិករណ៍ផ្សេងៗ ដែលកើតឡើងដោយថាហេតុនៅក្នុងព្រះពុទ្ធសាសនា។

**ព្រះពោធិវង្សៈ** គឺជាងារព្រះរាជាគណៈថ្នាក់ឯកនៅក្នុងព្រះពុទ្ធសាសនា។ ងារនេះជាធម្មតាត្រូវបានព្រះករុណាព្រះមហាក្សត្រព្រះរាជទាននូវងារជាសម្តេចផងដែរ។ តាមប្រពៃណី ព្រះភិក្ខុដែលបានទទួលងារជា ព្រះពោធិវង្ស មានតួនាទីទទួលបន្ទុកពុទ្ធិកសិក្សាក្នុងព្រះរាជាណាចក្រកម្ពុជា។

**ព្រះមហាវិមលធម្មៈ** គឺជាងារព្រះរាជាគណៈថ្នាក់ទោមានតួនាទីជាជំនួយការអមសម្តេចព្រះសង្ឃរាជ។ តួនាទីមួយទៀតគឺជាភត្តុទ្ទេសក៍ (អ្នកចែកបាយ) ក្នុងព្រះរាជនិមន្តន៍ និងប្រិតប្រៀងព្រះភិក្ខុសង្ឃឱ្យមានសណ្តាប់ធ្នាប់រៀបរយ។

**ព្រះពុទ្ធឃោសាចារ្យៈ** នាមព្រះមហាថេរមួយអង្គ ជាអ្នកប្រាជ្ញធំកើតនៅប្រទេសឥណ្ឌាប៉ែកកណ្តាលក្នុង

សតវត្សរ៍ទី១០នៃពុទ្ធសករាជ (សតវត្សរ៍ទី៥ នៃគ្រិស្តសករាជ) បានឆ្លងទៅនៅលង្កាទ្វីបក្នុងសតវត្សរ៍នោះ រូបរួមគំនិតជាមួយនឹងលោកអ្នកប្រាជ្ញក្នុងលង្កាទ្វីប បានប្រែអដ្ឋកថាព្រះត្រៃបិដកអំពីភាសាសីហឡមកជាមគធភាសាចប់គ្រប់គ្រាន់ ព្រមទាំងបានតែងគម្ពីរឯទៀតមានគម្ពីរ វិសុទ្ធិមគ្គ និងអដ្ឋកថាធម្មបទជាដើម ទុកជាប្រយោជន៍សំខាន់ក្នុងព្រះពុទ្ធសាសនា មានជាប់តទៅទៀតមកដល់សព្វថ្ងៃនេះ។ ព្រះមហាក្សត្រទាំងឡាយ ក្នុងកម្ពុជប្រទេសបានយកព្រះនាមព្រះថេរអង្គនេះ មកតាំងជាសមណស័ក្តិទីរាជាគណៈថ្នាក់ទោមួយក្នុងចំណោមព្រះរាជាគណៈថ្នាក់ទោទាំង៦ ដែលចេះដឹងព្រះត្រៃបិដកមុតមាំហើយ ដែលមានតួនាទីជាជំនួយការអមសម្តេច ព្រះសង្ឃរាជគណៈមហានិកាយ។

**ព្រះឃោសធម្ម:** គឺជាងារព្រះរាជាគណៈថ្នាក់ទោមានតួនាទីជាជំនួយការអមសម្តេចព្រះសង្ឃរាជ។

**ព្រះសិរីសម្មតិវង្ស:** គឺជាងារព្រះរាជាគណៈថ្នាក់ត្រីមួយក្នុងបណ្តាងារព្រះរាជាគណៈថ្នាក់ត្រីទាំង៦។ ងារនេះមានតួនាទីជាជំនួយការអមព្រះសង្ឃរាជគណៈមហានិកាយ។

**ព្រះឧបលិវង្ស:** គឺជាងារព្រះរាជាគណៈថ្នាក់ត្រី មានតួនាទីជំនួយការអមសម្តេចព្រះសង្ឃរាជ។

**ព្រះទេពមុនី:** គឺជាងារព្រះរាជាគណៈថ្នាក់ចត្វាមួយ ក្នុងបណ្តាងារព្រះរាជាគណៈថ្នាក់ចត្វាទាំង២០ ដែលមានតួនាទីជាជំនួយការអមសម្តេចព្រះសង្ឃរាជ។

**ព្រះសាសនសោភ័ណ:** គឺជាងារព្រះរាជាគណៈថ្នាក់កិត្តិយសមួយក្នុងព្រះពុទ្ធសាសនា។ ងារនេះត្រូវ បានព្រះករុណាព្រះមហាក្សត្រប្រទានថ្វាយចំពោះសម្តេចព្រះសង្ឃរាជ ជួន ណាត កាលព្រះអង្គនៅជាព្រះរាជាគណៈនៅឡើយ ។

**ព្រះឧត្តមមុនី:** គឺជាងារព្រះរាជាគណៈថ្នាក់កិត្តិយស ដែលត្រូវបានព្រះករុណាព្រះមហាក្សត្រព្រះរាជទានចំពោះភិក្ខុមួយរូប ដែលមានគុណធម៌ និងការសិក្សាអប់រំជ្រៅជ្រះ។ ជាប្រពៃណីងារនេះត្រូវបានប្រគេនចំពោះព្រះភិក្ខុ ដែលមានចំណេះដឹងខាងអភិធម្មច្បាស់លាស់ ជួនកាលងារនេះ ក៏បានទទួលនូវងារជាសម្តេចផងដែរ។

**ព្រះសិរីវង្ស:** គឺជាងារព្រះរាជាគណៈថ្នាក់កិត្តិយស ដែលត្រូវបានព្រះករុណា ព្រះមហាក្សត្រព្រះរាជទាន។

**ព្រះគ្រូសង្ឃវិជ្ជា:** គឺជាងារឋានានុក្រមក្នុងព្រះពុទ្ធសាសនា។ ងារនេះមានឋានៈទាប ជាងព្រះរាជាគណៈនិងត្រូវតែងតាំងដោយព្រះសង្ឃរាជ និងមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា។ ងារនេះត្រូវបានប្រគេនចំពោះសម្តេចព្រះសង្ឃរាជ ហួត តាត កាលព្រះអង្គនៅជាព្រះគ្រូនៅឡើយ។

**ព្រះវិន័យធរ:** គឺជាងាររបស់ព្រះភិក្ខុមួយរូប ដែលមានតួនាទីជាអ្នកត្រួតត្រាខាងវិន័យនៅក្នុងសហគមន៍សង្ឃ។ ពាក្យនេះមានប្រវត្តិជាប់ទាក់ទងនឹងភិក្ខុទ្រទ្រង់នូវចំណែក២យ៉ាង ក្នុងព្រះពុទ្ធសាសនា ដែលមានមកតាំងពី

បុរាណកាលគឺ វិន័យធរ និងធម្មកថិក ។ សព្វថ្ងៃ ពាក្យនេះប្រើសំគាល់ភិក្ខុមួយរូបដែលជាអ្នកត្រួតត្រាខាងវិន័យអមព្រះគ្រូអនុគណ ព្រះមេគណ និងក្នុងវត្តនិមួយៗផងដែរ ។

**ព្រះតេជគុណៈ** ជានាមហៅសំគាល់អ្នកបួសក្នុងព្រះពុទ្ធសាសនា ឬសំគាល់បុគ្គលជាឥស្សរជនជាន់ខ្ពស់ ។ នៅពេលបច្ចុប្បន្ននេះគេប្រើពាក្យនេះសំរាប់ហៅចំពោះតែអ្នកបួសក្នុងព្រះពុទ្ធសាសនាប៉ុណ្ណោះ ។

**ឧត្តមសង្ឃាយនាៈ** គឺត្រូវបានប្រើដោយអ្នកប្រាជ្ញខ្មែរ ដើម្បីសំគាល់នូវសង្គាយនាមួយ របស់ក្រុមជំនុំព្រះត្រៃបិដកខ្មែរ នៅពុទ្ធសាសនបណ្ឌិត្យ ដែលបានស្រាវជ្រាវ ចងក្រង រៀបរៀង និងបកប្រែគម្ពីរព្រះត្រៃបិដកក្នុងសាស្ត្រាស្លឹករឹតពីភាសាបាលីមកជាភាសាខ្មែរ ហើយបានបោះពុម្ពចប់សព្វគ្រប់នៅឆ្នាំ១៩៦៨ ។

ពុទ្ធសាសនបណ្ឌិត្យ
បណ្ណាល័យ
LIBRARY
BUDDHIST INSTITUTE

## ឯកសារយោង

### ១. បណ្ណសារដ្ឋានជាតិ

ឯកសាររ៉េស៊ីដង់ជាន់ខ្ពស់
សៀវភៅរាជកិច្ចរាជការ
រូបភាព

### ២. ស្ថាប័នជាភាសាខ្មែរ

ទស្សនាវដ្ដី កម្ពុជសុរិយា
ទស្សនាវដ្ដី មិត្តសាលាបាលី
ទស្សនាវដ្ដី ពុទ្ធចក្រ
ទស្សនាវដ្ដី អក្សរសាស្ត្រ
ទស្សនាវដ្ដី សាសនាកិច្ចានុក្រម
កាសែត នគរវត្ត
គុយ ឡូត ១៩៧២ ជីវប្រវត្តិព្រះអាចារ្យ ហែម ចៀវ
គីម សំបូរ ២០០៤ ព្រះរាជជីវប្រវត្តិសម្ដេចព្រះសង្ឃរាជ
គីម តូ ទ្រិញ វ៉ាញ និងអ្នកដទៃ ១៩៧០ ប្រជុំធម្មកថា ភ្នំពេញ: វត្តឧណ្ណាលោម
ឃីង ហុក ឌី ២០០២ មាលីបទ អក្សរសិល្ប៍ សតវត្សទី២០ ភ្នំពេញ: បណ្ណាគារអង្គរ
ជ័យ ចាប ១៩៨៨ ជីវប្រវត្តិអ្នកនិពន្ធខ្មែរ ភ្នំពេញ
ជា ទន់ គីម តូ និងអ្នកដទៃ ១៩៧៣ ជីវប្រវត្តិសង្ខេប និងធម្មកថា ភ្នំពេញ: រោងពុម្ពតារាវស្ទី
ប៊ុណ្ណ ច័ន្ទ ម៉ុល ១៩៧១ គុកនយោបាយ ភ្នំពេញ
លី្វ ឯម ជួន ណាត ហួត តាត និងអ្នកដទៃ បោះពុម្ពឡើងវិញ ១៩៩៧ អវសានកិច្ច ភ្នំពេញ: បណ្ណាគារត្រៃរតន៍
ហួត តាត បោះពុម្ពឡើងវិញ ១៩៩៣ កល្យាណមិត្តរបស់ខ្ញុំ ភ្នំពេញ: ពុទ្ធសាសនបណ្ឌិត្យ
ហួត តាត បោះពុម្ពឡើងវិញ ១៩៩៥ វេយ្យាករណ៍សំស្ក្រឹត ភ្នំពេញ: ពុទ្ធសាសនបណ្ឌិត្យ
ហួត តាត (អ្នកកែសម្រួល) បោះពុម្ពឡើងវិញ១៩៩៥ ឧប្បត្តិហេតុនៃព្រះត្រៃបិដកប្រែ រោងពុម្ពមិត្តភាពកម្ពុជា-ជប៉ុន

## ៣. ស្នាដៃជាភាសាបរទេស


EFEO *Chercheurs d'Asie: Répertoire biographique des membres scientifiques de l'École française d'Extrême-Orient* (EFEO, Paris, 2002)

Le Ministre de l'Information du Royaume du Cambodge (1957) *Le Cambodge célèbre l'an 2500 de l'ère Bouddhique* (Cambodia celebrates year 2500 of the Buddhist era) Phnom Penh

Buddhist Institute (1961) *A Buddhist Study Centre in Cambodia* (Phnom Penh: Buddhist Institute)

Leang Hap An (1970) *Biography of Samdech Preah Sanghareach Chuon Nath, the chief of Mahanikaya Order* (Phnom Penh: Buddhist Institute, Volume 7)

*Le Sangkum, revue politique illustrée*, n. 12 – Juillet 1966; n. 13, Août 1966

First Edition, 2005

© The Buddhist Institute, Phnom Penh, Cambodia
All rights reserved.

ISBN-13: 978-99950-50-00-9
ISBN-10: 99950-50-00-5

Printed and bound in Phnom Penh, Cambodia by X7Design Group.

Book design and layout: X7Design Group

Front Cover:
The Royal Library/Buddhist Institute, courtesy of the National Archives of Cambodia.
Cameo portraits, from left to top right: Suzanne Karpelès (*Nagaravatta*, 1941), Son Ngoc Thanh (Private collection), Venerable Em Sou, Venerable Huot Tath, Venerable Chuon Nath (Courtesy of National Archives of Cambodia).

Back Cover: Detail of the Buddhist Institute, 2005, by Anthony Maturin

Retail price direct from the Buddhist Institute: $US 2.50

HEINRICH
BÖLL
FOUNDATION

Embassy of
the Federal
Republic of
Germany
Phnom Penh

# The Buddhist Institute: A Short History

researched and written by
Chheat Sreang
Yin Sombo
Seng Hokmeng
Pong Pheakdeyboramy
Saom Sokreasey

edited and translated by
Penny Edwards

The Buddhist Institute
2005

# Contents


Acknowledgements ........ 4

Translator's Note ........ 6

Preface ........ 7

Introduction ........ 8

The Royal Library: 1921-1929 ........ 13

The Buddhist Institute 1930-2005 ........ 21

- Naissance: 1929-1942 ........ 21
- Transition: 1942-1954 ........ 33
- Independence: 1954-1975 ........ 37
- Closure: 1975-1992 ........ 40
- Reincarnation: 1992-2005 ........ 40

Conclusion ........ 46

Biographical Sketches ........ 48

Glossary of Khmer Buddhist Terms ........ 67

Timeline ........ 72

Bibliography ........ 75

# Acknowledgements

This book would simply not have been possible without the support of the Heinrich Böll Foundation, who funded both the Buddhist History Research Project from January to June 2005 during which time this book was researched and written, and subsidised the bulk of the publication costs. We are also deeply grateful to the German Embassy to Cambodia and to UNESCO, Phnom Penh Office, for their generous subsidy of publication costs.

At the Buddhist Institute, this project found an enthusiastic backer in the Director, Mr. Nguon Van Chanthy, who has offered his full support from the outset, and has assisted us with interviews and access to Institute records.

The slimness of this volume belies the breadth of our intellectual debt to many colleagues in and outside Cambodia. Since this project began in late 2004, Madame Jacqueline Filliozat of the Ecole Française d'Extrême Orient has provided important support and gone to great trouble to locate, digitize and share with us rare documents from her own personal collections as well as those from the EFEO in Paris. Dr. Christopher Goscha has displayed similar generosity with documents related to the Buddhist Institute. The scope of this study has precluded our using all of these. We hope that this small work will plant the seed for future, deeper treatments of modern Buddhism and its development in Cambodia; thanks to the generosity of Madame Filliozat and Dr Goscha, scholars so inclined will now find a rich archive at the Institute, including microfilms of the Khmer newspaper *Nagaravatta*, kindly placed on loan to the Institute by Professor David Chandler.

His Excellency Nouth Narang, President of the Buddhist Institute Research Committee, offered valuable advice concerning the substance and design of this volume. Dr. Hean Sokhom proof-read the Khmer manuscript and offered valuable semantic and stylistic guidance. His Excellency Hing Kim Than gave generously of his time in providing information and reflections about his memories of the Buddhist Institute in the 1960s. Mr. Henri Locard has offered valuable encouragement and practical help throughout, as has Dr. Khing Hoc Dy. Venerable Khy Sovanratana and David Chandler kindly reviewed the manuscript, at very short notice, and also helped polish the final text and glossary. Mr. Anthony Maturin volunteered his time, skills and aesthetic sense for the front and back cover design, to excellent effect.

Mrs. Sandra Jones, Research Advisor at the Institute, helped to co-ordinate publication; she and Mr. Sor Sokny are also to be thanked for fundraising for this volume. Finally, we would like to thank Dr. Gregor Müller and the staff of the National Archives of Cambodia; the National Library of Cambodia, and the library of the Buddhist Institute, for their assistance with locating relevant documents.

# Translator's Note

This work is a collaborative effort written in Khmer by multiple authors, working with a variety of predominantly French and Khmer sources. Although nominally in charge of the project leading to this publication, I did little through its duration other than point an energetic and inquisitive team of researchers in the direction of various archives and libraries, and encourage them to interpret primary sources with an eye to the political and intellectual climate of the time, and an antenna for the personalities of the period.

Since it is personalities as much as policies that shape any institution, I was delighted by the results of my colleagues' initial foray into the Buddhist Institute's formative years and its recent rehabilitation. Recorders of a blurred past, these scholars are also integral to the Institute's future development.

My English translation of their Khmer publication veers, sometimes chaotically, between literal representation and poetic licence. I am indebted to David Chandler for adding elegance to an earlier, hurried draft, and to Sandra Jones for her meticulous copy editing of a later draft. All errors of translation and interpretation remain my own.

My deepest thanks go to my husband Peter Bartu, and my children Ben, Maxine and Lorenza, for suffering my distracted presence and my extended absences during the final stages of this publication.

Penny Edwards,
Director,
Buddhist Institute History Project 2005

# Preface

*"This is the first book to discuss the history, role, activities and contribution of the Buddhist Institute, from its inception to the present time. In its 75 year history, the Buddhist Institute has passed through many different developments.*

*I consider this book to be of significant value to both general readers and scholars researching Cambodian culture and Buddhism. Despite its brevity, this work will light the way for future research concerning the priceless contribution of the Buddhist Institute towards Cambodian Buddhism, culture and customs."*

Venerable Khy Sovanratana
Preahreachkannah Honorary Advisor to
Samdecpreahsanghareach of the Mahanikay,
Professor,
Preah Sihanouk Buddhist University

*"This marvelous book tells the story of one of the most important cultural institutions in modern Cambodia, and provides fascinating biographical sketches of the scholars and monks who worked so hard to strengthen Cambodian Buddhism and to collect and disseminate information about Cambodian customs, history and folklore. I am delighted to celebrate the Institute's 75$^{th}$ anniversary, and to praise this absorbing study."*

Professor David P. Chandler
Monash University, Australia

# Introduction

For seventy-five years now, the Buddhist Institute has played a leading role in the dissemination of Buddhism and literature, guiding the Khmers in their quest for high culture. Today, the Buddhist Institute is playing an active role in the study, research and the collection of materials about Khmer culture. Under the guidance of the Institute and its newly established Research Committee, a number of young researchers are undertaking projects in such areas as history, literature, Buddhism, customs and the challenges currently facing Cambodia. These activities promise to consolidate the Institute's reputation in the field of academic research.

What we know today as the Buddhist Institute acquired its mandate, name and role under the French protectorate. Initially, 'The Buddhist Institute' was called 'The Indigenous Institute for the Study of Buddhism of the Little Vehicle.' Different versions of this name soon came into use. Some called it 'The Buddhist Studies Commission' or 'The Buddhist Studies Institute'. All these names were used after Independence. At that time, the most popular name was 'Institute (*vicciethaan*) of Buddhist Studies', perhaps to raise the status of this important institute in keeping with the country's newfound autonomy. Others knew it as 'The Ministry of the Buddhist Institute'. From 1950 to 1975, and again from 1992 until today, the Buddhist Institute has remained a department under the Ministry of Cults and Religion. Nowadays, this department is officially known as 'The Buddhist Institute (*viccies'thaan*)'. In fact, the Khmer terms *vicciethaan* and *viccies'thaan* are only very slightly different. Both mean 'institutions of study and research.'

The resurrection of this research institute in 1992 with the assistance of the Government and the support of a number of foreign aid organisations offered great hope for researchers to pick up the strands of Khmer national cultural identity. In the first stage, after the fall of the genocidal regime of Democratic Kampuchea (1975-1978), the Buddhist Institute faced many difficult obstacles to progress in raising confidence in various milieux, including the loss of research materials and staff. Nevertheless, the reconstruction of this once prestigious research institute truly demonstrated the preoccupation with national culture, which had come under severe threat in the recent past.

In the People's Republic of Kampuchea and the State of Cambodia, freedom of religion expanded for the general public within the legal parameters of state policy directives. In this phase of economic reconstruction, the historic nature of the Buddhist Institute was not discussed. In the late 1980s, a building was erected in the grounds of Wat Ounaloum, the chief Mahanikay temple in Phnom Penh. A plaque announced that it was the Buddhist Institute, but the institute itself had still not been organised.

After the victory of Khmer Rouge liberation forces against the Lon Nol Republic on 17 March 1975, many Khmer people imagined that their nation had finally been released from civil war and that the national culture was destined to reach new heights. Instead, they witnessed the reverse of these hallucinations. Whatever people had owned before, they lost. Individual liberty, freedom of religious belief, expression, study and the use of money were all forbidden. Furthermore, intellectual institutions and scholars themselves were almost entirely destroyed. The Buddhist Institute met a similar fate and was forced to close its doors from the day of liberation. After this, many materials which the Institute had collected and collated from its inception were either burned, or went missing due to neglect. The goal of the regime was to create a new history for the Khmer people, a new history which would break with the past 2000 years. The effect was the massive destruction of the customs and culture of this people.

Once treasured documents, and the past reputation of the Buddhist Institute, were destroyed in different ways at this time. After Independence, the Buddhist Institute had been highly valued by a wide range of researchers, following its extensive dissemination of its works. The many precious manuscripts housed in the Institute's library were a particularly prized resource for scholarly research. In the countryside, the reputation and activities of the Buddhist Institute were also well known. This legacy dated to the colonial period.

When the French Protectorate established this Institute in 1930, its founding aim was to foster the Buddhist studies in the Indochina region, so as to transform Buddhism into a strong force that could combat the influence of Siamese culture. The remit of the Institute was to cooperate closely with other institutions, including the Higher School of Pali, the Royal Library, and the Tripitaka Commission, which had also been established with a view to curbing Siamese influence in Cambodia.

As is well known, Khmer civilisation was long intertwined with that of India. A long history of cultural flows, including Buddhism, connected Cambodia to Siam and Sri

Lanka. Because Buddhist education had reached a higher standard in Siam than in Cambodia, Khmer monks often travelled there to continue their studies.

During the time of the French Protectorate Siam was not under direct foreign control. However, it was under the influence of Britain, which had colonised Malaya and Burma. For this reason, the French, who were competing with Britain for colonial possessions, used a variety of means to stop Siam exercising influence over Indochina.



Famous five: The great Mahanikay scholars
Thaong, Lvi Em, Em Sou, Chuon Nath and Huot Tath.

One such method was to stop Khmer monks going to Siam for their studies, by strengthening the education and schooling in Cambodia. In 1909, there was an attempt to establish a School of Pali in Siem Reap. Following its closure in 1911, a school of Pali was established in the royal palace in Phnom Penh. In 1914 the school moved to new premises and was renamed the 'Higher School of Pali'. Its first principal was Venerable Thaong.

His Holiness of Brilliant Dhamma (*Preahmahavimulthor*) Thaong was a monk and scholar who had advanced the study of the Dhamma, the Vinaya and the Pali language. A special interest of his was the study of the scriptures of the Tripitaka, and he favoured any branch of scholarship which would allow Buddhism to evolve in step with the national development of his people. Like his predecessor Chief Patriarch (*Sanghareach*) Thieng, chief of the Mahanikay Order, he respected traditions. However, Venerable Thaong was not averse to breaking with established tradition where doing so allowed him to follow what

he saw as correct Theravada practice. He was a staunch supporter of the Royal Library, an institution that also helped the advance of Buddhism.



These monks are wearing *phakrap* a mark of the old school Mahanikay

Alongside the restitution of national religion, the Buddhist Institute focused its attention on Khmer customs and traditions. Its devotion to the moral education of the Khmer people, was matched by its commitment to collect and conserve the precious cultural heritage comprising our national identity. In the colonial era, nationalists cultivated the Buddhist Institute as a bastion of Khmer knowledge from which they opposed moves to destroy Khmer culture. At a time when Cambodia was under foreign control, the Buddhist Institute's preoccupation with the nation's cultural destiny warrants further attention.

In the current political climate, the Buddhist Institute is primarily concerned with retrieving its historic reputation in research and with the collection of documents and works related to religion, history, literature, the arts, and national Khmer customs and traditions. At this juncture, its own evolution requires proper scientific study. Clearer knowledge of our past will allow the Institute to plan its present direction so as to make an active contribution to enriching national literature and culture in this age of globalisation. By researching the role and the activities of the Institute in its various incarnations under several distinct political regimes, we hope to learn important lessons for resurrecting the Institute and enhancing its once excellent reputation. At the same time, the Institute's current role in the conservation of the cultural identity that is our ancestral heritage has a definite part to play in national development.

Finally, a word of clarification. This publication is only a brief work by researchers at the Buddhist Institute. It was assembled over a six-month period to mark our alma mater's $75^{th}$ anniversary. Due to the destruction of many documents in the recent past, this work has relied heavily on materials in the National Archives. Our other sources have been the Buddhist Institute publication, *Kampuja Surya*, and the Khmer newspaper, *Nagaravatta*, which are now held on microfilm at the Institute, as well as Khmer and French journals from the Sangkum Reastr Niyum period held at the National Library. In the near future we hope to produce a more detailed and sophisticated academic treatment of the development and the role of the Institute, focusing on the period after Independence.

Chheat Sreang,
Deputy Director,
Buddhist Institute History Project
May, 2005



# History



# The Royal Library, 1921-1929

The Royal Library was established with the express purpose of collecting diverse materials, especially those concerning Buddhism, to assist members of the Khmer *sangha* in their research and scholarship. It was also committed to meeting the needs of foreign and Khmer lay scholars. Its particular focus was on Khmer customs and Buddhism, which its founders recognised as being the most important belief of Khmer people across the country.



